18K-CA082-東埔寨文：人生課題-字.pdf 1 2019/7/31 下午 05:49:14

# បញ្ហាជីវិត

ដោយ

ភិក្ខុធម្មបាល ខៀវ-ជុំ

វត្តលង្កា ភ្នំពេញ

ព.ស. ២៥០៣ គ.ស. ១៩៦១

ភ្នំពេញ

ការផ្សាយរបស់អង្គការមូលនិធិវត្តបញ្ញាធំ

បោះពុម្ពចែកជាធម្មទាន

ព.ស. ២៥៦៣ គ.ស. ២០១៩

CA082 បញ្ហាជីវិត Problems of life

As this is a Dhamma text,
we request that it be treated with respect.
If you are finished with it,
please pass it on to others or
offer it to a monastery, school or public library.
Thanks for your co-operation.
**Namo Amitabha!**

《東埔寨文：人生課題 Problems of life》
財團法人佛陀教育基金會 印贈
Printed for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Website: www.budaedu.org ; overseas@budaedu.org,
**This book is for free distribution, it is not to be sold.**
សម្រាប់ចែកជាធម្មទាន
Printed in Taiwan
CA082

# បញ្ញាជីវិត

ដោយ

ភិក្ខុធម្មបាល ខៀវ-ជុំ

វត្តលង្កា ភ្នំពេញ

ព.ស. ២៥០៣ គ.ស. ១៩៦១

ភ្នំពេញ

ការផ្សាយរបស់អង្គការមូលនិធិវត្តបញ្ញាធំ

បោះពុម្ពចែកជាធម្មទាន

ព.ស. ២៥៦៣ គ.ស. ២០១៩

# បញ្ហាជីវិត

ក្នុងបណ្ដាបញ្ហាទាំងឡាយ, បញ្ហាជីវិតមានសេចក្ដីថ្លៃថ្នូរក្រៃលែងជាងបញ្ហាណាៗ ទាំងអស់, ទស្សនវិទូនិងសាស្ត្រាចារ្យនៃលទ្ធិសាសនាទាំងឡាយ ព្យាយាមស្រាវជ្រាវរករឿងជីវិតជាច្រើន, លុះខគោលទស្សនវិជ្ជានិងឱវាទខាងសាសនា ដែលទាក់ទងនឹងជីវិតមានជាច្រើនអនេក, តែរឿងជីវិតជារឿងរៀនមិនចេះចប់ មិនអាចនឹងបានក្ដីស្វាងច្បាស់លាស់ ព្រោះសាស្ត្រាចារ្យឬទស្សនវិទូទាំងនោះមានយោបល់ប្លែកៗគ្នាក្នុងរឿងជីវិត ដែលយើងអាចចែកចេញបានជា ៣ ប្រការគឺ :

១-) ឃើញថាជីវិតនេះ ប្រកបដោយសេចក្ដីទុក្ខព្រួយលំបាក,

២-) ឃើញថាជីវិតនេះ ប្រកបដោយសេចក្ដីសុខសប្បាយ,

៣-) ឃើញថាជីវិតនេះ មិនមានន័យអ្វីសោះ, មនុស្សយើងនឹងមានសេចក្ដីសុខ ឬទុក្ខ មិនមែនអាស្រ័យនៅក្នុងលក្ខណៈនៃជីវិត តែមកអំពីអំណាចនៃវត្ថុធាតុដែលជីវិតត្រូវប្រាស្រ័យទាក់ទងនឹងអំពើនៃម្ចាស់ជីវិតនុ៎ះឯង ។

សេចក្ដីពិត យោបល់ទាំង ៣ ប្រការនេះ, សូម្បីមានផ្លូវខុសគ្នាក៏ដោយ តែសាស្ដាចារ្យ និងទស្សនវិទូទាំងឡាយក្រោយដែលបានរៀបចំលទ្ធិសាសនានិងលំខគោលនៃទស្សនវិជ្ជារបស់ខ្លួនហើយក៏ត្រឡប់ជាមានកម្មវិធីស្របគ្នាគឺបង្រៀនមនុស្សឲ្យប្រកបគុណធម៌ល្អតាមសេចក្ដីយល់ឃើញរៀងខ្លួន, ដែលឃើញថា ជីវិតជាធម្មជាតប្រកបដោយសេចក្ដីទុក្ខព្រួយ ក៏បង្រៀនឲ្យចេះខំប្រឹងតស៊ូ ឬ គេចដោះសេចក្ដីទុក្ខលំបាកនោះដោយព្យាយាមសាងសន្សំសេចក្ដីល្អគ្រប់យ៉ាង, ដែលឃើញថាជីវិតជាធម្មជាត ប្រកបដោយសេចក្ដីសុខសប្បាយ, ក៏បង្រៀនឲ្យព្យាយាមការពារភ័យវិបត្តិ ដែលមកធ្វើឲ្យគុណតម្លៃ

របស់ជីវិតបាត់បង់ទៅ ។ យោបល់ទី ៣ ដែលឃើញថាជីវិតមិនមានចំណុចទីដៅអ្វីសោះ នៅក្នុងតួនៃជីវិតនោះ ក៏បង្រៀនឲ្យមនុស្សសាងសន្សំវត្ថុធាតុនៅជុំវិញជីវិតឲ្យបានប្រកបដោយសេចក្ដីល្អដូចគ្នា ។

តែរឿងជីវិត, ជារឿងមានតម្លៃច្រើន ការបកប្រែលក្ខណៈរបស់ជីវិតទៅក្នុងន័យណានឹងមានសេចក្ដីថ្លៃថ្នូរ ក្នុងការស្វែងរករបបតស៊ូ ដើម្បីស្រាយបញ្ហាជីវិតនោះជាមុខងាររបស់ម្ចាស់ជីវិតគ្រប់គ្នា ។ ដូច្នេះ ទើបជាការចាំបាច់ត្រូវប្រមូលរូបរួមល័ខគោលនៃទស្សនវិជ្ជានានា ដែលមានសេចក្ដីទាក់ទងនឹងជីវិតមកសិក្សាខ្លះដើម្បីជាជំនួយនៃគំនិតបញ្ញា ជាការសិក្សាមានផលល្អដល់មនោសញ្ចេតនា របស់មនុស្សយើងជាច្រើន, ព្រោះរឿងជីវិតនេះ ជាទស្សនវិជ្ជាមួយធំបំផុតដែលអ្នកប្រាជ្ញទាំងឡាយ ព្យាយាមស្រាវជ្រាវមកជាយូរណាស់ហើយ ។

ខ្ញុំសូមស្រង់យកយោបល់អ្នកប្រាជ្ញខ្លះជូនលោកអានសៀវភៅនេះទៅខាងមុខ ។ ការជូនយោបល់លោកអ្នកប្រាជ្ញក្នុងទីនេះមិនមែនសព្វគ្រប់ទេគឺគ្រាន់តែបានមួយភាគតូចពីក្នុងភាគធំៗ រាប់រយភាគនុ៎ះឯង ព្រោះជីវិតជារឿងពិបាកចូលចិត្ត, អ្នកដែលអាចចូលចិត្តជីវិតបាន ត្រូវជាអ្នកដែលបានឆ្លងកាត់ការងាររបស់ជីវិតច្រើនលើកច្រើនគ្រា, ធ្លាប់គប់ប្រសព្វគ្រោះកាចជា ឬ បានសិក្សាអំពីព្រឹត្តិការណ៍ក្នុងជីវិតរបស់មនុស្សទាំងឡាយយ៉ាងជិតដិត ទើបយល់ច្បាស់នូវចំណោទជីវិតបន្តិចម្តងៗ តាមលំដាប់ ។ យុវជននៅក្នុងបឋមវ័យច្រើនគិតថាខ្លួនមានសេចក្តីចេះដឹងក្នុងរឿងជីវិតល្មមហើយ, ហេតុការណ៍ដែលធ្លាប់កើតមានមកត្រឹមតែបន្តិចបន្តួចក៏ប្រកាន់ថាជារឿងធំចូលចិត្តថាមានសេចក្តីដឹងល្អិតល្អន់ហើយ, ដូច្នេះទើបគេកាត់ចិត្តងាយៗ ក្នុងការដែលគេត្រូវសម្រេច, តែវេលាវ័យក្មេងកន្លងហួសទៅ វ័យចាស់ចូលមកដល់គឺកាន់តែចាស់

ច្រើន ក៏កាន់តែស្គាល់ច្បាស់នូវរឿងរបស់ជីវិតតិចចុះមកគ្រប់ៗពេល ។

លក្ខគោលឯណាដែលគេបានរៀបចំឡើង នៅខាងក្រោមគំនិតដែលគេបានត្រិះរិះយ៉ាងជ្រៅជ្រះ, បានឆ្លងកាត់កិច្ចការរបស់ជីវិតយ៉ាងច្រើន លក្ខគោលនោះ រមែងជាលក្ខគោលមានសេចក្ដីត្រឹមត្រូវ ។ វិជ្ជាការដែលមានសេចក្ដីទាក់ទងនឹងទស្សនវិជ្ជានៃរឿងជីវិត មិនសូវមានការផ្លាស់ប្ដូរតាមកាល តាមសម័យ ដូចវិជ្ជាការរឿងដទៃៗ, ការសិក្សាអំពីរឿងជីវិតមានការចាំបាច់ ត្រូវប្រមូលរួបរួមគំនិតចាស់របស់មនុស្សជាន់ដើម ជាពិសេសគំនិតរបស់ជនដែលមានអាយុវែងធ្លាប់បានជួបប្រទះហេតុការណ៍ក្នុងលោកច្រើន នេះចាត់ជាការសិក្សាល្អបំផុត ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់យល់ឃើញតាមលក្ខគោលទី ១ គឺថាក្នុងជីវិតនេះមិនមានអ្វីល្អសោះឡើយ វត្ថុធាតុរាល់យ៉ាងមាន

សេចក្ដីទុក្ខនៅប្រចាំ **“ជាតិបិ ទុក្ខា ជរាបិ ទុក្ខា មរណម្បិ ទុក្ខំ”** សេចក្ដីកើតក៏ជាទុក្ខ សេចក្ដីធំធាត់និងសេចក្ដីចាស់ទ្រុឌទ្រោមចុះទៅក៏ជាទុក្ខ, សេចក្ដីស្លាប់ក៏ជាទុក្ខ, មានសភាពក្រៅអំពីនេះជាច្រើនទៀតក៏សុទ្ធតែជាទុក្ខដូចៗ គ្នា ។ សាវ័កព្រះសម្មាសម្ពុទ្ធកុងវេលាជួបគ្នាម្ដងៗពាក្យប្រាស្រ័យសាកសួរដែលគេធ្លាប់និយាយថា “សួស្ដី” លោកត្រឡប់ជាពោលពាក្យថា “ខមនិយំ” ប្រែថា “ល្មមអត់ធន់បានឬ?” ដោយសេចក្ដីថាជីវិតនេះជាទុក្ខ ។

ពាក្យថា “វ័យ” ដែលគេសម្គាល់ដល់សេចក្ដីចម្រើនដែលហៅថាចម្រើនដោយវ័យ ឬវ័យវុឌ្ឍ, ន័យរបស់ពាក្យនេះពិតៗ ប្រែថា “សូន្យ” ព្រោះគតិខាងព្រះពុទ្ធសាសនានោះមានការសម្គាល់នូវសេចក្ដីធាត់ធំឡើង ថាជាជំហានលូកទៅកាន់សេចក្ដីស្លាប់ ។ កុមារមានអាយុមួយថ្ងៃក៏ខិតចូលទៅជិតសេចក្ដីស្លាប់បានមួយថ្ងៃ មានអាយុដល់មួយខួបក៏ខិត

ចូលទៅជិតសេចក្តីស្លាប់បានមួយឆ្នាំ ។ សេចក្តីធំធាត់របស់ក្មេងដែលយើងមើលឃើញថាជាសេចក្តីចម្រើន ឬហៅថាចម្រើនវ័យ, ខាងព្រះពុទ្ធសាសនាមើលឃើញថាជាសេចក្តីសាបសូន្យ "**ខយវយធម្មា សង្ខារា**" "សង្ខារទាំងឡាយមានសេចក្តីអស់ទៅសូន្យទៅជាធម្មតា" ដូចជាវិទ្យាសាស្ត្រមិនកាន់យកនូវសេចក្តីត្រជាក់ជាប្រមាណ កាន់យកតែសេចក្តីក្តៅជាប្រមាណនោះឯង ។

ការពិតគំនិតយ៉ាងនេះ, ក៏មិនមែនមានចំពោះតែក្នុងព្រះពុទ្ធសាសនា, អ្នកប្រាជ្ញខាងបារាំងខ្លះ ដែលមិនធ្លាប់ចេះដឹងខាងព្រះពុទ្ធសាសនាក៏មានគំនិតត្រូវគ្នាដូច្នេះដែរ ។ វ៉ុលតែរ (Voltaire) អ្នកប្រាជ្ញបារាំងបានសរសេរថា : (la vie est une partie qu'il faut toujours perder.) ប្រែថា ជីវិតគឺជាល្បែងភ្នាល់មួយ បើប្រព្រឹត្តក៏ត្រូវសាបសូន្យ" អ្នកប្រាជ្ញបារាំងម្នាក់ទៀតឈ្មោះ ដឺឡាវីញ (De la Vigne)

សរសេរថា : "Chauque pas daris la vie est un pas Vers la mort" ប្រែថា "ការឈានទៅពល់តែជំហាន នៃជីវិតនោះ ជាការឈានទៅកាន់សេចក្ដីស្លាប់" ។ អាលេកហ្សង់ដ៏ ឌុយម៉ាស (Alexandre Dumas) អ្នកនិពន្ធជាតិបារាំងសរសេរថា : "Il y a des moments ou la vie ne-merite pas qu'oun se donne la peine de la sauver" ប្រែថា មានពេលខ្លះដែលជីវិតមិនមានគុណតម្លៃ ទុកណាជាយើងខំប្រឹងខ្នះខ្នែង ដើម្បីស្ងួនរក្សាក៏ដោយ" តាមយោបល់របស់អ្នកប្រាជ្ញនេះស្ដែងថា ជីវិតជារបស់មានគុណដូចគ្នា, តែក៏មានពេលខ្លះឬករណីខ្លះដែលជីវិតមិនមានគុណតម្លៃអ្វីសោះ មិនមានការចាំបាច់ដែលមនុស្សយើងនឹងត្រូវអត់ធន់ទទួលសេចក្ដីព្រួយលំបាកដើម្បីស្ងួនគ្រងនូវជីវិតនោះ, អ្នកប្រាជ្ញនេះនៅក្នុងពួកបុគ្គល មើលឃើញជីវិតថាជាទុក្ខច្រើនជាងសុខ ។ ប៉ាសកាល (Pascal) អ្នកប្រាជ្ញបារាំងបាន

សរសេរថា : "Etre nous et le ciel, l'enfer et le neant il y a done que la vie qui est la chose du monde le plus fragile" ប្រែថា "ជីវិតជាធម្មជាតទន់ខ្សោយបំផុតនៅក្នុងរវាងសួគ៌នរកនិងសេចក្ដីសោះសូន្យ" តាមគំនិតរបស់អ្នកប្រាជ្ញនេះ ជីវិតមិនមានអ្វីដែលនាំឲ្យរីករាយ, ជារបស់ដែលបែកធ្លាយងាយ, សោះសូន្យងាយ នៅក្នុងវត្ថុធាតុទាំងឡាយដែលមានអំណាចធំលើសលុប គឺ សួគ៌ នរក និងសេចក្ដីសូន្យបង់, ដូច្នេះ ជីវិតទើបទៅជារកសេចក្ដីមាំមួនគង់ធន់ប្រកបដោយខ្លឹមសារជាស្ថាពរគ្មានសោះឡើយ ។

វ៉ុលតែរ (Voltaire) អ្នកនិពន្ធបារាំងបានសរសេរទៀតថា :

"Quand on a tout perdu,
Quand on n'a plus d'espoir,
La vie est un opprodre,
Et la morl un devoir,"

ប្រែថា "កាលណាសភាពគ្រប់យ៉ាងបានបាត់បង់ទៅ

កាលណាមិនមានសេចក្ដីសង្ឃឹមណាមួយសល់នៅ, កាលនោះជីវិតក៏ជារបស់មិនមានតម្លៃ, ឯសេចក្ដីស្លាប់ក៏ក្លាយមកជានាទី" ការសិតរបស់រ៉ូលតែរក្នុងចំណុចនេះមានអ្នកមិនយល់ឃើញផងជាច្រើន ព្រោះជាពាក្យប្រដៅឲ្យថយក្រោយ អស់មានះចចេស, តែរ៉ូលតែរនៅមានពាក្យដទៃៗ ទៀតថា :

"On a toujours espéré vainement de jouir de la vie, et a la fin, tout ce qu'on peut faire, c'est de la aupporter." ប្រែថា មនុស្សយើងសង្ឃឹមជានិច្ចថា នឹងបានទទួលសេចក្ដីរីករាយ សុខស្រួលក្នុងជីវិត តែក៏ខុសសង្ឃឹមជានិច្ចដូចគ្នា ព្រោះជំនួសដែលជីវិតនឹងឲ្យសេចក្ដីរីករាយជាសុខ ជីវិតត្រឡប់ឲ្យសេចក្ដីលំបាក ដល់មនុស្សក្នុងការដែលត្រូវថែទាំរក្សា" ។ ចំណុចនេះមានសេចក្ដីពិតជាច្រើនព្រោះសេចក្ដីលំបាកធំៗ របស់មនុស្សនោះ នៅក្នុងការដែលត្រូវធ្វើសេចក្ដីព្យាយាម ទំនុកបម្រុងជីវិត ជំនួសដែលជីវិតនឹងឲ្យ

សេចក្តីសុខក្រេមក្សាន្តជីវិតនោះឯង ត្រឡប់ជាឲ្យសេចក្តីលំបាកទៅវិញ ។ គតិរបស់វ៉ូលតែរនេះ ត្រូវនឹងគតិខាងព្រះពុទ្ធសាសនា ដែលឃើញថាជីវិតមិនមានអ្វីក្រៅអំពីសេចក្តីទុក្ខលំបាកប៉ុណ្ណោះ ។ វ៉ូលតែរសរសេរមួយខទៀតថា :

"La fin de la vie est triste, le milieu n'en vaut rien et le commencement est ridicule. ប្រែថា "ជីវិតនោះក្នុងឃ្នាទីបំផុតជារឿងសៅសោក, ត្រង់ឃ្នាកណ្តាលក៏មិនមានតម្លៃអ្វី, ក្នុងឃ្នាដើមរើម ក៏គួរអស់សំណើច" ។

សេចក្តីនេះ, ជាគ្រឿងស្តែងឲ្យឃើញថា គំនិតរបស់វ៉ូលតែរ ក្នុងរឿងជីវិតនោះជាគំនិតពោរពេញទៅដោយសេចក្តីផងឹត, តែក៏មានសេចក្តីពិតជាច្រើន, មូលហេតុនៃសេចក្តីកើតរបស់ជីវិតមកអំពីកាមារម្មណ៍ ជាអំពើដែលអ្នកប្រាជ្ញនេះមើលឃើញថាជារបស់អស់សំណើច, វេលាជីវិតចម្រើនតមកក៏មិនឃើញមានប្រយោជន៍អ្វី លុះស្លាប់បាត់បង់ទៅ ក៏ត្រ-

ឡប់ទៅជារឿងសៅសោកខូចចិត្ត, រួមសេចក្តីតាមយោបល់របស់រ៉ូលតែរ ក្នុង ១ នេះក៏គឺជាជីវិតមានសេចក្តីមិនល្អគ្រប់កាលទាំងអស់ ។

សាំងប៊ែរណារដ៍ (Saing Bernard) បានសរសេរជាភាសាបារាំង ហើយដែលគេបានប្រែជាភាសាអង់គ្លេសថា : "It is misery to be born, a pain to live, a trouble to die." ប្រែថា "ជីវិតវេលាកើតក៏លំបាក, វេលារស់ក៏លំបាក, វេលាស្លាប់ក៏លំបាក" សេចក្តីយល់ឃើញនេះ ស្របជាមួយនឹងមតិព្រះពុទ្ធសាសនា ដែលបានអាងមកហើយក្នុងខាងដើមថាសេចក្តីកើតក៏ជាទុក្ខ, សេចក្តីជំងាត់ចាស់ទ្រុឌទ្រោមចុះទៅក៏ជាទុក្ខ, សេចក្តីស្លាប់ក៏ជាទុក្ខ, ទុក្ខគ្រប់រឿងទាំងអស់ ពុំមានអ្វីល្អក្នុងជីវិតដល់បន្តិចបន្តួចឡើយ ។

អ្នកប្រាជ្ញបារាំង ឡាព្រុយែរ (La Bruyére) ម្នាក់ទៀតសរសេរថា : "Si la vie est mésirable, elle est

Pénible a supporter, si elle est heureuse, i lest hor-rible de la perdre" ប្រែថា "បើជីវិតជាសេចក្ដីលំបាកលំបិន ក៏លំបាកនឹងស្នូនគ្រងរក្សា, បើជីវិតជាសុខក្សេមក្សាន្តក៏មុខគួរឲ្យស្រៀវស្រុតស្ដាយស្រណោះ ក្នុងពេលដែលខូចបង់ទៅ" ។

យោបល់នេះស្ដែងថា ជីវិតនោះមិនមានអ្វីល្អឡើយ ព្រោះថាបើជីវិតជាសេចក្ដីលំបាកលំបិន ក៏នាំឲ្យមានសេចក្ដីព្រួយលំបាកដល់មនុស្សយើងដែលត្រូវរក្សាស្នូនគ្រង, បើជីវិតប្រកបដោយសេចក្ដីសុខ ក៏នាំឲ្យកើតសេចក្ដីស្ដាយស្រណោះក្នុងជីវិតនឹងនាំឲ្យមានសេចក្ដីទុក្ខក្ដៅក្រហាយ ស្រៀវស្រុតក្នុងពេលដែលជីវិតនឹងត្រូវស្លាប់បាត់បង់ទៅ ។

អ្នកស្រីដឺម៉ាំងតឺណង់ត៍ (De maintenant) ជាតិបារាំងសរសេរថា : "C'est étre bien avancé dans la science dela vie que de savoir souffrir." ប្រែថា សេច-

ក្តីបេះដឹងខ្ពង់ខ្ពស់ក្នុងវិទ្យាការរបស់ជីវិតនោះគឺ ការបេះធន់ទ្រាំសេចក្តីទុក្ខលំបាក ។ នេះជាគតិមួយទៀតដែលប្រកាន់ថាជីវិតនោះជាសេចក្តីទុក្ខលំបាក, មនុស្សយើងត្រូវបេះអត់ធន់រឿយៗ ទៅ, មិនមានវិជ្ជាចំណេះឯណាសំខាន់ ជាងការបេះអត់ធន់សេចក្តីទុក្ខលំបាកក្នុងជីវិតគឺដឹងថា ធ្វើដូចម្តេចទើបអាចអត់ធន់ សេចក្តីទុក្ខលំបាកក្នុងជីវិតបាន ។

អ្នកប្រាជ្ញបារាំងឈ្មោះ ម៉ាស៊ីយ៉ុង (Massillon) សរសេរថា: “Toute la vie des grands n’est qu’une précaution penible contre l’ennui. ប្រែថា “អស់មួយជីវិតនៃជនអ្នកធំមានសភាពតែមួយ គឺសេចក្តីលំបាកចិត្តកើតមកអំពីសេចក្តីកង្វល់ហួងហែង” សេចក្តីថា អ្នកធំគ្រប់រូបនៅក្នុងឋានៈខ្ពង់ខ្ពស់ ឬ ប្រកបទៅដោយវត្ថុសម្បទាបរិបូណ៌ ក៏មិនមានពេលបានសេចក្តីសុខ មានតែសេចក្តីទុក្ខលំបាកកើតមកអំពីការហួងហែងរក្សាយសស័ក្តិទ្រព្យសម្បត្តិ, គ្រួសារនឹងជននៅ

ក្រោមបង្គាប់ ជាបុគ្គលមានសេចក្តីទុក្ខព្រួយច្រើន ជាងអ្នកដែលមិនមានអ្វីនឹងហួងហែងរក្សានោះទៅទៀត ។

អ្នកប្រាជ្ញបារាំងឈ្មោះ ហ្សង់-ហ្សាក់រូស្សូ -(Jean-Jeacques-Rousseau សរសេរថា : "Quand une foil l'ennui de vivre l'emporte aur l'horreur de mourir, alors la vie est évidenment un grand mal" ប្រែថា "កាលណាសេចក្តីកង្វល់ហួងហែងក្នុងជីវិតមានច្រើន, ដល់ទៅដឹកនាំឲ្យកើតស្រៀវខ្លាចសេចក្តីស្លាប់, កាលនោះជីវិតក៏ទៅជាអំពូអអាក្រក់" ។

គំនិតរបស់អ្នកប្រាជ្ញនានា ដែលមិនធ្លាប់ចេះដឹងព្រះពុទ្ធសាសនា ក៏មានសេចក្តីគិតឃើញត្រូវនឹងព្រះពុទ្ធសាសនាជាច្រើន គឺឃើញថាជីវិតយើងនេះជាទុក្ខមិនមានខ្លឹមសារអ្វីឡើយ កើតមកក៏ជាទុក្ខ, វេលារស់នៅក៏ជាទុក្ខ វេលាស្លាប់ក៏ជា-ទុក្ខ ។

តែអ្នកដែលឃើញថា ជីវិតជារបស់ល្អក៏មានខ្លះដែរ ដូចជាអ្នកប្រាជ្ញបារាំងឈ្មោះ ឡារ៉ូស ហ្វ៊ូកូដ៍ (La Rochefou-could) បានសរសេរថា : “La vie est bonne en soi et le plus grand hien du monde, mais le plus mal ménagée” ប្រែថា ជីវិតជារបស់ល្អ, ជារបស់ល្អបំផុតនៅក្នុងលោក, តែកម្រនឹងធ្វើឲ្យប្រព្រឹត្តទៅបានតាមបំណង ។

នេះជាគំនិតមួយថ្មី ផ្ទុយអំពីគំនិតអ្នកដទៃៗ គឺថាសេចក្ដីទុក្ខលំបាកមិនបាននៅក្នុងជីវិតទេ, តែនៅក្នុងការរៀបចំនៃជីវិត, ជីវិតនោះជារបស់ល្អហើយត្រូវជារបស់ល្អបំផុតនៅក្នុងលោកនេះឯង ។

កវីម្នាក់ឈ្មោះ មីលឡេយ៍ (Saint Vincent Millay) សរសេរថា :

“My candle burns at both ends.
It will not last the night.
But, ah, my focs end. – Oh, my friends,
It gives a lovely light.

ប្រែថា ជីវិតដូចជាទៀន ដែលត្រូវគេអុជភ្លើងទាំងសងខាង គង់នឹងមិនឆេះនៅបានអស់យប់ទាំងមូល, តែពន្លឺរបស់ទៀននោះក៏ជាពន្លឺដែលគួរឲ្យ មានសេចក្ដីជ្រះថ្លារីករាយ ។

អត្ថបទពាក្យកាព្យនេះ ជ្រៅទៅដោយន័យ គឺថាជីវិតរបស់មនុស្សយើងនោះ ត្រូវភ្លើងឆេះទាំងសងខាង, សេចក្ដីចាស់ជរានៅម្ខាង, សេចក្ដីស្លាប់នៅម្ខាង, ជីវិតគង់មិនអាចរស់នៅយូរប៉ុន្មានឡើយ, តែជីវិតកំពុងរស់នៅនោះជារបស់ដែលគួរឲ្យត្រេកអររីករាយ គំនិតរបស់អ្នកប្រាជ្ញនេះនៅក្នុងពួកអ្នកប្រាជ្ញដែលយល់ថាជីវិតជារបស់ល្អ ។

ពួកអ្នកប្រាជ្ញ ដែលឃើញថាជីវិតមិនមានគោលដៅ ឬមិនមានន័យ ។ ចំពោះរឿងនេះ ហេក្រ-ស្ពៀរ (Shakespeare) អ្នកប្រាជ្ញអង់គ្លេសដែលជាបុរសចូលចិត្តប្រៀបលោកដោយរោងល្ខោន, ប្រៀបជីវិតរបស់មនុស្សដូចតួល្ខោន

មិនមានសេចក្ដីពិត, គ្រាន់តែលោតកញ្ឆេងទៅតាមបទភ្លេង ហើយបិទឆាកចប់រឿង មានសេចក្ដីស្លាប់ជាអវសាន ។

អ្នកប្រាជ្ញនេះបាននិយាយថា : "Life's but a walking shadow" ប្រែថា "ជីវិតនោះមិនមែនអ្វីដទៃឡើយ គឺជាស្រមោលដើរបាននោះឯង" ។

យោបល់របស់ ហ្សេកស្ពៀរ ចំពោះជីវិតនោះច្រើនតែស្ដែងចេញថា ជីវិតមិនមានខ្លឹមសារ, មិនមានសេចក្ដីអាក្រក់ល្អ មិនមានអ្វីជារបស់ពិតប្រាកដ ។ ហ្សង់-ហ្សាក់-រ៉ូស្សូ (Jean-Jacques-Rousseau) ជាបុគ្គលចូលចិត្តគិតល្អិតប្រកបដោយហេតុផល, ពេញចិត្តក្នុងមជ្ឈិមប្បដិបទាបាននិយាយថា : "La vie n'est rien pas elle meme: son prix depend de son emploi" ប្រែថា ជីវិតក្នុងតួរបស់វានោះមិនមានអ្វីឡើយ, តម្លៃរបស់ជីវិតនឹងមានបានក៏ស្រេចតែការប្រើប្រាស់នៃជីវិតនោះ ។

នេះជាគំនិតរបស់អ្នកដើរផ្លូវកណ្តាល គឺមិនប្រកាន់ថា ជីវិតជារបស់ល្អ ឬ អាក្រក់នៅក្នុងតួរបស់វា សេចក្តីថ្លៃថ្នូរ ឬ ថោកទាបរបស់ជីវិតនៅលើម្ចាស់របស់ជីវិត ។ គតិនៃបុគ្គល ពួកនេះ បើយើងលើកមកពិចារណាមើល, យើងនឹងបាន ជួបនឹងគតិជាច្រើនទៀតដែលមានលំនាំដូចគ្នានេះ ដែលនាំឲ្យ កើតជំនឿធ្វើឲ្យចិត្តយើងជានាយចៅហ្វាយរបស់ជីវិត មិន បណ្តោយឲ្យជីវិតជានាយចៅហ្វាយរបស់យើង ។ ពាក្យរបស់ រ៉ូស្សូស្រ្សបនឹងពាក្យទស្សនវិទូនានាដែលថាអនាគតនោះយើង សាងដោយខ្លួនឯង អាក្រក់ល្អនៅលើខ្លួនយើង, ជីវិតគ្រាន់ តែជាវត្ថុធាតុ ដែលធម្មជាតិសាងឲ្យ នឹងប្រើទៅក្នុងផ្លូវអាក្រក់ ឬផ្លូវល្អស្រេចលើខ្លួនឯង ។

វិចទ័រហ៊ុយគ្រោ (Victor Hugo) អ្នកនិពន្ធបារាំងបាន និយាយថា : “La vie est un mets qui n’agree que par la sauce” ប្រែថា “ជីវិតគ្រាន់តែជាអាហារមួយ

ប៉ុណ្ណោះ ដែលនឹងមានរសជាតិយ៉ាងណាៗ ស្រេចតែទឹក "សូស"[១] ដែលគេផ្សំជាមួយ ។ យោបល់របស់ វិចទ័រ-ហ៊ុយគោ្គ ស្របគ្នានឹងយោបល់របស់ រ៉ូស្សូ ត្រង់ថាជីវិតនោះ មិនមានសេចក្ដីថ្លៃថ្នូរ ថោកទាបនៅក្នុងតួរបស់វា ។

គំនិតអ្នកប្រាជ្ញទាំងអស់នេះបានស្របគ្នាត្រង់ថា ជីវិតជារបស់កណ្ដាលៗ មិនមានអាក្រក់ល្អ, បើយើងប្រើជីវិតទៅក្នុងផ្លូវមិនល្អជីវិតក៏មិនល្អ, បើយើងប្រើជីវិតទៅក្នុងផ្លូវល្អជីវិតក៏ល្អ, ជីវិតយើងនៅក្នុងដៃរបស់យើងនឹងញាក់ពង្រឹលឲ្យទៅជាយ៉ាងណាក៏បាន ។

សាស្ដាចារ្យនៃលទ្ធិសាសនា ឬ ទស្សនវិទូនានាក៏មានមតិស្របគ្នាថា ការញ៉ាក់ពង្រឹលជីវិត ឬ ការសាងអនាគតនោះជាការលំបាកពន់ពេកណាស់ ។ ពាក្យប្រដៅក្នុងគ្រីស្ដសាសនាថា : "ជីវិតជាទ្វារធំទូលាយ, តែមានប្រកបផ្អៀត

១- (ទឹកសូស) - គឺទឹកមួយយ៉ាងដែលគេផ្សំគ្រឿងសម្លឲ្យមានរសផ្សេងៗ

ដោសេចក្តីថា ទ្វារដែលមនុស្សយើងនឹងដើរចូលទៅកាន់ជី-វិតនោះ ជាទ្វារធំទូលាយ, តែកាលណាចូលទៅផុតទ្វារនោះហើយ នឹងបានជួបប្រទះនូវផ្លូវចង្អៀត ធ្វើឲ្យដំណើរមានសេចក្តីលំបាកក្រៃលែង ។

អ្នកនិពន្ធម្នាក់ឈ្មោះ រីគ្លោលត៍ (H. Rigault) សរសេរថា : “La vie est un ouvrage d’art qu’il faut-savoir faconner d’une main habile” ប្រែថា ជីវិតជាសិល្បៈវត្ថុមួយ ដែលគេសាងដោយដៃយ៉ាងប៉ិនប្រសប់" វ៉ូលតែរ (Voltaire) ដែលមើលឃើញជីវិតថាជារបស់អាក្រក់ដូចពោលមកហើយខាងដើមបាននិយាយថា : “Le plus grand bien auquel on puisse pretender est de mener une vie conforme a son etat et a son gout.” ប្រែថា "សេចក្តីល្អបំផុតដែលមនុស្សអាចនឹងអួតអាងនោះ គឺការបេះធ្វើជីវិតឲ្យសមស្ទួនជាមួយឋានៈ និងរសនិយមរបស់ខ្លួន" ។ ពាក្យវ៉ូលតែរ ត្រូវនឹងពាក្យ រីគ្លោលត៍ដែលថាការ

រៀបចំជីវិតនោះ ជាសិល្បៈមួយត្រូវស្គាល់ និងត្រូវចូលចិត្តកម្មវិធី ។ រីឯតែរ ឃើញថាកម្មវិធីដែលល្អបំផុតនោះ គឺចេះរៀបចំជីវិតឲ្យសមស្ងួនទីឋាន: ឲ្យប្រព្រឹត្តទៅតាមសេនិយមរបស់ខ្លួន បើយើងត្រូវការឲ្យមានជីវិតរស់នៅយ៉ាងណា, ឲ្យយើងប្រព្រឹត្តនូវកិច្ចការសមគួរ តាមសេចក្ដីត្រូវការយ៉ាងនោះ ។

អ្នកប្រាជ្ញអង់គ្លេសម្នាក់ឈ្មោះ បេលី (Bailey) បានសរសេរថា : It matters not how long we live, but how. ប្រែថា "យើងរស់នៅយឺនយូរ មិនជាការសំខាន់ទេ តែសេចក្ដីសំខាន់នៅត្រង់យើងនឹងរស់នៅយ៉ាងណា" បញ្ហារឿងប៉ុណ្ណេះប៉ុណ្ណោះ មិនសំខាន់ទេ មនុស្សយើងអាចនឹងមានអាយុតិចក៏មាន, អាយុច្រើនក៏មាន, ជនដែលស្លាប់ក្នុងវ័យក្មេង តែគេបានធ្វើជីវិតរបស់គេឲ្យល្អ ឲ្យជាជីវិតមានប្រយោជន៍ ក៏ល្អជាងជនដែលមានអាយុយឺនយូរជាង

១០០ ឆ្នាំ តែមិនបានធ្វើប្រយោជន៍អ្វីឲ្យជីវិតរបស់ខ្លួន ។

ទស្សនវិជ្ជា រឿងជីវិតរេរទៅក្នុងផ្លូវថា ឲ្យយើងមានសេចក្ដីមានៈ ព្យាយាមសាងជីវិតរបស់យើងឲ្យល្អ ។ សេចក្ដីមានៈ ព្យាយាមនេះជាល័ខគោលសំខាន់ក្នុងទស្សនវិជ្ជារបស់ជីវិត, យើងតែងបានឮគេនិយាយរឿយៗ ថា ដរាបណាជីវិតរស់នៅ ដរាបនោះត្រូវធ្វើសេចក្ដីព្យាយាមកុំឈប់, ដរាបណាយើងនៅដកដង្ហើមបាន យើងមិនទាន់ស្លាប់, ដរាបនោះ យើងត្រូវធ្វើការតទៅ ។ ពាក្យនេះជាពាក្យរបស់ទស្សនវិទូ ហុលឡង់ម្នាក់ឈ្មោះ អ៊ីរ៉ាស្មុស (Erasmus) មានអ្នកប្រែជាភាសាអង់គ្លេសដូចខាងក្រោមនេះ ៖

“No one is to be despaires of as long as he breaths” ប្រែថា “កាលណាមនុស្សយើងមានដង្ហើមនៅ មិនគួរអស់សង្ឃឹមឡើយ” ។ ពាក្យរបស់អ្នកប្រាជ្ញនេះនាំឲ្យមនុស្សមានសម្បជញ្ញៈ គឺសេចក្ដីសង្ឃឹម, សេចក្ដីសង្ឃឹមជាហេតុ

ឲ្យមនុស្សមិនចង់ស្លាប់ ព្រោះគេចូលចិត្តថា អនាគតខាង មុខនឹងនាំមកនូវរបស់ល្អណាមួយ, មកឲ្យគេទៀត ។

ខាងព្រះពុទ្ធសាសនាប្រកាន់ថា ជីវិតជាទុក្ខ, ជីវិតមិន មានសេចក្ដីសុខ, មិនទៀងទាត់ឋិតថេរ, តែព្រះពុទ្ធសាស-នាក៏មិនយល់ព្រមជាមួយផងក្នុងការស្លាប់ខ្លួនឯង ហើយប្រ-កាន់ថា បុគ្គលសម្លាប់ខ្លួននោះជាបាបមួយយ៉ាងធ្ងន់ ។ ខាង គ្រឹស្ដសាសនាជឿថា ជីវិតមិនមែនរបស់ខ្លួន, តែជារបស់ ព្រះអាទិទេព, មនុស្សមិនមានសិទ្ធិនឹងទម្លាយជីវិតខ្លួនឯង ទេ ។ លទ្ធគោលទស្សនវិជ្ជាទូទៅ មានទ្រឹស្ដីផ្ទុយអំពីនោះ គឺប្រកាន់ថា ការសម្លាប់ខ្លួននោះ ជាសេចក្ដីល្ងង់ខ្លៅរបស់ មនុស្ស, ការរំលត់ជីវិតដោយព្យាយាមរបស់ខ្លួន ជាការ ស្ដែងឲ្យឃើញនូវចំណុចទន់ខ្សោយ គឺគ្មានសេចក្ដីមានះព្យា-យាម ដូចមានពាក្យទស្សនវិទូរបស់អ៊ីតាលី ម្នាក់ឈ្មោះ អាល់ហ្វិអេរី (Alfeiri) បានសរសេរហើយ មានអ្នកប្រែជា

ភាសាអង់គ្លេសថា : “The test of courage becomes rather to live than to die”. ប្រែថា “ការពិសោធនូវសេចក្ដីក្លាហាននោះ នៅត្រង់ការមានជីវិតរស់នៅ ច្រើនជាងការស្លាប់” ។ ដោយសេចក្ដីថា ជនក្លាហានពិតៗ ត្រូវនៅតស៊ូជាមួយនឹងសត្រូវ តស៊ូជាមួយហេតុការណ៍, តស៊ូជាមួយគ្រោះកាចទាំងឡាយ ដែលឈមមុខមករកខ្លួន ជនក្លាហានរមែងមិនរត់លួន, មានតែជនញ៉ាកប៉ុណ្ណោះទេ ដែលរត់លួនគេចសត្រូវ, គេចដល់ទៅជីវិតខ្លួនស្លាប់បង់ នេះគឺជាសេចក្ដីខ្លៅល្ងង់យ៉ាងធំបំផុត, ជាកំហុសយ៉ាងសម្បើម ព្រោះថា បើយើងសុខចិត្តលះបង់របស់គ្រប់យ៉ាង រហូតដល់ទៅជីវិតរបស់យើងក៏ព្រមលះបង់ដែរ ដូចម្ដេចទើបមិនប្រើការលះបង់នោះដើម្បីការតស៊ូ, ព្រោះថាសូម្បីការតស៊ូជាសេចក្ដីលំបាកយ៉ាងណាក៏ដោយ ក៏គង់មិនលំបាកវេទនាជាងសេចក្ដីស្លាប់ទេ ។ យើងគួរស្លាប់ដោយការតស៊ូ ដែលជាគុណសម្បត្តិ

ល្អជាងស្លាប់ដោយការញ៉ាំមចាញ់, ការសម្លាប់ខ្លួនឯងនោះ ជាការញ៉ាំមចាញ់ សឹងចុះទៅក្នុងតម្រាថាជាមនុស្សញ៉ាំកផង, លូង់ផង ។

សេចក្តីពិត, ការតស៊ូដើម្បីជីវិតនោះ ធម្មជាតិបានឲ្យជំនួយជាច្រើនប្រសិនបើយើងមានការចាំបាច់ត្រូវតស៊ូ ទោះជាការតស៊ូជាមួយសត្រូវជាមួយហេតុការណ៍ ឬជាមួយជោគអាក្រក់ណាៗ ក៏ដោយ បើយើងកាត់ចិត្តតស៊ូដោយមិនរាថយក្រោយ ធម្មជាតិក៏ជួយបន្ថែមកម្លាំងឲ្យយើង ទាំងកម្លាំងចិត្ត កម្លាំងកាយ និងកម្លាំងគំនិត ។ ក្នុងខណៈដែលយើងដាក់ចិត្តតស៊ូនោះ យើងនឹងបានទទួលកម្លាំងបន្ថែមជាច្រើនជាងកម្លាំងដែលយើងធ្លាប់មានក្នុងពេលប្រក្រតី ។ កម្លាំងនេះហើយ ដែលនឹងនាំឲ្យធ្វើការបានសម្រេចដូចបំណង នៃជនអ្នកតស៊ូ ។

អ្នកប្រាជ្ញបារាំងម្នាក់ឈ្មោះ ហ្សាតូព្រីយ៉ង់ដ៍ (Chateau

Braind) បានសរសេរថា : “Les moments de crise produisent un redoublement de vie chez les homes ប្រែថា: “ក្នុងពេលកើតវិបត្តិ មនុស្សមានជីវិតទ្វេមួយជាពីរ” ។ ដោសេចក្ដីថាធម្មជាតិបានឲ្យកម្លាំងក្នុងជីវិតរបស់មនុស្សថ្មីឡើងទៀត ដើម្បីប្រយុទ្ធជាមួយនឹងការវិបត្តិនោះ ។

វិទ័រហ៊ុយគ្រោ (Victor Hugo) បានសរសេរទៀតថា : “ceux qui vient, ce sont ceux qui luttent” ប្រែថា “អ្នកដែលមានជីវិតរស់នៅបាន គឺអ្នកដែលតស៊ូ គតិនេះមានជាប់តមកថា ជីវិតគឺការតស៊ូ, អ្នករស់នៅបាន គឺអ្នកដែលរឹងប៉ឹងមាំមួនបំផុត, ចំណែកអ្នកដែលទន់ខ្សោយនោះ រមែងរលត់សូន្យទៅ បើយើងចង់រស់, យើងត្រូវតែតស៊ូ បើយើងមិនតស៊ូ, យើងក៏មានតែស្លាប់បាត់ទៅប៉ុណ្ណោះ ។

រឿងតស៊ូ, ជារឿងចាំបាច់ដែលយើងត្រូវរៀនចាកជីវិតរបស់ជនដទៃថា តើគេតស៊ូយ៉ាងណា ឬរៀនចាកជីវិត

របស់យើងដែលធ្លាប់បានធ្វើការតស៊ូមកហើយថា យ៉ាងណាខុស, យ៉ាងណាត្រូវ, អ្វីជាផ្លូវនាំឲ្យចាញ់, អ្វីជាផ្លូវនាំឲ្យមានជ័យជម្នះ ។ លទ្ធិគោលទស្សនវិជ្ជា ដែលបានរកឃើញមានសេចក្តីស្របគ្នាថា ការតស៊ូក្នុងជីវិតនោះ ត្រូវធ្វើដោយសេចក្តីឱហាតខ្នះខ្នែង, ត្រូវតស៊ូដោយការងារ, ត្រូវកុំបណ្តោយឲ្យកាលវេលាកន្លងហួសទៅទទេៗ គ្មានផលប្រយោជន៍, ទស្សនវិទូច្រើនគ្នាតែងរំលឹកដាស់តឿនដូច្នេះ ។ (វ៉ូលតែរ) ដដែលសរសេរថា : “Le ravail est la-vie des homes.” ប្រែថា “ការងារជាជីវិតរបស់មនុស្ស” ដោសេចក្តីថា មនុស្សដែលមិនបានធ្វើការ ក៏ដូចជាមិនមានជីវិត, បើយើងកាន់យកគតិនេះ ឈ្មោះថាយើងចាប់ផ្តើមតស៊ូយ៉ាងត្រឹមត្រូវ, តែមានបញ្ហាតទៅទៀតថា យើងនឹងធ្វើការយ៉ាងណា ទើបទៅជាការតស៊ូ នាំមកនូវជ័យជម្នះដល់ខ្លួនយើង ។ ទោះជាយ៉ាងណាក៏ដោយ ការសង្ឃឹមយកជ័យ

ជម្នះដោយមិនធ្វើការនោះ ពុំបានសម្រេចដូចបំណងឡើយ, តែជួនកាលអំពើការងារនោះ អាចមិនប្រសិទ្ធិជ័យជម្នះឲ្យយើងក៏មានដែរ ព្រោះមានកម្មវិធីច្រើនយ៉ាងទៀតទាក់ទងជាមួយការតស៊ូ ប៉ុន្តែបើយើងមិនធ្វើអ្វីសោះ ការស៊ូរបស់យើងក៏មិនអាចនឹងមានបាន ។

អ្នកប្រាជ្ញអាមេរិកកាំងម្នាក់ឈ្មោះ ហ្វ្រង់គ្លិន (Frank lin) បានសរសេរថា : Dost thou live life Then do not squander time, for that is the stuff life is made of” ប្រែថា “អ្នកស្រឡាញ់ជីវិតរបស់អ្នក ឬ? បើស្រឡាញ់ កុំបណ្តោយឲ្យវេលាបាត់បង់ទៅទទេៗ ព្រោះវេលាជារបស់ផ្សំធ្វើឲ្យមានជីវិត” ។

ពាក្យថា កុំបណ្តោយឲ្យវេលាបាត់បង់ទៅទទេៗ នោះខាងព្រះពុទ្ធសាសនាក៏មាននិយាយជាអាទិ៍ថា

**“អតិ បត្តិ វយោ ខណោ តថេវ”** វ័យ

រមែងកន្លងផុតទៅដូចយ៉ាងខណៈ" សេចក្តីថា កាលណា វេលាកន្លងទៅ វ័យរបស់យើង ក៏កន្លងទៅជាមួយផងរាល់ៗ ថ្ងៃ, រាល់ៗ ម៉ោង, ជីវិតរបស់យើងឈានចូលទៅជិតសេចក្តីស្លាប់រឿយៗ ។ ខណៈ ឬវេលា ដែលកន្លងហួសទៅហើយ យើងមិនអាចហៅឲ្យត្រឡប់មកវិញបានទេ, វ័យរបស់យើងដែលចូលផុតទៅហើយក៏មិនអាចនឹងហៅឲ្យត្រឡប់មកទៀតបានដូចគ្នា ។

"**កាលោ ឃសតិ ភូតានិ សព្វានេវ សហត្តនា**" កាលវេលារមែងទំពាស៊ីសព្វសត្វ ព្រមជាមួយនឹងខ្លួនរបស់វា" យើងត្រូវសាងផលប្រយោជន៍ល្អទុកសម្រាប់ខ្លួន កុំឲ្យវេលាស៊ីប្រយោជន៍របស់យើងទៅទទេៗ ។

"**ឥតិ វិស្សជ្ជកាម្មន្តេ អត្ថា អច្ចេន្តិ មាណវេ**" ប្រយោជន៍រមែងកន្លងហួសយុវជន អ្នកបោះបង់ការ សេចក្តីថា ជនដែលចូលចិត្តថា ខ្លួនមានវ័យនៅក្មេង,

ចូលចិត្តថា មានវេលានៅច្រើនទៀត, បណ្តោយឲ្យវេលាកន្លងទៅ, គុណប្រយោជន៍រមែងកន្លងទៅជាមួយផង ព្រោះវេលានោះឯងគឺជាតួគុណប្រយោជន៍ ។

ទស្សនវិទូជាតិអាល្លឺម៉ង់ម្នាក់ឈ្មោះ កូតេ (Goethe) បានសរសេរហើយមានអ្នកប្រែជាភាសាអង់គ្លេសថា : "A useless life is an early death." ប្រែថា "ជីវិតដែលមិនមានប្រយោជន៍ គឺជីវិតដែលស្លាប់មុនដល់វេលាស្លាប់" អ្នកប្រាជ្ញអង់គ្លេសម្នាក់ឈ្មោះ ស្វីហ្វត៍ (Swift) បានសរសេរថា : "May you live all the days of your life." ប្រែថា "សូមឲ្យអ្នកមានជីវិតរស់នៅមួយថ្ងៃ នៃជីវិតរបស់អ្នក" សេចក្តីថា គ្រប់វេលាដែលមានជីវិតរស់នៅនោះ សូមឲ្យយើងរស់នៅយ៉ាងមនុស្សដែលមានជីវិត គឺរស់នៅដោយប្រើវេលាឲ្យជាប្រយោជន៍ មិនមែនរស់នៅយ៉ាងមនុស្សស្លាប់ គឺមានជីវិតរស់នៅដោយមិនមានប្រយោជន៍អ្វី ។

មានយោបល់នៃជនខ្លះថា វិធីរំលត់កិលេសទាំងឡាយនោះ គឺការរស់នៅជាមនុស្សធ្វើការ ព្រោះថាបើប្រើជីវិតទៅក្នុងការងារហើយ គំនិតថោកទាបអាក្រក់ ក៏មិនអាចកើតឡើងបាន ។

អ្នកប្រាជ្ញឈ្មោះវ៉ូវីណារគ្គ (Volvenarque) បានសរសេរថា : "Il n'y a que la vie laborieuse qui puisse amorTir les passion" ប្រែថា ជីវិតដែលធ្វើការប៉ុណ្ណោះដែលអាចនឹងសម្លាប់កិលេសទាំងឡាយឲ្យស្លាប់ទៅបាន" ។

ការតស៊ូជាដំបូងរបស់យើងគឺសេចក្តីឱហាតខ្នះខ្នែង មិនបណ្តោយឲ្យវេលាកន្លងទៅទទេៗ ។ បើយើងចង់មានជីវិតរស់នៅដោយសម្បូរសប្បាយ ហើយបណ្តោយឲ្យវេលាកន្លងទៅទទេៗ ដោយមិនធ្វើការអ្វី ការតស៊ូក្នុងជីវិតរបស់យើងក៏មិនមាន ។ ព្រោះតាមសេចក្តីពិត នៅក្នុងលោកនេះគេអាចពិសោធឃើញជាក់ច្បាស់ថា មានតែមនុស្សឱហាត

ខ្នះខ្នែង មនុស្សដែលពេញចិត្តធ្វើការងារប្រើវេលាឲ្យជាប្រ-យោជន៍ប៉ុណ្ណោះទេ ដែលអាចនឹងតស៊ូជាមួយជីវិតបាន ចំណែកជន ដែលមិនធ្វើការអ្វី រង់ចាំឲ្យលាភជោគបានមកឯងៗ ដូចមាននិយាយក្នុងរឿងព្រេង នឹងមានផ្លូវបានលាភជោគតែត្រឹមក្នុងរឿងព្រេងប៉ុណ្ណោះឯង, ឯក្នុងរឿងជីវិតពិតប្រាកដនោះ មិនអាចនឹងមានផ្លូវចេញទៅជួបលាភជោគបានឡើយ ។

យើងវិលមកមើលកាសិតក្នុងពុទ្ធសាសនាម្តង, ព្រះពុទ្ធបរមគ្រូទ្រង់ត្រាស់ដឹងនូវបញ្ហាជីវិត ហើយព្រះអង្គទ្រង់សំដែង ដូចមានជាអាទិ៍ថា :

"អប្បមាទោ អមតំ បទំ បមាទោ មច្ចុនោ បទំ អប្បមត្តា ន មិយ្យន្តិ យេ បមត្តា យថា មតា"

ប្រែថា "សេចក្តីមិនធ្វេសប្រហែស ជាផ្លូវនៃសេចក្តី

មិនស្លាប់, សេចក្តីធ្វេសប្រហែសជាផ្លូវនៃសេចក្តីស្លាប់, ជនដែលមិនមានសេចក្តីធ្វេសប្រហែសជាជនមិនស្លាប់, ជនដែលមានសេចក្តីធ្វេសប្រហែស ទុកណាជាមានជីវិតរស់នៅ ក៏ដូចជាស្លាប់ទៅហើយ” ។

**“យោ ច វស្សសតំ ជីវេ កុសីតោ ហីន-វីរិយោ ឯកាហំ ជីវិតំ សេយ្យោ វីរិយំ អារព្ភ-តោ ទឡ្ហំ”**

ប្រែថា ជនណាខ្ជិលច្រអូសមិនមានសេចក្តីព្យាយាមរស់នៅអស់មួយរយឆ្នាំ ការរស់នៅនៃជននោះ ពុំប្រសើរស្មើនឹងការរស់នៅត្រឹមតែមួយថ្ងៃ នៃជនដែលមានព្យាយាមមាំមួន” ពុទ្ធភាសិតនេះមានន័យថា អ្នករស់នៅមួយរយឆ្នាំតែពុំបានធ្វើការអ្វីឲ្យជាប្រយោជន៍ដល់ខ្លួន ដល់គ្រួសារ ដល់ប្រទេសជាតិរបស់ខ្លួន, ជាមនុស្សបណ្តោយខ្លួនឲ្យសេចក្តីខ្ជិលច្រអូសគ្របដណ្តប់, ជាជនមានជីវភាពទន់ខ្សោយ, ការ

រស់នៅដូច្នេះពុំប្រសើរសោះឡើយ ។

"យោ ច វស្សសតំ ជីវេ ទុស្សីលោ អ-សមាហិតោ ឯកាហំ ជីវិតំ សេយ្យោ សីល-វន្តស្ស ឈាយិនោ" ។

ប្រែថា "ជនណាទ្រុស្តសីលមានខ្លួនមិនតម្កល់នៅក្នុងសីលធម៌រស់នៅអស់មួយរយឆ្នាំ ការរស់នៅនៃជននោះ ពុំប្រសើរស្មើនឹងការរស់នៅត្រឹមតែមួយថ្ងៃនៃជន ដែលមានសីល, មានខ្លួនតាំងនៅក្នុងសីលធម៌" ពុទ្ធភាសិតនេះមានន័យថា អ្នកមានជីវិតរស់នៅមួយរយឆ្នាំ ដោយមិនមានសីល មិនមានចរិយាមារយាទថ្លៃថ្នូរ, មានការបៀតបៀនជិះជាន់មនុស្សគ្នាឯងដោយប្រើកម្លាំងណាមួយ មានកម្លាំងយសស័ក្តិ កម្លាំងទ្រព្យសម្បត្តិ កម្លាំងជាតិ កម្លាំងគោត្រ ជាដើម ការរស់នៅដូច្នេះ ពុំប្រសើរសោះឡើយ មានតែការរស់នៅផ្ទុយអំពីនេះ ទើបចាត់ថាជាការរស់នៅថ្លៃថ្នូរ ។

"យោ ច វស្សសតំ ជីវេ ទុប្បញ្ញោ អសមាហិតោ ឯកាហំ ជីវិតំ សេយ្យោ បញ្ញវន្តស្ស ឈាយិនោ" ។

*ប្រែថា ជនណាមិនមានបញ្ញា មានខ្លួនប្រាស់ចាកសេចក្តីចេះដឹង រស់នៅអស់មួយរយឆ្នាំ ការរស់នៅនៃជននោះ ពុំប្រសើរ ស្មើនឹងការរស់នៅត្រឹមតែមួយថ្ងៃ នៃជនដែលមានបញ្ញា, មានខ្លួនតម្កល់នៅក្នុងសេចក្តីចេះដឹង" ពុទ្ធភាសិតនេះដោយឲ្យដឹងថា អ្នកមានជីវិតរស់នៅយូរ តែពុំបានរៀនសូត្រវិជ្ជានានា, ពុំបានដឹកនាំខ្លួនទៅរកសេចក្តីចេះដឹងគ្រប់កម្មវិធីទាំងអស់ មានការចូលកាន់សមាគមបណ្ឌិតអ្នកប្រាជ្ញជាដើម ។ ជីវិតរស់នៅប្រាសចាកបញ្ញាដូចនេះ ជាជីវិតថុនអន់បំផុត, បើរស់នៅយូរណាស់ក៏កាន់តែថោកទាបណាស់, កាន់តែធ្ងន់សង្គមមនុស្សណាស់, កាន់តែទទឹងទាស់នឹងសេចក្តីចម្រើនដែលសាសនានិងជាតិត្រូវការណាស់ ។*

"យោ ច វស្សសតំ ជីវេ អបស្សំ ធម្ម-មុត្តមំ ឯកាហំ ជីវិតំ សេយ្យោ បស្សតោ ធម្ម-មុត្តមំ" ។

ប្រែថា "ជនណាមិនឃើញនូវធម៌មានគុណភាព ខ្ពង់ខ្ពស់, រស់នៅអស់រយៈកាលមួយរយឆ្នាំ ការរស់នៅនៃជននោះ ពុំប្រសើរស្មើនឹងការរស់នៅត្រឹមតែមួយថ្ងៃនៃជនអ្នកបានឃើញនូវធម៌មានគុណភាពខ្ពង់ខ្ពស់" ធម៌មានគុណភាពខ្ពង់ខ្ពស់ក្នុងទីនេះ បើជាផ្លូវបច្ចុប្បន្ន បានដល់ មគ្គបច្ចុប្បន្ន ៨ យ៉ាងគឺ៖

១) សម្មាទិដ្ឋិ ឃើញត្រូវក្នុងសម្បទា[(១)] បច្ចុប្បន្ន ៤ យ៉ាង

២) សម្មាសង្កប្បៈ គិតគូរត្រូវអំពីសម្បទាបច្ចុប្បន្ន ៤ យ៉ាង

៣) សម្មាវាចា និយាយត្រូវអំពីសម្បទាបច្ចុប្បន្ន ៤ យ៉ាង

---

(១) សម្បទាបច្ចុប្បន្នមាន ៤ យ៉ាងគឺ ១- ឧដ្ឋានសម្បទា, ២- អារក្ខសម្បទា, ៣- កល្យាណមិត្តតា, ៤- សមជីវិតា ។

៤) សម្មាកម្មន្តៈ ធ្វើការត្រូវតាមសម្បទាបច្ចុប្បន្ន ៤ យ៉ាង,

៥) សម្មាអាជីវៈ រស់នៅត្រូវតាមសម្បទាបច្ចុប្បន្ន ៤ យ៉ាង,

៦) សម្មាវាយាមៈ ខំប្រឹងធ្វើការតាមសម្បទាបច្ចុប្បន្ន ៤ យ៉ាង,

៧) សម្មាសតិ ចងស្មារតីត្រូវក្នុងសម្បទាបច្ចុប្បន្ន ៤ យ៉ាង,

៨) សម្មាសមាធិក្រុងចិត្តដោយសម្បទាបច្ចុប្បន្ន ៤ យ៉ាង ។

បើជាផ្លូវអនាគត បានដល់មគ្គបរលោក ៨ យ៉ាងគឺ៖

១) សម្មាទិដ្ឋិ ឃើញត្រូវក្នុងសម្បទា(២) បរលោក ៤ យ៉ាង

២) សម្មាសង្កប្បៈ គិតគូរត្រូវអំពីសម្បទាបរលោក ៤ យ៉ាង

៣) សម្មាវាចា និយាយត្រូវអំពីសម្បទាបរលោក ៤ យ៉ាង

៤) សម្មាកម្មន្តៈ ធ្វើការត្រូវតាមសម្បទាបរលោក ៤ យ៉ាង,

៥) សម្មាអាជីវៈ រស់នៅត្រូវតាមសម្បទាបរលោក ៤ យ៉ាង,

---

(២) សម្បទាបរលោកមាន ៤ យ៉ាងគឺ ១- សទ្ធា... សីល... បាគ... បញ្ញា ។

៦) សម្មាវាយាមៈខំប្រឹងធ្វើការត្រូវតាមសម្បទាបរលោក ៤ យ៉ាង,

៧) សម្មាសតិ ចងស្មារតីត្រូវក្នុងសម្បទាបរលោក ៤ យ៉ាង,

៨) សម្មាសមាធិ ក្រុងចិត្តដោយសម្បទាបរលោក ៤ យ៉ាង ។

បើជាផ្លូវនិព្វាន បានដល់លោកុត្តរមគ្គ ៨ យ៉ាងគឺ៖

១) សម្មាទិដ្ឋិ ឃើញត្រូវក្នុងសច្ចធម៌ ៤ យ៉ាង,

២) សម្មាសង្កប្បៈ គិតគូរត្រូវក្នុងសច្ចធម៌ ៤ យ៉ាង,

៣) សម្មាវាចា និយាយត្រូវតាមសច្ចធម៌ ៤ យ៉ាង,

៤) សម្មាកម្មន្តៈ ធ្វើការត្រូវតាមសច្ចធម៌ ៤ យ៉ាង,

៥) សម្មាអាជីវៈ រស់នៅត្រូវតាមសច្ចធម៌ ៤ យ៉ាង,

៦) សម្មាវាយាមៈ ព្យាយាមត្រូវតាមសច្ចធម៌ ៤ យ៉ាង,

៧) សម្មាសតិ ចងស្មារតីត្រូវក្នុងសច្ចធម៌ ៤ យ៉ាង,

៨) សម្មាសមាធិ ប្រកចិត្តចូលក្នុងសច្ច[១] ធម៌ ៤ យ៉ាង ។

ពុទ្ធភាសិតនេះបង្រៀនឱ្យចេះអំពីការរស់នៅថា អ្នកមានជីវិតរស់នៅយូរ, តែពុំបានស្គាល់ធម៌មានគុណភាពខ្ពង់-ខ្ពស់ទាំង ៣ ប្រភេទ, ប្រភេទណាមួយ, ពុំបានទុកដាក់ខ្លួនឲ្យរស់នៅក្រោមកម្មវិធីទាំងអស់ណា, ដែលជនមានចិត្តខ្ពស់បានបង្កើតឡើង គឺជាមនុស្សមិនខ្វីរវល់អំពីអ្វីៗ ទាំងអស់ រ-ហូតដល់វិញ្ញាណដែលជាពីជៈនៃរូបកាយរបស់ មនុស្សសត្វ, ជាគ្រាប់សម្រាប់បណ្ដុះវិញ្ញាណថ្មីទៀត ក៏មិនមានធ្វើការលាងសម្អាតសូម្បីបន្តិចបន្តួចសោះ, បណ្ដោយឲ្យវិញ្ញាណរបស់មនុស្ស ក្លាយភាពទៅជាវិញ្ញាណនៃសត្វគោអស់រលីងផង ។ ជីវិតរស់នៅប្រាសចាកគំនិតខ្ពស់ដូចនេះ ជាជីវិតធុនអន់បំផុត, បើរស់នៅកាន់តែយូរណាស់ ក៏កាន់តែថោកទាបណាស់ ។

(១) សច្ចធម៌៤យ៉ាងគឺ ១- ទុក្ខសច្ចៈ, ២- សមុទយសច្ចៈ, ៣- និរោធសច្ចៈ, ៤- មគ្គសច្ច ។

មនុស្សជួបគ្នាគេមិនចូលចិត្តសេពគប់រាប់រក រហូតដល់សត្វតិរច្ឆាន គឺឆ្កែដែលជាសត្វចូលចិត្ត និយាយទៅកាន់មនុស្សច្រើនជាងសត្វដទៃៗ ក៏វាឈប់និយាយរក ព្រោះអ្វី? ព្រោះមនុស្សពួកនេះមានខ្លួនធ្លាក់ចុះក្នុងហីនលក្ខណៈ ដែលមាននិយាយក្នុងតម្រាជោគជតាថា មនុស្សមិនមានការប្រាកដ គឺមិនប្រាកដ ជា អាវ ជា ខោ ជាភាពយន្ត, ជាល្ខោន, ជាផ្ទះ, ជាវត្ត, ជាស្នូម, ជាចោរ, ជាបារ, ជាសមោសរ ជាសមាគម (ល) គេទាំងឡាយនេះ ម្តងទៅយកខោធ្វើជាអាវ, ម្តងទៅយកអាវធ្វើជាខោ, ម្តងទៅលក់ប័ណ្ណរោងភាពយន្ត, ម្តងទៅបោសរោងភាពយន្ត, ម្តងទៅអង្គុយលើកៅអីមើលភាពយន្ត, ម្តងទៅជូតកៅអីរោងភាពយន្ត (ល) ប្រសិនបើនិយាយឲ្យបានច្បាស់លាស់ងាយស្តាប់ជាងនេះ, ជនទាំងឡាយប្រកបដោយគំនិតទាបនេះ គេច្រើនឃើញនៅក្នុងភាពកៀនៗ, មានជាអាទិ៍កៀនខោ កៀនអាវ

កៀនរោងភាពយន្ត, កៀនរោងល្ខោន, កៀនផ្ទះ, កៀនវត្ត, កៀនបុណ្យ, កៀនបារ, កៀនជប (ល) គឺមនុស្សគំនិតខ្ពស់ គេស្មៀកខោពាក់អាវ, គេអង្គុយមើលភាពយន្ត, ល្ខោន, នៅក្នុងរោង, គេនៅលើផ្ទះ, គេទៅវត្ត, គេធ្វើបុណ្យ, គេចូលបារ, គេផឹកកេសជ្ជៈគ្រប់យ៉ាងពេញលក្ខណៈ ។ ចំណែកមនុស្សពួកនេះ បានត្រឹមតែនៅក្បែរៗ ជិតៗ កៀនៗ មានកៀនជបជាដើម ។ ប្រហែលជាដោយជីវភាពនៃមនុស្សមានលក្ខណៈខ្ពង់ខ្ពស់និងមានលក្ខណៈ ថោកទាបជាងគ្នានេះហើយដឹង! បានជាព្រះសម្មាសម្ពុទ្ធរបស់យើងទ្រង់ហៅ មនុស្សមានជីវភាពខ្ពស់ថា “មនុស្សទេព” ទ្រង់ហៅមនុស្សមានជីវភាពទាបថោកថា “មនុស្សនរក” ឬ “មនុស្សប្រេត” ឬ “មនុស្សតិរច្ឆាន” មានន័យថា រស់នៅមានសេចក្ដីទុក្ខព្រួយដូចសត្វនរក រស់នៅដោយអំណោយអ្នកដទៃដូចពួកប្រេត រស់នៅដោយអាហារសំណល់ដូចសត្វតិរច្ឆាន ។

តែព្រះអង្គមិនទ្រង់បើកដៃឲ្យមនុស្សទេពចេះតែនាំគ្នាសប្បាយនៅលើសេចក្តីអត់ឃ្លាន ព្រួយលំបាករបស់មនុស្សគ្រប់ប្រភេទទេ ។ ផ្ទុយពីនេះទៅវិញ ព្រះអង្គទ្រង់សូមចិត្តមនុស្សទេពឲ្យជួយរំដោះសេចក្តីទុក្ខលំបាករបស់មនុស្ស ប្រភេទដទៃឲ្យអស់អំពីសមត្ថភាពរបស់ខ្លួន បើមិនដូច្នេះទេ ពិភពលោកនឹងត្រូវវេរគ្រោះថ្នាក់ទាំងអស់គ្នាជាពុំខានឡើយ ។

"យោ ច វស្សសតំ ជីវេ អបស្សំ ឧទយព្វយំ ឯកាហំ ជីវិតំ សេយ្យោ បស្សតោ ឧទយព្វយំ" ។

ប្រែថា "ជនណាមិនឃើញនូវសេចក្តីសោះសូន្យមាននៅក្នុងសេចក្តីកើត, រស់នៅអស់រយៈកាលមួយរយឆ្នាំ, ការរស់នៅនៃជននោះពុំប្រសើរស្មើ នឹងការរស់នៅត្រឹមតែមួយថ្ងៃ នៃជនដែលមានសេចក្តីឃើញ នូវសេចក្តីសោះសូន្យដែលមាននៅក្នុងសេចក្តីកើត, មានស្មារតីភ្ញាក់រលឹករឿយៗ

ក្នុងខយវយធម៌" ។ ពុទ្ធភាសិតនេះ បង្ហាញឲ្យឃើញថា អ្នកមានជីវិតវែង, តែមិនមានស្មារតីដឹងថា ជីវិតរបស់ខ្លួនកំពុងអស់ទៅជាមួយសភាវៈជុំវិញ ដែលធម្មជាតិតាក់តែងឡើង សម្រាប់ពិភពលោកនៃមនុស្ស ។ ជីវិតរស់នៅប្រាសចាកស្មារតីដូចនេះ ជាជីវិតអន់បំផុត បើរស់នៅកាន់តែយូរ ក៏កាន់តែអន់ណាស់ទៅទៀត ព្រោះអ្វី? ព្រោះតែមិនមានគំនិតក្នុងរឿងថា ជីវិតរស់នៅសម្រាប់ស្លាប់ ហើយគេក៏ពុំបានស្រាយបញ្ហាជីវិតមុនថ្ងៃដែលខ្លួនគេត្រូវស្លាប់ ។

**"អនិមិត្តមនញ្ញាតំ មច្ចានំ ឥធ ជីវិតំ កសិរញ្ច បរិតញ្ច តញ្ច ទុក្ខេន សញ្ញុតំ"**

ប្រែថា "ជីវិតនៃសត្វទាំងឡាយក្នុងលោកនេះ មិនមាននរណាកំណត់បាន, មិនមាននរណាដឹងមុន (នូវចលនារបស់វា) ជីវិតជារបស់លំបាកផង, ព្រោះវត្ថុធាតុដែលត្រូវរស់សុទ្ធតែបានមកអំពីស្វែងរក, ជារបស់តិចណាស់ផង ព្រោះ

ទោះណាជាមានគ្រឿងឧបភោគបរិភោគសម្រាប់ចិញ្ចឹម ស-ម្រាប់រក្សាគ្រប់គ្រាន់ ក៏នៅតែស្លាប់, ជារបស់ប្រកបដោយទុក្ខផង ព្រោះប្រកពនៃជីវិតមានកំណើត, មានចំណាស់ មានជំងឺ មានសម្លាប់ជាធម្មតា" ។ ពុទ្ធភាសិតនេះបង្រៀនឲ្យយើងចេះចាំថា ជីវិតមនុស្សមិនមាននរណាម្នាក់អាចដឹង, អាចកំណត់ទោះទាយមុនអំពីចលនាក្នុងអនាគតរបស់វាបានទេ វាលំបាក, វាតិច, វាមានទុក្ខច្រើន, ដូចនេះ ម្ចាស់ជីវិតគ្រប់គ្នាកុំបណ្ដោយឲ្យខូចពេល ត្រូវព្យាយាមដោះស្រាយបញ្ហាជី-វិតឲ្យស្រេច មុនដែលវានឹងលាយើងទៅ ។

"កម្មំ វិជ្ជា ច ធម្មោ ច សីលំ ជីវិតមុត្តមំ
ឯតេន មច្ចា សុជ្ឈន្តិ ន គោត្តេន ធនេន វា"

ប្រែថា "មនុស្សទាំងឡាយ រមែងបរិសុទ្ធបាន, ដោយការងារដែលខ្លួនធ្វើត្រូវ, ដោយវិជ្ជាដែលខ្លួនចេះដឹង

ពិតប្រាកដ, ដោយនាទីដែលខ្លួនបានប្រតិបត្តិល្អ, ដោយសីលធម៌ដែលខ្លួនបានអប់រំប្រពៃ ជីវិតខ្ពង់ខ្ពស់ មិនមែនដោយទ្រព្យសម្បត្តិ ដោយគោត្តត្រកូលទេ" ។ ពុទ្ធភាសិតនេះ បានបំភ្លឺគំនិតរបស់យើងឲ្យយល់ថា អ្វីៗ ទាំងអស់មិនអាចធ្វើឲ្យជីវិតបរិសុទ្ធ ជីវិតថ្លៃថ្នូរបានទេ, តែមនុស្សមានជីវិតបរិសុទ្ធ ថ្លៃថ្នូរ មកតែអំពីធម្មជាតុទាំងឡាយដូចបានពោលមកខាងលើនេះ ។

"ន ជច្ចា វសលោ ហោតិ ន ជច្ចា ហោតិ ព្រាហ្មណោ កម្មុនា វសលោ ហោតិ កម្មុនា ហោតិ ព្រាហ្មណោ"

ប្រែថា អំណាន់មិនមែនមកអំពីជាតិឬកំណើតទេ សេចក្តីប្រសើរថ្លៃថ្នូរក៏មិនមែនមានមកអំពីជាតិឬកំណើតដែរគឺមកអំពីការងារដែលមនុស្សធ្វើ ។ ពុទ្ធភាសិតនេះក៏មានបំណងចង់និយាយឲ្យឃើញសេចក្តីដូចពុទ្ធភាសិតខាងដើមនោះដែរ ។ អ្នកអាន

ចូរពិចារណា ហើយធ្វើនូវសេចក្ដីយល់ឃើញដោយខ្លួនឯងផងចុះ ។

ពុទ្ធសាសនា កាលណាអឺយអំពីរឿងជីវិត, ទំនុកក៏គឺចាស់, ឈឺ, ស្លាប់, តិច, ខ្លី, លំបាក, ទុក្ខ, ព្រួយមិនទៀង, មិនមានខ្លឹមសារ (ល) តែបើកាលណាអឺយដល់មុខងាររបស់ជីវិត, ពុទ្ធសាសនាមានមេរៀនប្រកបដោយទ្រឹស្ដីល្អច្រើនរាប់មិនអស់, សម្រាប់ឲ្យមនុស្សអនុវត្តទ្រឹស្ដីទាំងអស់នោះឲ្យទៅជាការងាររបស់ជីវិតនៃខ្លួន ។ ដូច្នេះឃើញថាគំហើញ[១] របស់ពុទ្ធសាសនាចំពោះរឿងជីវិតនេះ, ក្នុងខាងដើមថា មិនកើតមិនបានការ, តែក្នុងខាងចុងបំផុតថា ត្រូវតែកែជីវិតដែលមិនកើតនោះ ឲ្យទៅជាកើត, ដែលមិនបានការនោះ ឲ្យទៅជាបានការវិញ ។

**"សព្វេ សត្តា មរិស្សន្តិ មរណន្តំ ហិ**

(១) "គំហើញ" ជាពាក្យវេយ្យាករណ៍ ប្រើជំនួសសេចក្ដីឃើញ ។

**ជីវិតំ យថាកម្មំ គមិស្សន្តិ បុញ្ញបាបផលូប-
គា**″

ប្រែថា “សត្វទាំងឡាយទាំងពួងនឹងស្លាប់ ព្រោះថា ជីវិតរបស់មនុស្សទាំងឡាយ មានសេចក្តីស្លាប់ក្នុងទីបំផុត (មុនអំពីការស្លាប់) មនុស្សទាំងឡាយ ត្រូវបានទទួលកាន់យកផលនៃបុណ្យបាបហើយនិងទៅកាន់ (កំណើតថ្មីទៀតល្អអាក្រក់) ទៅតាមបុណ្យបាបរបស់ខ្លួន” ពុទ្ធ-ភាសិតនេះ បានបំភ្លឺគំនិតរបស់យើង មួយចំណែកធំទៀតដោយបានបញ្ជាក់យ៉ាងច្បាស់ថា “មនុស្សទាំងឡាយត្រូវបានទទួលកាន់យកនូវផលនៃបុណ្យ បាបហើយទើបទៅ” ធម្មជាតុដែលទៅក្នុងទីនេះ បានដល់វិញ្ញាណ, តែមិនមែនជាវិ-ញ្ញាណចាស់សព្វថ្ងៃនេះទេ គឺជាវិញ្ញាណមួយថ្មីទៀតដែលត្រូវបង្កើតឡើងដោយថាមពលនៃវិញ្ញាណចាស់ ។ ចំណែកវិញ្ញា-ណចាស់របស់មនុស្ស ក្រោយអំពីកាលបានបញ្ចេញវិញ្ញាណ

ថ្មីអំពីកម្លាំងថាមពល របស់វាស្រេចហើយ វាក៏រំលាយខ្លួនរបស់វាចោលទៅ ។ ព្រឹត្តិកម្មនៃវិញ្ញាណចាស់ និងព្រឹត្តិកម្មនៃវិញ្ញាណថ្មី យើងអាចប្រដូចបានទៅនឹងគ្រាប់ស្វាយចាស់ និងផ្លែស្វាយថ្មី, គ្រាប់ស្វាយចាស់ បានបង្កើតដើមស្វាយមួយថ្មី ហើយវាក៏រំលាយខ្លួនរបស់វាចោលបាត់ទៅ, ចំណែកដើមស្វាយថ្មី ក៏បានបំពេញមុខងាររបស់វា គឺបញ្ចេញផ្លែ, តែផ្លែរបស់វាមិនមែនជាផ្លែដែលបង្កើតដើមរបស់វានោះទេ គឺជាផ្លែមួយថ្មីទៀត ។ ដូច្នេះ វិញ្ញាណចាស់ និងគ្រាប់ស្វាយចាស់ ទើបត្រូវបានជាប្រភពនៃវិញ្ញាណថ្មី ផ្លែស្វាយថ្មី ។ បើវិញ្ញាណចាស់មានគុណភាពថ្លៃថ្នូរ, គ្រាប់ស្វាយចាស់មានគុណភាពល្អ, វិញ្ញាណថ្មីនិងផ្លែស្វាយថ្មី ក៏មានគុណភាពល្អថ្លៃថ្នូរដូចគ្នាដែរ ។

កាលណាវិញ្ញាណមានគុណភាពល្អ, សម្ភារៈនៃកំណើតទាំងឡាយ មានសក់ និងស្បែកជាដើម ក៏មានគុណ-

ភាពល្អ ៗ ដូច្នេះ បុគ្គលអ្នកត្រូវការចង់បាននូវកំណើតនៃជីវិតល្អ, ជាជីវិតនៃមនុស្សធម្មតាក្តី, ជាជីវិតនៃទេពក្តី, ជាជីវិតនៃព្រហ្មក្តី, ជាជីវិតព្រះទាំងឡាយមានព្រះពុទ្ធជាដើមក្តី គប្បីខំប្រឹងបំពេញធម៌សម្រាប់ចម្លងជីវិតមនុស្សអំពីដំណាក់មួយទៅកាន់ដំណាក់មួយ ហៅថា "ទសបារមី" ប្រែថា "បារមី ១០" ឬ "ធម៌សម្រាប់ចម្លងសត្វទៅកាន់ត្រើយ ១០ ប្រការ" គឺ៖

១) ទានៈ បំពេញទាន

២) សីលៈ បំពេញសីលធម៌

៣) នេក្ខម្មៈ បំពេញផ្នួស

៤) បញ្ញា បំពេញបញ្ញា

៥) វីរិយៈ បំពេញព្យាយាម

៦) ខន្តិ បំពេញសេចក្តីអត់ធន់

៧) សច្ចៈ បំពេញសច្ចធម៌

៨) អធិដ្ឋាន បំពេញសេចក្តីគួសដៅ

៩) មេត្តា បំពេញមេត្តាធម៌

១០) ឧបេក្ខា បំពេញគំហើញក្នុងឧត្តមគតិ ។

ខ្ញុំបានបំភ្លឺគំនិតរបស់អ្នកអានទូវបញ្ហាជីវិត ដោយបានដកស្រង់យកយោបល់របស់ទស្សនវិទូ និងសាសនាចារ្យទាំងឡាយ ដែលលោកមើលឃើញជីវិត របស់មនុស្សក្នុងន័យផ្សេងៗ គ្នា, រួមទាំងការត្រាស់ដឹងនូវជីវិតរបស់មនុស្សនៃព្រះពុទ្ធបរមគ្រូរបស់យើង ជូនអ្នកអានពិចារណាក្នុងសៀវភៅតូចនេះតែប៉ុណ្ណោះ ។ តអំពីនេះទៅ ខ្ញុំនឹងរៀបចំកម្មវិធីតស៊ូនៃជីវិត តាមរបបពុទ្ធសាសនា ដែលមានការទាក់ទងជាប់ជាមួយសង្គមនៃមនុស្សលោក និងការស្រាយបញ្ហាជីវិតរបស់មនុស្ស តាមគតិនៃពុទ្ធសាសនាជាន់កណ្តាល និងជាន់ខ្ពស់, ដើម្បីឲ្យអ្នកអានបានពិចារណា ហើយអនុវត្តនូវទ្រឹស្តីទាំងឡាយនោះទៅជាសេចក្តីប្រតិបត្តិតាមគួរដល់សេចក្តីត្រូវការរបស់ខ្លួន ។

## ជីវិតគឺការតស៊ូ

ការតស៊ូចែកបានជា ៣ ប្រភេទគឺៈ

១) តស៊ូជាមួយធម្មជាតិ,

២) តស៊ូជាមួយមនុស្សគ្នាឯង,

៣) តស៊ូជាមួយហេតុការណ៍ ។

## ការតស៊ូជាមួយធម្មជាតិ

ការតស៊ូមានសេចក្ដីថា ទម្លាយគូសត្រូវ គឺធ្វើឲ្យសត្រូវទទួលចុះចាញ់, តែការតស៊ូជាមួយធម្មជាតិមានសេចក្ដីផ្ទុយពីនេះគឺគ្រាន់តែកែប្រែធម្មជាតិ ឲ្យគួរដល់សេចក្ដីត្រូវការរបស់ខ្លួននៃជនអ្នកធ្វើការតស៊ូ ដោយការរៀបចំធម្មជាតិ ដែលមិនមានប្រយោជន៍ឲ្យទៅជាមានប្រយោជន៍ក៏មាន, ដោយចៀសវាងធម្មជាតិដែលប្រកបដោយគ្រោះកាចក៏មាន , ឧទា-

ហរណ៍ ដូចមនុស្សយើងនៅក្នុងទឹកដែ្នងធម្មជាតិអាក្រក់, មាន អាកាសមិនល្អ, មានជំងឺគ្រុនចាញ់ច្រើន, យើងចៀស ចេញអំពីកន្លែងនេះទៅរកកន្លែងថ្មីទៀត, យើងនៅក្នុងទឹកន្លែងហែងហួតមិនមានទឹក, ធ្វើស្រែចំការមិនកើត, យើងអាកៀសទៅរកទឹកន្លែងមានទឹកសម្រាប់ប្រកបរបរដំណាំ អំពើនេះមិនរាប់ថា ខុសកម្មវិធីតស៊ូទេ ព្រះពុទ្ធបរមគ្រូក៏មានសំដែងថា "បដិរូបទេសវាស[១]" ប្រែថា "ការនៅក្នុងប្រទេសសមគួរ"

តែខាងប្រវត្តិសាស្ត្រ គេពិសោធឃើញថា មនុស្សដែលមានសេចក្តីចម្រើនយ៉ាងពិតប្រាកដនោះ មិនមែនជាមនុស្សចុះចាញ់កំណាចរបស់ធម្មជាតិទេ, តែជាមនុស្សតស៊ូការពារកំណាចរបស់ធម្មជាតិ ឬ រកមធ្យោបាយយកកំណាចរបស់

(១)បដិរូបទេសវាសប្រទេសសមគួរគឺប្រទេសដែលមានការបដិរូបនិងការបដិវត្តន៍ក្នុងវិស័យទាំងឡាយមានវិស័យសេដ្ឋកិច្ចនិងវិស័យវប្បធម៌ជាដើម ។

ធម្មជាតិនោះមកធ្វើជាប្រយោជន៍ខ្លួន, ចំណែកមនុស្សដែលរត់លួនគេចចេញពីកំណាចរបស់ធម្មជាតិ រមែងរកសេចក្ដីចម្រើនពុំបានឡើយ ព្រោះខ្លួនជាមនុស្សស្ញារប្ដូរផ្លាស់កន្លែងរឿយៗ ទីបំផុតអាចនឹងសូន្យជាតិសូន្យប្រទេសទៅក៏មាន ។

ដូច្នេះ យើងត្រូវប្រកាន់លំខគោលថា ជាមនុស្សត្រូវតែតស៊ូនឹងធម្មជាតិកាចអាក្រក់ មានក្ដៅណាស់ត្រជាក់ណាស់ជាដើម ។ ក្នុងពេលប្រតិបត្តិការ, អ្នកធ្វើការត្រូវជាអ្នកភ្លេចសេចក្ដីនឿយហត់, ភ្លេចសេចក្ដីសប្បាយដែលមកធាតោការងារ, ភ្លេចសេចក្ដីឈឺចាប់បន្តិចបន្តួច, ភ្លេចអារម្មណ៍ស្នេហា ។ ត្រូវកុំអាងថាក្ដៅ, ថាត្រជាក់, ថាព្រឹក, ថាល្ងាច, ថាស្រេក, ថាឃ្លាន, ។ល ។ ហើយមិនធ្វើការងារ ។

ធម្មជាតិមិនត្រូវការឲ្យមនុស្សយើងរត់លួន, ធម្មជាតិត្រូវការឲ្យតស៊ូ, ធម្មជាតិបានឲ្យផលជាច្រើនក្នុងការតស៊ូ ។

គេសង្កេតឃើញថាក្នុងផែនដី ដែលមានកម្លាំងកាចអាក្រក់របស់ធម្មជាតិនោះ សុទ្ធតែមានរបស់ល្អនៅក្នុងទីនោះជាច្រើន កន្លែងណាមានធម្មជាតិកាចអាក្រក់ណាស់ កន្លែងនោះរឹងរឹតតែមានវត្ថុធាតុល្អណាស់ ។

ក្នុងកន្លែងដែលមានអណ្តូងមាស ប្រាក់ ប្រេងកាត ប្រេងសាំង ឬក្នុងកន្លែងដែលមានទ្រព្យសម្បត្តិ ធម្មជាតិដែលសាងសភាពមនុស្សឲ្យទៅជាមហាសេដ្ឋីបាននោះ, តាមប្រ-ក្រតីសុទ្ធតែជាកន្លែងដែលមានគ្រោះកាចអាក្រក់, មានជំងឺគ្រុនចាញ់ច្រើន, ក្នុងទ្វីបអាមេរិក, សូម្បីត្រង់រដ្ឋធានី វ៉ាស៊ីង-តោន ដែលជាកន្លែងស្អាងស្អាតសុខចម្រើនជាទីបំផុតមួយក្នុងលោកនេះ កាលអំពី ១០០ ឆ្នាំកន្លងមកហើយនោះកន្លែងនេះពោរពេញទៅដោយជំងឺគ្រុនចាញ់ មនុស្សយើងព្យាយាមតស៊ូពង្រាបកម្លាំងកាចអាក្រក់របស់ធម្មជាតិ ទាល់តែក្លាយទៅជាទីចម្រើនរុងរឿងខ្ពង់ខ្ពស់បាន ។

តាមធម្មតាក្នុងព្រៃជ្រៅធំៗ ដែលមានសេចក្ដីអន្ដរាយអំពីសត្វសាហាវ ឬអំពីជំងឺគ្រុនចាញ់ ច្រើនតែមានរបស់ល្អ ៗ ឬច្រើនតែមានរ៉ែជាតុ ព្រោះធម្មជាតិបានសាងវត្ថុល្អៗ ទុកឲ្យមនុស្សដែលមានសេចក្ដីមានះព្យាយាម, ចំណែកមនុស្សដែលមានសេចក្ដីអន់ខ្សោយ មិនអាចនឹងទៅយករបស់ល្អរបស់ធម្មជាតិបាន, ក្នុងកន្លែងដែលទឹកលិចជ្រៅខួបប្រាំងរស្សាជាកន្លែងមានគ្រោះថ្នាក់អាក្រក់ ដល់ផ្ទះសម្បែងលំនៅឋានរឿយៗ បើមនុស្សយើងបានប្រើសេចក្ដីព្យាយាមសាងប្រឡាយបង្ហូរទឹក ក៏បានផលយ៉ាងប្រសើរ, កន្លែងត្រង់នោះនឹងក្លាយទៅជាកន្លែងឧត្ដមសម្បូរណ៍ដោយរបរដំណាំ និងរបរចិញ្ចឹមសត្វ នេះគឺជាផលនៃការតស៊ូ ដែលមនុស្សយើងបានទទួលអំពីធម្មជាតិ ។

ទីដៅក្នុងការតស៊ូជាមួយនឹងធម្មជាតិ ក៏គឺដើម្បីឲ្យមនុស្សមានជីវិតរស់នៅបាន, មនុស្សយើងនឹងមានជីវិតរស់

នៅបានត្រូវអាស្រ័យបច្ច័យ ៤ យ៉ាងគឺ គ្រឿងស្លៀកដណ្តប់, អាហារ, ទីកន្លែងនៅ, និងឱសថរក្សាជំងឺ ដើម្បីតស៊ូជាមួយសេចក្តីត្រជាក់ កម្តៅមនុស្សយើងមិនមានស្បែកក្រាស់មិនមានរោមវែងដូចសត្វ យើងត្រូវសាងគ្រឿងស្លៀកដណ្តប់ ស្វែងរកអាហារចំណី ដោយចាំបាច់ខានមិនបាន, កាលណាមនុស្សមានចំនួនច្រើនឡើង ការស្វែងរកអាហារទុកដាក់សម្រាប់ចិញ្ចឹមជីវិត រមែងមិនគ្រប់គ្រាន់ដល់សេចក្តីត្រូវការ មនុស្សត្រូវរកកម្មវិធីមួយទៀតគឺធ្វើផលិតផល បានដល់ការសាបព្រោះ, ការចិញ្ចឹមសត្វយកទឹកដោះ, ការហត្ថកម្មនិងការឧស្សាហកម្ម ដែលមានប្រយោជន៍ដល់ជីវភាពរបស់ខ្លួន ។

សេចក្តីសំខាន់ក្នុងការតស៊ូជាមួយធម្មជាតិនោះ កម្មវិធីដំបូងគឺធ្វើឲ្យរាងកាយមានអនាម័យល្អ មិនបណ្តោយឲ្យជីវិតរស់នៅក្នុងសេចក្តីទន់ខ្សោយខាងសុខភាព ព្រោះកម្លាំងតស៊ូទាំង

បី គឺកម្លាំងកាយ កម្លាំងចិត្ត និងកម្លាំងគំនិតនោះ កម្លាំងកាយមានសេចក្ដីសំខាន់ជាងកម្លាំងឯទៀតៗ បើកម្លាំងកាយមានមិនគ្រប់គ្រាន់ហើយ ក៏លំបាកនឹងសាងកម្លាំងឯទៀតៗឲ្យកើតឡើងបានណាស់ ។ ចំពោះរឿងសុខភាពអនាម័យល្អនេះ ព្រះពុទ្ធសាសនាបានរំលឹកដោយភាសិតថា "**អា-រោគ្យា បរមា លាភា**" ដែលយើងធ្លាប់បានដឹងបានឮស្រាប់ហើយ ។ ការតស៊ូជាមួយធម្មជាតិដើម្បីរក្សាអនាម័យនោះ, ត្រូវអនុវត្តតាមលក្ខណៈរបស់ធម្មជាតិ, ធម្មជាតិបានសាងឡើងនូវរបស់គ្រប់យ៉ាងឲ្យជាវេលា, បើយើងរក្សា "សភាពជាវេលា" យ៉ាងធម្មជាតិតាក់តែងឲ្យក៏ជាវិធីល្អបំផុតរបស់មនុស្សយើង, អាកាសបរិសុទ្ធធម្មជាតិបានសាងទុកឲ្យ ដោយមិនមានការហួងហែងឬ មិនចាំបាច់ត្រូវទិញដោយលុយកាក់, អ្នកគង់បានជួបនូវជីវប្រវត្តិនៃមហាបុរសខ្លះគង់បានដឹងថា ការដែលគេធ្វើជាដំបូងក្នុងវេលាព្រឹកនោះ គឺ

ដកដង្ហើមស្រូបអាកាសបរិសុទ្ធចូលទៅក្នុងសួត, ក្រោកដើរចេញទៅក្រៅអំពីព្រឹក ដើម្បីបានទទួលអាកាសបរិសុទ្ធ ។

សរុបសេចក្ដីថា, បឋមតស៊ូរបស់មនុស្សគឺតស៊ូដើម្បីសុខភាពនិងអនាម័យល្អ ធម្មជាតិបានបង្គាប់ឲ្យយើងតស៊ូ, បានជាធម្មជាតិឲ្យគ្រឿងឧបករណ៍តស៊ូគ្រប់គ្រាន់, ការបដិបត្តិតាមលក្ខណៈរបស់ធម្មជាតិ, ការស្ដាប់ពាក្យដំបូន្មានរបស់គ្រូពេទ្យ និងការធ្វើតាមតម្រាសុខវិទ្យាជាការល្អបំផុត, ហើយមិនមានបង់ខាតទ្រព្យសម្បត្តិអ្វីផង ដូចការដកដង្ហើមឲ្យវែងៗ ក្នុងវេលាព្រឹកជាការងាយធ្វើបំផុត តែយើងពុំបានធ្វើឲ្យជាប់លាប់ ឯជនដែលគេបានធ្វើត្រឹមត្រូវតាមពេលវេលាៗ នោះ គេរមែងមានសុខភាពអនាម័យល្អជាងយើង ។

## ការតស៊ូជាមួយមនុស្សគ្នាឯង

១- ជាមនុស្សគប្បីជឿថា មនុស្សយើងនឹងរស់

នៅបានក្នុងលោកនេះ ដោយការតស៊ូ, បើយើងមិនតស៊ូក៏ប្រែថាយើងត្រូវស្លាប់ ព្រោះការមិនតស៊ូនោះជាសេចក្តីស្លាប់ពិតៗ ជាសេចក្តីស្លាប់សម្រាប់មនុស្សម្នាក់ៗ ផង ជាសេចក្តីស្លាប់សម្រាប់ប្រទេសជាតិផង, ការរាថយក្រោយមិនបានឲ្យផលអ្វីឡើយ, សេចក្តីចាំបាច់បង្គាប់ឲ្យយើងតស៊ូ, មនុស្សយើងកើតមកសម្រាប់ការតស៊ូ, ការគេចរត់លូន បានទទួលផលគឺចាញ់ឬស្លាប់ប៉ុណ្ណោះឯង ។

២-) ក្នុងពេលតស៊ូនោះ យើងត្រូវមានគ្រឿងឧបករណ៍ពីរយ៉ាង, ម្យ៉ាងគឺសេចក្តីអត់ធន់ ទាំងខាងរូបកាយនិងចិត្តវិញ្ញាណ, ខាងរូបកាយដោយកអនាម័យល្អ, សុខភាពរឹងប៉ឹង, ខាងចិត្តវិញ្ញាណដោយកសេចក្តីធន់ទ្រាំទុក្ខលំបាកមិនស្តែងអាការៈត្អូញត្អែរ ឬចំណុចទន់ខ្សោយឲ្យគេដឹងឮ, ម្យ៉ាងទៀតមនុស្សអ្នកតស៊ូត្រូវមានគ្រឿងប្រដាប់ មានគ្រឿងឧបករណ៍គ្រប់គ្រាន់សម្រាប់ខ្លួន ដែលស្តែងឲ្យឃើញ

ថា បើនរណាមកបៀតបៀនជិះជាន់យើង គេនឹងត្រូវបាន ទទួលការតបតវិញយ៉ាងពេញបន្ទុក ។

ការតស៊ូដូចពោលមកខាងដើម គ្រាន់តែជាចំណែក មួយនៃការតស៊ូក្នុងជីវិតគឺជាការតស៊ូបេញមុខ ចំពោះកម្លាំង របស់សត្រូវត្រង់ៗ ចាប់តាំងអំពីត្រូវកំហែងសង្កត់សង្កិនលើ រូបកាយរហូតដល់កេរ្តិ៍ឈ្មោះ និងអនាគតរបស់យើង, តែ ពាក្យថា "ការតស៊ូ" មានន័យពីរយ៉ាង ម្យ៉ាងជាការត ស៊ូដើម្បីការពារនូវសេចក្តីជិះជាន់, ម្យ៉ាងទៀត ជាការតស៊ូដើ- ម្បីយកជ័យជម្នះ ក្នុងការដណ្តើមប្រជែងរបស់ជីវិត ព្រោះ ជីវិតរបស់មនុស្សដែលរស់នៅជាមួយគ្នាក្នុងលោក មានចំនួន កាន់តែច្រើនឡើងៗ ការដណ្តើមប្រជែងប្រកួតប្រណាំងជា ការចាំបាច់ត្រូវធ្វើទាំងខាងការពារទាំងខាងដណ្តើមប្រជែង ។

មានពុទ្ធភាសិតមួយបទថា "អសាធុំ សាធុនា ជិនេ" ប្រែថា "ជាមនុស្សគប្បីយកឈ្នះដោយសេចក្តី

ល្អ" មួយទៀតថា

"អប្បមត្តោ បមត្តេសុ សុត្តេសុ ពហុជាគរោ

អពលស្សំវ សីឃស្សោ ហិត្វា យាតិ សុមេ-

ធសោ" ប្រែថា "អ្នកណាប្រមាទក្មេចខ្លួនក៏តាមតែគេចុះ យើងកុំប្រមាទ, អ្នកណាដេកលក់សប្បាយក៏តាមតែគេចុះ, យើងត្រូវតែភ្ញាក់រលឹកជានិច្ច, បុគ្គលវៃឆ្លាតចូលចិត្តរឿងនេះ រមែងស្ទុះស្ទារត់មុខជនឯទៀតបាន ដូចសេះមានថ្វីជើងល្អ បោះបង់ចោលនូវសេះមានថ្វីជើងអន់ខ្សោយទៅខាងក្រោយ" ។

ភាសិតទាំងពីរបទនេះ បានចង្អុលផ្លូវតស៊ូឲ្យដល់យើងពីរយ៉ាង គឺខាងការពារនិងខាងប្រណាំងប្រជែង ។ ភាសិតដើមគឺ "**អសាធុំ សាធុនា ជិនេ**" នោះមានន័យពីរយ៉ាង, ម្យ៉ាងគឺអ្នកណាមកធ្វើអំពើអាក្រក់ដល់

យើង, យើងត្រូវធ្វើអំពើល្អតបវិញ, ម្យ៉ាងទៀត អ្នកណាធ្វើអំពើអាក្រក់យ៉ាងណាក៏ដោយតាមតែគេចុះ យើងចេះតែធ្វើអំពើល្អ ដរាបបានជ័យជម្នះ ។

ត្រង់បទទី ២ ដែលថាធ្វើសេចក្ដីល្អ ត្រូវបានឈ្នះសេចក្ដីមិនល្អរបស់ជនដទៃនោះមិនមានចោទជាបញ្ហាអ្វីទេ តែការប្រណាំងប្រជែងគ្នាពិតៗ យើងនឹងយកសេចក្ដីល្អ ទៅផ្ចាញ់សេចក្ដីមិនល្អពុំបានឡើយ, ចំពោះរឿងការតស៊ូក៏មានន័យត្រូវពិចារណា ត្រូវសិក្សាតទៅទៀតឲ្យច្រើនទើបយល់បាន ឧទាហរណ៍ដូចជាព្រះពុទ្ធបរមគ្រូទ្រង់ឈ្នះភិក្ខុទេវទត្ត ដោយសេចក្ដីល្អរបស់ព្រះអង្គ ក៏នៅក្នុងរឿងសិក្សារបស់យើង ។

ខាងគ្រីស្ដសាសនាគេបង្រៀនថា បើមានអ្នកណាមកទះកំភ្លៀងអ្នកម្ខាង, ឲ្យហុចកំភ្លៀងម្ខាងទៅឲ្យគេទះទៀត ។ ពាក្យបង្រៀននេះ ស្រដៀងគ្នានឹងព្រះពុទ្ធសាសនាថា "អសាធុំ សាធុនា ជិនេ" តែជាពាក្យបង្រៀនមាន

សេចក្តីខ្ទាំងក្លាជាងព្រះពុទ្ធសាសនារបស់យើង, ព្រះយេស៊ូរបស់គេ បានប្រតិបត្តិតាមពាក្យនេះយ៉ាងតឹងរឹង, ព្រោះកាលយេស៊ូត្រូវគេប្រហារនោះ, មិនមែនថាមិនមានដៃតស៊ូទេ ។ ពួកកូនសិស្សមានកម្លាំងអាវុធគ្រប់គ្រាន់សម្រាប់តស៊ូ, តែយេស៊ូហាមដាច់ខាតមិនឲ្យតស៊ូ, សុខចិត្តស្លាប់ដោយមិនមានការតស៊ូ លទ្ធផលដែលបានពីការស្លាប់របស់យេស៊ូនោះក៏ជាលទ្ធផលធំពិសាលមុខគួរសរសើរ ។ មរណកម្មនៃយេស៊ូធ្វើឲ្យគ្រឹស្តសាសនា បានចម្រើនរុងរឿងដល់សព្វថ្ងៃ ព្រោះមហាបរិច្ចាគរបស់ម្ចាស់នៃលទ្ធិនេះឯង ទើបនាំឲ្យគ្រិស្តបរិស័ទឃើញចិត្តតស៊ូនៃព្រះរបស់ខ្លួន ហើយនាំគ្នារាប់អានរហូតមក ។

តែព្រះពុទ្ធបរមគ្រូរបស់យើងទ្រង់តស៊ូផ្ទុយអំពីនេះ ក្នុងកាលទេវទត្តគិតសម្លាប់ព្រះអង្គ, ព្រះអង្គពុំព្រមស្លាប់ដូចព្រះយេស៊ូ គឺក្នុងកាលណាមានការប្រទូសរ៉ាយកើតឡើង ព្រះ-

អង្គទ្រង់រកពិធីរម្ងាប់ មិនបណ្ដោយឲ្យការអាក្រក់នោះ រាល ដាលដល់ទៅឲ្យផលអាក្រក់ដល់ព្រះអង្គ, គតិខាងព្រះពុទ្ធ- សាសនាទើបទៅជាផ្លូវកណ្ដាល សមនឹងឈ្មោះថា "មជ្ឈិមា បដិបទា" ។

ចំណែកខាងយោបល់ផ្ទាល់ខ្លួនរបស់ខ្ញុំៗ ជឿថា ការប្រទូសរ៉ាយនោះ នឹងបណ្ដោយឲ្យធ្វើពុំបានឡើយ ព្រោះថា បើចេះតែបណ្ដោយទៅ អំពើប្រទូសរ៉ាយក៏ចេះតែមានច្រើនឡើងទៀត ។ ដូច្នេះ ត្រូវតែតស៊ូ ដោយវិធីណាមួយតាមផ្លូវច្បាប់សម្រាប់ប្រទេស ឬ តាមកម្លាំងណាមួយ ដែលអាចជ្រើសរើសរកបាន ។

អ្នកប្រវត្តិសាស្ត្រម្នាក់បានសរសេរថា "ជាគ្រោះកាចមួយរបស់សាកលលោក នេះដែលយើងមិនអាចនឹងកម្ចាត់បង់នូវអំពើសាហាវមួយដែលមានកម្លាំង ខ្លាំងក្លាជាងការតទប់របស់យើង គឺយើងត្រូវតទប់ដោយកម្លាំងខ្លាំងក្លាជាងទើប

បាន ។ ការបង្ក្រាបចោរកំណាច ដែលប្ញន់ទ្រព្យសម្បត្តិដោយប្រើកម្លាំងអាវុធ, យើងត្រូវប្រើកម្លាំងអាវុធឲ្យពូកែជាង" ពាក្យនេះមានសេចក្តីជំទាស់នឹងសីលធម៌ តែការពិតជារឿងចាំបាច់សម្រាប់ជីវិត ទាំងចំពោះខ្លួនបុគ្គលម្នាក់ៗ ទាំងប្រទេសជាតិ ។

យើងមានការតស៊ូមួយទៀត ជាការតស៊ូខាងប្រណាំងប្រជែង, ការប្រណាំងប្រជែង ជាការចាំបាច់សម្រាប់ជីវិតមនុស្ស ព្រោះមនុស្សមានចំនួនច្រើន, ឋានន្តរល្អៗ មានចំនួនតិច, មនុស្សចាំបាច់ត្រូវដណ្តើមប្រជែងគ្នា ដើម្បីឡើងទៅកាន់ឋានន្តរនោះ សូម្បីក្នុងរឿងទ្រព្យសម្បត្តិក៏ដូចគ្នាដែរ ទ្រព្យសម្បត្តិធម្មជាតិក្នុងលោកមានចំនួនតិច មនុស្សក្នុងលោកមានចំនួនច្រើន បើជនពួកមួយមានសម្បត្តិទ្រព្យស្តុកស្តម្ភ ជនមួយពួកទៀតរមែងខ្វះទ្រព្យសម្បត្តិព្រោះមកអំពីការចាក់ផ្ទេរពីជនម្នាក់ទៅជនម្នាក់, កម្រនឹងរកវិធីណា

មកធ្វើឲ្យមនុស្សមានទានស្មើៗ គ្នាបាន, ការប្រណាំងប្រ-ជែងរវាងមនុស្សរមែងកើតឡើងរឿយៗ ចូលក្នុងភាសិតថា "សេះមានថ្វីជើងលឿនជាង រមែងចោលសេះដែលមានថ្វីជើងអន់ខ្សោយ" ។

តែយើងត្រូវប្រកាន់ខ្ជាប់នូវឧត្តមគតិមួយថា ការប្រណាំងប្រជែងនោះត្រូវប្រណាំងប្រជែងដោយល្អ គឺប្រណាំងប្រជែងខាងប្រកបរបរធ្វើការងារឲ្យបានច្រើនជាងគ្នា វិធីប្រ-ណាំងប្រជែង ដោយយកល្អដាក់ខ្លួនឯង យកអាក្រក់ដាក់ឲ្យជនដទៃនោះ ជាវិធីប្រណាំងប្រជែងយ៉ាងទាបថោក មិនចំពោះតែខាងសីលធម៌ទេ សូម្បីក្នុងសេចក្តីពិតដែលតែងកើតមានឡើងដល់ជីវិតមនុស្សក៏ជាការមួយអាចឲ្យគេពិសោធបានថា ការដណ្តើមប្រជែងដោយយកសេចក្តីល្អដាក់ខ្លួនឯង យកសេចក្តីអាក្រក់ដាក់ឲ្យអ្នកឯទៀតនោះ ទីបំផុតផលអាក្រក់រមែងកើតមានដល់ខ្លួនឯងវិញ ។

ខ្ញុំមិនធ្លាប់ឃើញ មនុស្សដែលឡើងកាន់ឋានៈខ្ពង់ខ្ពស់ ឬ ឋានៈមានទានស្តុកស្តម្ភ ដោយការធ្វើឲ្យជនដទៃធ្លាក់ចុះ ដុនដាបរលំរលាយ, ហើយខ្លួនឯងទៅជាបុគ្គលមានសេចក្តីសុខ ឬ តាំងនៅក្នុងឋានៈខ្ពង់ខ្ពស់បានយូរឡើយ ។ ការលើកខ្លួនឯងឡើងកាន់ឋានៈខ្ពង់ខ្ពស់ ដោយការជិះជាន់អ្នកដទៃរមែងឲ្យផលអាក្រក់ទាន់ភ្នែក មិនចាំបាច់និយាយដល់ឋានសួគ៌ឋាននរក សូម្បីក្នុងជីវិតបច្ចុប្បន្ននេះ ក៏រមែងបានទទួលផលអាក្រក់យ៉ាងជាក់ស្តែង ត្រូវនឹងសុភាសិតខ្មែរយើងថា "ឲ្យសេចក្តីទុក្ខដល់អ្នកឯទៀត នឹងមានទុក្ខដល់ខ្លួនវិញ"

រឿងចាប់កំហុសរបស់ជនដទៃ បើជាអ្នកមាននាទីដោយចំពោះ គឺជាប៉ូលិសកាន់នាទីខាងស៊ើបអង្កេតសួរចម្លើយជនទុច្ចរិត ឬ បុគ្គលដែលបានទទួលការតែងតាំងឲ្យជាគណៈកម្មការសួរចម្លើយ ឬ ចៅក្រមកាត់សេចក្តី មាននាទីត្រូវវិនិ-

ចូយទោសដោយត្រង់ៗ តាមផ្លូវច្បាប់, អ្នកមាននាទីយ៉ាងនេះនឹងធ្វើអ្វីៗ ទៅក៏មិនកើតផលអាក្រក់, ប៉ូលិសរឹងរឹតតែចាប់ចោរបានច្រើន ក៏រឹងរឹតតែមានកេរ្តិ៍ឈ្មោះល្អឡើង, គណៈកម្មការសួរចម្លើយបានច្រើន, ចៅក្រមកាត់សេចក្តីបានច្រើន ក៏រឹងរឹតតែបានយសស័ក្តិធំឡើងទៀត មិនមានអ្នកណាស្អប់ខ្ពើមប៉ូលិស គណៈកម្មការនិងចៅក្រម ដែលបានប្រតិបត្តិការដោយសុចរិតយុត្តិធម៌តាមនាទីរបស់ខ្លួនឡើយ ។

ដោយហេតុនេះ ការដណ្តើមប្រជែងក្នុងជីវិតរបស់មនុស្សនោះ បើធ្វើដោយល្អគឺឲ្យបានល្អទាំងខ្លួនឯងផងទាំងអ្នកដទៃផង, អ្នកណាធ្វើបានច្រើនជាង អ្នកនោះឈ្នះ, នេះគឺជាការប្រណាំងប្រជែងយ៉ាងត្រឹមត្រូវ ។

# ការតស៊ូជាមួយហេតុការណ៍

រឿងតស៊ូជាមួយហេតុការណ៍នោះ មានកម្មវិធីខុសអំពីការតស៊ូជាមួយធម្មជាតិ ឬ មនុស្សគ្នាឯងពីរប្រការគឺៈ

១) ការតស៊ូជាមួយធម្មជាតិ ឬ ជាមួយមនុស្សផងគ្នា ត្រូវប្រើវិធីពីរយ៉ាងគឺតស៊ូដោយត្រង់ចំៗ ឬ តស៊ូដោយគៀនៗ ក្បែរៗ តែការតស៊ូជាមួយហេតុការណ៍នោះ ធ្វើដូច្នេះពុំបានសម្រេចផលឡើយ ត្រូវតស៊ូដោយគៀនៗក្បែរៗ វិញទើបបានផលល្អ ។

២) ការតស៊ូជាមួយហេតុការណ៍ ដែលនឹងបានជ័យជម្នះត្រូវផ្អែកទៅលើសេចក្ដីអត់ធន់ច្រើនជាងកលល្បិច ព្រោះហេតុការណ៍រមែងមានការប្រែប្រួលប្ដូរផ្លាស់ជានិច្ច ។ ហេតុការណ៍មួយៗ ដែលកើតឡើងទាក់ទងនឹងមនុស្សភាគច្រើនបុគ្គលម្នាក់ៗ នឹងប្រយុទ្ធតស៊ូដោយត្រង់ចំៗ ជាការលំបាក

របៀបតស៊ូជាមួយនឹងហេតុការណ៍អាក្រក់នោះ គឺត្រូវសាង កម្លាំងឲ្យបានមាំមួនជាមុន ។ ឧទាហរណ៍ ដូចក្នុងប្រទេស របស់យើងមានទឹកលិចរាល់ឆ្នាំ, បុគ្គលម្នាក់ៗ នឹងការពារ ឬ ហាមមិនឲ្យទឹកមកលិចនោះជាការផុតនិស្ស័យ, តែយើង ត្រូវរកវិធីការពារជាពិសេសដូចជាលើកទំនប់ឲ្យខ្ពស់ ធ្វើរបាំង ឲ្យបានមាំមួន ។ យើងខ្លាចជំងឺធ្ងន់ ត្រូវចាក់ថ្នាំការពារ បើ យើងមិនចង់មានគ្រោះថ្នាក់អំពីសង្គ្រាម ត្រូវរៀបចំធ្វើបន្ទាយ លេណដ្ឋានសម្រាប់ជ្រករៀងរាល់ខ្លួន ។

សេចក្តីពិត, ការរៀបចំការពាររបស់មនុស្សជាការថ្លៃ ថ្នូរបំផុត ក្នុងជីវិតរបស់មនុស្សមិនឃើញមានអ្វីសំខាន់ក្រៃ- លែងជាងការតស៊ូទេ ។ ខ្ញុំយល់ឃើញថា មនុស្សចេះធ្វើ ការប្រយុទ្ធតស៊ូ ជាមនុស្សគួរស្រឡាញ់រាប់អានគួរសរសើរ ទោះជាមនុស្សនោះមានឋានៈជាអ្វីក៏ដោយ, ខ្ញុំពេញចិត្តនឹង ឲ្យកិត្តិយសដល់អ្នកតស៊ូ សូម្បីអ្នកនោះជាសត្រូវ ជាគូតស៊ូ

របស់ខ្ញុំក៏ដោយ ។

ខ្ញុំមិនដែលនឹកស្អប់ខ្ពើមជន អ្នកមានសេចក្តីព្យាយាមតស៊ូ នឹងសត្រូវដែលជិះជាន់ខ្លួនទេ, តែខ្ញុំមិនចូលចិត្តមនុស្ស ដែលឆ្លៀតឱកាសចូលខាងពួកឈ្នះ ដើម្បីរកប្រយោជន៍អំពីការតស៊ូរបស់អ្នកដទៃ, ខ្ញុំជឿថាអ្នកអានគង់មានសេចក្តីគិតឃើញដូចខ្លួនខ្ញុំដែរ យើងមិនស្អប់ខ្ពើមបច្ចាមិត្រ ដែលវាស៊ូប្រយុទ្ធដរាបដល់ទីបំផុត, យើងត្រឡប់ជាជ្រះថ្លាពេញចិត្តនឹងសេចក្តីក្លាហានរបស់គេ ទោះជាការតស៊ូនោះខុសនឹងផ្លូវច្បាប់ខុសនឹងផ្លូវសីលធម៌ក៏ដោយ, តែយើងខ្ពើមឆ្អើមនឿយណាយចំពោះមនុស្សកំសាកកំសោយ មិនហ៊ានតស៊ូជាមួយជីវិត ឬហេតុការណ៍ ណាៗ ដោយខ្លួនឯង, ដេកចាំតែប្រចុបប្រចែងយកផលប្រយោជន៍អំពីការតស៊ូរបស់ជនដទៃ ។ ខ្ញុំទុកការតស៊ូនោះ ជាគុណធម៌, ជាលទ្ធិ, ជាសាសនាមួយសម្រាប់ខ្លួនខ្ញុំ ។

តែទោះជាយ៉ាងណាក្ដី សូមឲ្យយើងតស៊ូក្នុងផ្លូវធម៌, តស៊ូដើម្បីឧត្ដមការ, ដើម្បីឧត្ដមគតិ, ដើម្បីមនុស្សធម៌, ដើម្បីយុត្តិធម៌ និងដើម្បីចំណុចទីដៅចុងបំផុតនៃសន្តិភាពពិភពលោក ។

បើយើងតស៊ូដើម្បីឧត្ដមគតិល្អ សូម្បីយើងធ្វើអ្វីភ្លាំងភ្លាត់ខុស យើងគង់បានទទួលអភ័យទោសអំពីប្រជាជនក្នុងពិភពលោក ។ អ្នកធ្វើការតស៊ូដើម្បីផលប្រយោជន៍របស់ជាតិ, របស់សាសនា, របស់ព្រះមហាក្សត្រិយ៍នៃខ្លួន, ទោះជាធ្វើទៅហើយមិនបានសម្រេច ដោយមានឧបស័គ្គមករាំងរា ឬ មានគ្រោះថ្នាក់ដល់បាត់បង់ជីវិត គេក៏នៅជាមនុស្សល្អដដែល ។

លក្ខណៈនៃជនព្យាយាមតស៊ូ ហើយបានសម្រេចដូចសេចក្ដីប៉ុនប៉ងដូចមានតទៅនេះ ។

## ១- ធ្វើការអ្វី ធ្វើពិតៗ

អ្នកធ្វើការអ្វី ធ្វើពិតរមែងបានសម្រេចនូវប្រយោជន៍ជាទីពេញចិត្ត, សេចក្តីផ្សេងគ្នានៃជនអ្នកធ្វើការបានសម្រេច និងពុំបានសម្រេចនោះ នៅត្រង់មានសេចក្តីក្លាហានអង់អាច និងពុំមានសេចក្តីអង់អាច ។ មនុស្សយើងមិនអាចធ្វើការបានសម្រេចគ្រប់គ្នា, អ្នកដែលសាងការបានសម្រេចនោះ គឺបុគ្គលមានលក្ខណៈ ផ្សេកពីអ្នកដទៃ, លក្ខណៈផ្សេកនោះ មិនមែនសំដៅយកសេចក្តីវៃឆ្លាត ឬ គំនិតជ្រាលជ្រៅលើសមនុស្សធម្មតាទេ ព្រោះអ្វី ព្រោះថា "សេចក្តីចេះដឹងអាចរៀនទាន់គ្នាបានទាំងអស់, តែលក្ខណៈផ្សេកក្នុងទីនេះសំដៅយកធ្វើការពិតៗ នោះឯង" ។

ខ្ញុំបានអានជីវប្រវត្តិ ជីវ៉ា-ឡេវ៉ា

ដែលមានសេចក្តីថា:

ពេលមួយ,បុរសនោះឈរថ្ងៃងសុន្ទរកថាក្នុងកន្លែងមួយ

ហើយត្រូវគេចាប់ចងយកទៅឃុំឃាំងអស់មួយឆ្នាំ ។ លុះចេញមកអំពីគុកភ្លាម ក៏មកឈរនៅក្នុងទីដែលត្រូវចាប់នោះ ហើយថ្លែងសុន្ទរកថា តអំពីពាក្យដែលបាននិយាយក្នុងពេលដែលត្រូវគេចាប់ ។

លក្ខណៈធ្វើអ្វីធ្វើពិត អាចជួយឲ្យលះបង់នូវរបស់អ្វីដែលគេត្រូវលះបង់ គឺលក្ខណៈនេះ មិនត្រឹមតែឲ្យគេធ្វើការបានពិតៗប៉ុណ្ណោះទេ អាចទាំងឲ្យគេលះបង់នូវការដែលគេមិនត្រូវធ្វើនោះទៀតផង ដូចជា "ហ៊ីតែ្លរ៍" មុស្សូលិនី" មហាត្មគន្ធី" ដឺវ៉ាំ ឡេរ៉ា" បុរសពួកនេះ, តមផឹកស្រាជក់បារី, តមដល់ទៅទឹកតែ - កាហ្វេ - សាច់សត្វ, បរិភោគតែបន្លែជាបុគ្គលមានជីវិតរស់នៅតាមធម្មជាតិពិតៗ ។ ការតមនៃជនពួកនេះ នឹងរាប់ថាជាសេចក្ដីល្អ ឬ មិនល្អស្រេចនឹងអ្នកអានពិចារណាចុះ, តែការដែលគេអាចលះបង់នូវរបស់ដែលជនទាំងពិភពលោកពេញចិត្តនោះ ជាសេចក្ដីធ្វេកមួយ

នៅក្នុងខ្លួនរបស់គេ ។

## ២- Simplicity

ពាក្យថា: Simplicity ប្រែថា "សភាពស្មើៗ, រាបៗ, ឬ ធូរៗ ងាយៗ" សេចក្ដីប្រែនេះមិនសូវចំន័យប៉ុន្មានទេ, ដូច្នេះ សូមអ្នកអានសង្កេតអត្ថន័យរបស់រឿងនេះតាមពាក្យអធិប្បាយរបស់ខ្ញុំ ហើយផ្ចិតយកយោបល់អំពីពាក្យអធិប្បាយនេះផងចុះ ។

បុគ្គលដែលធ្វើការបានសម្រេច ឬ ធ្វើពិភពលោកឲ្យភ្ញាក់ផ្អើលច្រើនប្រកបដោយលក្ខណៈគឺ Simplicity, លក្ខណៈនេះខ្ញុំសង្កេតឃើញតាមរូបថត ហ៊ីត្លែរ័ក្ដី, មូស្សូលិនីក្ដី, ស្តាលីនក្ដី, មានផ្លាស់ប្ដូរគ្រឿងតែងកាយតិចបំផុតស្ទើរតែមិនមានគ្រឿងផ្លាស់ប្ដូរ, ជាពិសេសហ៊ីត្លែរ៍ មិនមានគ្រឿងតែងកាយច្រើនបែបទេ ទោះជាក្នុងពេលធម្មតា ឬ ក្នុងពេលពិធីកម្មយ៉ាងណាៗ ក៏ដោយ សម្លៀកបំពាក់របស់ហ៊ីត្លែរ៍

គង់នៅជាប្រក្រតី, ក្រៅអំពីហ៊ីត្ល៉ែរមាន "ណាប៉ូឡេអុង" មួយរូបទៀត ដែលមានគ្រឿងតែងកាយ គ្រឿងឥស្សរិយ-យសតិចបំផុតដូចហ៊ីត្ល៉ែរដែរ, ទាបជាងនោះទៅទៀតគឺមហាត្មគន្ធី, បុរសនោះស្លៀកពាក់តែងកាយដូចមនុស្សសាមញ្ញទូទៅ, មិនមានគ្រឿងឯកសណ្ឋានយ៉ាងណាមួយឡើយ, សំពត់អាវដែលមហាត្មគន្ធីស្លៀកពាក់នោះ, ជាសំពត់ធម្មតាដែលត្បាញរវៃដោយដៃរបស់ខ្លួន ។

លក្ខណៈដូចនេះ តាមផ្លូវព្រះពុទ្ធសាសនាហៅថាៈ "សន្តុដ្ឋិលក្ខណៈ" គឺ Simplicity នោះឯង ។ ដូចម្តេចមហាបុរសពួកនេះ, ទើបមានលក្ខណៈរាបៗ ស្មើៗ ដូច្នេះ? អ្នកខ្លះចូលចិត្តថា ព្រោះបុគ្គលពួកនេះបានឡើងមកអំពីឋានៈទាបថោក, បានជាមិនចូលចិត្តសេចក្តីថ្លៃថ្នូរ, តែសេចក្តីចូលចិត្តនេះក៏មិនត្រូវដែរ ព្រោះតាមប្រក្រតីមនុស្សដែលឡើងអំពីឋានទាបមកកាន់ឋានខ្ពស់ ដោយគ្រោះជាល្អរបស់អ្នកដទៃ

គឺមិនមែនដោយការតស៊ូរបស់ខ្លួន ច្រើនចូលចិត្តហ៊ឹកហាក់ហ៊ឹហា, ជនដែលមានបានដោយជោគជ័យជួយ, ច្រើនចាយធំ ចូលចិត្តអួតភ្នែកត្រចៀកអ្នកដទៃ តែផ្ទុយទៅវិញ មហាបុរសមិនមានលក្ខណៈអួតអាង ដើរស៊ីចាយប្រើប្រាស់វត្ថុនានា ដូចជនធម្មតាឡើយ ។

បុគ្គលដែលបានកសាងខ្លួន, សាងការសំខាន់ៗ រាល់រូបជាបុគ្គលមានសេចក្ដីសំថៃជានិច្ច ។ ណាប៉ូឡេអុង, មានកេរ្តិ៍ឈ្មោះខាងសន្ដោសសំថៃ ប្រសិនបើប្រៀបទៅជាមួយព្រះមហាក្សត្រិយ៍ផងគ្នា, ក្នុងប្រទេសបារាំងណាប៉ូឡេអុង ជាក្សត្រមានសេចក្ដីសន្ដោសសំថៃ ជាងក្សត្រអង្គណាៗទាំងអស់ ។

Simplicity លក្ខណៈអាចជាសញ្ញាលក័ខ្ខមួយយ៉ាងសំខាន់របស់មនុស្ស ព្រោះជនដែលមានសេចក្ដីសន្ដោសសំថៃ នោះត្រូវជាមនុស្សមានលក្ខណៈរឹងប៉ឹង, ជនដែលមាននិ-

ស្ប៉យទន់ខ្សោយ មិនអាចសន្តោសសំចៃបានឡើយ ។ លក្ខ-ណៈ ដែលហៅថា Simplicity នេះជាលក្ខណៈមួយដែលមនុស្សយើងយកជ័យជម្នះលើខ្លួនឯង គឺសេចក្ដីមិនលោភទ្រព្យសម្បត្តិ, មិនត្រូវការជាឯកអគ្គខ្ពង់ខ្ពស់ក្នុងរបស់គ្រប់បែបគ្រប់យ៉ាង, ព្រមឲ្យកិត្តិយសដល់ជនដទៃច្រើនជាងខ្លួន គិតតែធ្វើសេចក្ដីល្អ មិនត្រូវការកេរ្តិ៍ឈ្មោះ ។ លក្ខណៈដូចនេះជាលក្ខណៈរបស់អ្នកឈ្នះ, អ្នកណាដែលត្រូវការកេរ្តិ៍ឈ្មោះច្រើនជាងសេចក្ដីល្អ ឬ បណ្ដោយចិត្តឲ្យជ្រុលជ្រប់ក្នុងសេចក្ដីប្រាថ្នាប្រយោជន៍ផ្ទាល់ខ្លួន បរាជ័យនឹងមានដល់អ្នកនោះមិនខានឡើយ ។

## ៣- ការមិនខ្លាចបាញ់

អ្នកចិត្តសាស្ត្រច្រើននិយាយថា មនុស្សយើងគិតយ៉ាងណា នឹងបានសម្រេចយ៉ាងនោះ" គឺគិតថាចាញ់ក៏ច្រើនត្រូវចាញ់, បើគិតថាឈ្នះ ក៏ច្រើនត្រូវឈ្នះ, ហេតុផល

របស់អ្នកចិត្តសាស្ត្រក្នុងរឿងនេះក៏នៅក្នុងរឿងកម្លាំងចិត្ត ។ ការដែលល្អបំផុតសម្រាប់ការតស៊ូក្នុងជីវិត គឺយើងត្រូវរកផ្លូវចេញឲ្យបាន, យើងត្រូវធ្វើការយកឈ្នះ, តែយើងកុំគិតតែពីឈ្នះតែម្យ៉ាង យើងត្រូវរៀបចំការពារបរាជ័យឲ្យហើយជាស្រេច ក្រែងលោជួនជាមានឡើងតាមផ្លូវណាមួយ ។ បើយើងរកផ្លូវចេញបានហើយ ទោះណាជាចាញ់ក៏មិនជាអ្វី ។ មានល័ខធម៌ពុទ្ធសាសនាមួយកន្លែង ដែលគេមិនសូវជាយកចិត្តទុកដាក់ណាស់, ដោយគេគិតថាខ្ពស់ហួសពេក មិនសមគួរនឹងស្ថានភាពនៃជីវិតបច្ចុប្បន្ននេះ, ល័ខនោះគឺ: "នេក្ខម្ម:" ប្រែថា "ផ្លូវចេញ" បានដល់ការចេញបួស, ការលះបង់ទ្រព្យសម្បត្តិទាំងអស់, ការបំពេញសីលជារឿងចេញចាកលោក, ជារឿងមិនត្រេកអររីករាយក្នុងសេចក្ដីទាក់ទងជាមួយលោក ។ តែសេចក្ដីពិតរឿង "នេក្ខម្ម:" នេះ យើងអាចនាំមកប្រើក្នុងលោក ក្នុង

ជីវិតបច្ចុប្បន្នរបស់យើងបានដូចគ្នា, គឺយើងនឹងធ្វើអ្វីៗក្តី, យើងត្រូវយកខ្លួនរបស់យើងទៅចងភ្ជាប់ក្នុងនាទី ឬ ក្នុងកិច្ចការមួយដែលយើងបានធ្វើ, យើងត្រូវនឹកដល់ "នេក្ខម្ម:" គឺផ្លូវចេញចាកគ្រោះថ្នាក់ នេះគឺជាសេចក្តីចាំបាច់មួយសម្រាប់ការតស៊ូក្នុងជីវិត ។

៤) Active et Passive

ពាក្យពីរម៉ាត់គឺ: Active និង Passive នេះ ពិបាកប្រែមកជាភាសាខ្មែរឲ្យចំ តែខ្ញុំអាចនឹងអធិប្បាយឲ្យមានសេចក្តីងាយស្តាប់ដូចតទៅនេះ ។

ការតស៊ូ ឬការតទប់បែប active ឬ active resistance នោះមានន័យថា ការតស៊ូបែបបុករុក, តស៊ូដោយខ្លួនឯងជាអ្នកផ្តួចផ្តើមធ្វើឡើង, បើជាចម្បាំងដោយកដល់ការផ្តើមវាយលុក ។ ឯការតស៊ូ ឬ ការតទប់បែប Passive ឬ Passive resistance នោះដោយកដល់ការនៅស្ងៀម ។

ព្រងើយៗ មិនសុខចិត្តស្ដាប់, តែមិនព្រមប្រយុទ្ធតស៊ូដោយកម្លាំងខ្លាំងក្លា ។

ដើម្បីឲ្យអ្នកអានចូលចិត្តងាយ ខ្ញុំសូមលើកឧទាហរណ៍ជូនដូចខាងក្រោមនេះ ៖

រដ្ឋាភិបាលចេញច្បាប់បង្គាប់ឲ្យរាស្ត្រធ្វើការអ្វីមួយ ដែលរាស្ត្រមិនពេញចិត្ត, រាស្ត្រសម្រេចចិត្ត នឹងធ្វើការតស៊ូ ឬ ទប់ទល់ បើជារឿង active resistance បានសេចក្ដីថា រាស្ត្រកសេចក្ដីជ្រួលច្របល់ នាំគ្នាឈប់ធ្វើការ ឬ ក ការចលាចលណាមួយឡើង លុះត្រាតែរដ្ឋាភិបាលញ៉ាមចាញ់, ញ៉ាមកែប្រែច្បាប់នោះ ។ តែបើជារឿង passive resistance ក៏ត្រឹមតែមិនញ៉ាមប្រតិបត្តិតាមច្បាប់ រដ្ឋាភិបាលនឹងយកខ្លួនទៅដាក់គុកច្រវាក់ ក៏ព្រម, ដោយមិនមានការតស៊ូ, តែមិនញ៉ាមប្រតិបត្តិតាមច្បាប់ ។ វិធីនេះ, មហាត្មៈគន្ធី ធ្លាប់ប្រើតទល់នឹងអំណាចអង់គ្លេស ដែលមានឈ្មោះ

ហៅម៉្យាងទៀតថាៈ Non-violence បានសម្រេចផលជាទីពេញចិត្តរបស់ខ្លួនមកហើយ ។

៥-) ការធ្វើសេចក្ដីធ្វែកត្រអាល

ការធ្វើសេចក្ដីធ្វែកចិត្តឲ្យដល់គូតស៊ូ, ជាវិធីសំខាន់បំផុតសម្រាប់យកជ័យជម្នះ, ខាងទាហានដឹងរឿងនេះគ្រប់គ្នាថាបើកាលណាយើងអាចធ្វើឲ្យសត្រូវចម្លែកចិត្ត, ខុសសេចក្ដីស្មានរបស់គេ, ខុសគំនិតរបស់គេគិតទុកជាមុននោះផ្លូវឈ្នះមុខជានឹងបានមកយើងជាមិនខានឡើយ ។

វិធីនេះមិនក្រប៉ុន្មានទេ, គឺថាបើយើងចាំបាច់ត្រូវប្រឈមមុខនឹងសត្រូវ ឬ គូប្រណាំងប្រជែងរបស់យើង, ឲ្យព្យាយាមនឹកមើលជាមុនថា គូសត្រូវ ឬ គូប្រណាំងប្រជែងរបស់យើងនោះ, គេគិតស្មានថាយើងនឹងធ្វើការយ៉ាងណា, គេមានសង្ឃឹមជួបនឹងយើងក្នុងព្រឹត្តិការណ៍យ៉ាងណា, បើយើងយល់ឃើញថា, គេចង់ជួបយើងក្នុងសភាពក្រោធខឹង

ឬ ប្រកាន់ទិដ្ឋិមានៈ យើងក៏ត្រូវទៅជួបនឹងគេក្នុងផ្លូវផ្ទុយទៅវិញគឺជួបគេក្នុងអាការៈស្រស់ស្រាយញញឹមញញែម ឬ ក្នុងអាការៈទន់ភ្លន់, បើគេចង់ជួបនឹងយើងក្នុងសភាពស្ងន់ខ្ចាចអានេមអានុំ យើងក៏ធ្វើឲ្យផ្ទុយទៅវិញ គឺឲ្យគេជួបយើងដោយសភាពក្លាហានរបស់យើង ។ ឥរិយាបថចម្លែកនេះជាផ្លូវនាំឲ្យមានជ័យជម្នះ ព្រោះគូសត្រូវមិនបានត្រៀមខ្លួនគ្រប់គ្រាន់តាមឥរិយាបថរបស់យើង ។

៦-) សេចក្ដីមិនប្រមាទ

ខ្ញុំសូមរំឭកជាថ្មីម្ដងទៀត, ឲ្យអ្នកអានយកចិត្តទុកដាក់ក្នុងពុទ្ធភាសិតនេះព្រោះជាពុទ្ធភាសិតខ្ពង់ខ្ពស់បំផុត សម្រាប់ជីវិតអ្នកតស៊ូគ្រប់ផ្លូវទាំងអស់, ជាពុទ្ធភាសិតជួយខ្លួនយើងបានប្រសិនជាយើងព្រមរស់ នៅជាមួយពុទ្ធភាសិតនេះគ្រប់កាល ។

ពុទ្ធភាសិតនេះខ្ញុំបានសរសេរជាមួយភាសិតដទៃៗ មក

ហើយ, តែខ្ញុំពុំទាន់បានជូនយោបល់របស់ខ្ញុំចំពោះពុទ្ធភាសិតនេះនៅឡើយ ដើម្បីសេចក្តីភ្ញាក់ស្មារតីដល់ជនជាតិយើង ក្នុងឋានៈជាពុទ្ធសាសនិក, ជាពលរដ្ឋ, ជាពលលោក, ខ្ញុំសូមស្រង់យកពុទ្ធភាសិតនោះមកសរសេរក្នុងទីនេះទៀតថា "អប្បមាទោ អមតំ បទំ បមាទោ មច្ចុនោ បទំ ។ ល ។

ប្រែថា "សេចក្តីមិនធ្វេសប្រហែស ជាផ្លូវនាំឲ្យមិនស្លាប់ សេចក្តីធ្វេសប្រហែស ជាផ្លូវនាំឲ្យស្លាប់ ជនមានសេចក្តីធ្វេសប្រហែសទោះណាជារស់នៅ ក៏ទុកដូចជាស្លាប់ទៅហើយ" ។

ពុទ្ធភាសិតនេះមានន័យថា: សេចក្តីមិនធ្វេសប្រហែសនាំឲ្យមនុស្សយើងបានរស់នៅក្នុងលោកនេះ, ក្នុងលោកខាងមុខ, ក្នុងព្រះនិព្វាន, ការណាដែលគេធ្វើដោយសេចក្តីមិនធ្វេសប្រហែស ទោះជាបច្ចុប្បន្នការរង្វាក្តី, ទោះជាអនាគត

ការងារក្តី, ទោះជានិព្វានការងារក្តី, សុទ្ធតែបានសម្រេចផលជាទីពេញចិត្ត ។ ការឯណាដែលគេធ្វើដោយសេចក្តីធ្វេសប្រហែស ទោះជាបច្ចុប្បន្នការងារក្តី, ទោះជាអនាគតការងារក្តី, ទោះជានិព្វានការងារក្តី, សុទ្ធតែមិនបានទទួលផលជាទីពេញចិត្ត ។ សេចក្តីស្លាប់រស់នៃការងារទាំងអស់ ទៅពីបមាទធម៌ និងអប្បមាទធម៌ ។ ជនណារស់នៅក្នុងបមាទធម៌, ជននោះត្រូវស្លាប់ប្រយោជន៍គ្រប់ថ្នាក់ទាំងអស់, ជនណារស់នៅជាមួយអប្បមាទធម៌, ជននោះត្រូវបានប្រយោជន៍គ្រប់ថ្នាក់ទាំងអស់ ។

ដូច្នេះ, ការតស៊ូរបស់អ្នកក្នុងផ្លូវបច្ចុប្បន្នក្តី, ក្នុងផ្លូវបរលោកក្តី, ក្នុងផ្លូវព្រះនិព្វានក្តី, អ្នកត្រូវប្រកាន់យកអប្បមាទធម៌ជាគូតស៊ូ ហើយត្រូវលះបង់បមាទធម៌ដែលជាសត្រូវនឹងការតស៊ូ កុំឲ្យមានសេសសល់ឡើយ ។

ជីវិតមនុស្សមានទុក្ខច្រើន, មិនមានខ្លឹមសារ, ធាប់សឹក

ឆាប់រហ័ស, ជារបស់មិនទៀង, មានការប្រែប្រួលជានិច្ច មានសភាពទន់ជ្រាយ, ធន់ទ្រាំនៅជាមួយធម្មជាតិ, ជាមួយសត្វសាហាវ, ជាមួយហេតុការណ៍អាក្រក់ បានដោយក្រ, តែបើគេចេះប្រើជីវិតទៅក្នុងវិធីតស៊ូល្អ ។ ដូចបានពោលមកហើយនោះជីវិតក៏ប្រែទៅជាមានសភាពសុខស្រួលធូរធោយ នៅក្នុងលោកនេះខ្លះដែរ ។ មិនត្រឹមតែប៉ុណ្ណោះ គេអាចប្រយុទ្ធតស៊ូបាបអកុសលតាមកម្មវិធី នៃព្រះពុទ្ធសាសនាទៅយកព្រះនិព្វានបានទៀតផង, យើងគប្បីដឹងថា: ជីវិតមនុស្សគឺជាការតស៊ូ, លោកមនុស្សជាលោកតស៊ូ, ជីវិតត្រូវចោទដោយល្ងង់, ចេះ, ក្រ, ទ្រព្យ, មានយសស័ក្តិ, មានអំណាចឥតអំណាច, មានសិទ្ធិ, ឥតសិទ្ធិ, មានសេរី, ឥតសេរី ។ ល ។ ជីវិតជាគូប្រណាំងប្រជែង, ប្រណាំងដោយចេះដឹង, ប្រណាំងដោយទ្រព្យសម្បត្តិ ប្រណាំងដោយកេរ្តិ៍ឈ្មោះ ។ ល ។ ដូចនេះ ម្នាក់ៗ ត្រូវព្យាយាមដោះស្រាយបញ្ហាជីវិតទៅ

តាមកម្មវិធីរបស់ជាតិ, របស់សាសនានៃខ្លួន ។ បើអ្នកមិនព្យាយាមដោះស្រាយទេ, ជីវិតអ្នកនឹងបានទទួលផលអាក្រក់ក្នុងលោកដែលគេសម្គាល់ថា ជាវិមានសោយសុខនៃជនអ្នកតស៊ូ, អ្នកធ្វើការ, អ្នកអត់ធន់, អ្នកក្លាហានជាពុំខានឡើយ ។

សូមអ្នកអានចូលមកកាន់កម្មវិធីតស៊ូខាងផ្លូវពុទ្ធសាសនាជាមួយនឹងលោកនេះ, លោកខាងមុខនិងព្រះនិព្វានដូចខ្ញុំរៀបចំជូនទុកតទៅនេះ ។

# ការតស៊ូដើម្បីជីវភាពក្នុងលោកបច្ចុប្បន្ន

អ្នកអានបានដឹងហើយថា: ជីវិតគឺការតស៊ូ, ក្នុងពិភពលោកយើងនេះ, មានប្រជាពលលោកដោយប្រមាណប្រហែលជាជាង ២០០០.០០០.០០០ រស់នៅក្នុងប្រទេសផ្សេងៗគ្នា ។ មនុស្សកាន់តែកើតច្រើន ផែនដីដែលជាកន្លែងមនុស្សនៅកាន់តែរួមតូចមក ដោយរបរអាជីវកម្មដែលគេប្រកបឡើងតាមរបៀបវិទ្យាសាស្រ្តទំនើបថ្មី ទោះជាផែនដីនៅធំដដែលតែឧស្សាហកម្មទំនើប មានគ្រឿងចក្របញ្ចេញផលិតផលជាច្រើន បណ្តាលឲ្យការរស់នៅនៃមនុស្សក្នុងលោកកាន់តែតានតឹងចង្អៀតចង្អល់ឡើង ហើយការតានតឹងនេះច្រើនតែធ្លាក់មកលើជនដែលមានព្យាយាមតិច, មានរបរឧស្សាហកម្មស្តួចស្តើង, ឯជនដែលមានព្យាយាមច្រើន ក៏រឹងរឹតតែបានសេចក្តីសុខច្រើនឡើង ។ មនុស្សត្រូវដណ្តើមប្រជែងគ្នា ដើម្បីរស់នៅឲ្យបានស្រួលរៀងរាល់ខ្លួន ។

ព្រះពុទ្ធបរមគ្រូជាសាស្តាចារ្យឯកមួយព្រះអង្គ ទ្រង់ធ្លាប់មានការពិសោធន៍ច្រើន, ហើយតែងតែមានព្រះទ័យមេត្តាករុណាសត្វលោក, ព្រះអង្គទ្រង់ណែនាំឲ្យមនុស្សគ្រប់គ្នាប្រឹងប្រែងធ្វើការងារ ឲ្យអស់ពីកម្លាំងសមត្ថភាព ដើម្បីរក្សានូវជីវភាពជាប្រក្រតី និងពង្រីកនូវជីវភាពធម្មតាឲ្យខ្ពង់ខ្ពស់ឡើងទៀតដោយសម្បទាបួនយ៉ាងនេះគឺ:

១-) ឧដ្ឋានសម្បទា ដល់ព្រមដោយសេចក្តីខ្នះខ្នែង ។ មនុស្សម្នាក់ៗ ត្រូវមានសេចក្តីព្យាយាមប្រកបកិច្ចការជានិច្ច, កិច្ចការដែលខ្លួនត្រូវប្រកបនោះ ត្រូវហ្វឹកហាត់ខ្លួនឲ្យស្ទាត់ជំនាញ, ឲ្យជាមនុស្សស្ទុះស្ទាសង្វាតឱហាតធ្វើការ, អត់ធន់នឹងការ ក្លាហាននឹងការងារ, ហ៊ានពុះពារសេចក្តីលំបាក, មិនធុញទ្រាន់នឹងការងារធ្ងន់ ។ មិនព្យាយាមធ្វើតែការណាស្រាលស្រណុខ ការទុច្ចរិតផ្សេងៗមានដើរលេងល្បែងភ្នាល់ជាដើម ។ សេចក្តីឧស្សាហ៍ក្នុង

ផ្លូវចិត្ត ដោយយកដល់លក្ខណៈនៃសេចក្ដីធន់ទ្រាំរបស់ចិត្ត ដែលមិនញ៉ើមចុះចាញ់, មិនញ៉ើមរាថយក្រោយចំពោះសេចក្ដី លំបាក, ចំពោះសេចក្ដីមិនសមតាមបំណង, ចំពោះការប្រមាថមើលងាយចំអកឡកឡឺយ, ចំពោះសេចក្ដីណាយទ្រាន់ ចំពោះសេចក្ដីជោគជាំឈ្លីឈ្លក់នឹងឧបសគ្គទាំងឡាយ ដែល ចូលមកជ្រែកសេចក្ដីឧស្សាហ៍ នេះហើយគឺជាលក្ខណៈរបស់ មនុស្សចិត្តរឹងប៉ឹង, ក្លាហាន, ដាច់ខាត ។

ខ្ញុំសូមឲ្យឧទាហរណ៍ ដូចយើងត្រូវរៀនវិជ្ជាណាមួយ ឲ្យបានសម្រេចផល ប្រឡងជាប់ដល់ថ្នាក់បរិញ្ញា, យើង ត្រូវមានចិត្តរឹងប៉ឹង, ក្លាហានដាច់ខាត, អានសៀវភៅ ដោយមិនឈប់ឈរ អានហើយអានទៀត មើលតម្រាក្បួនខ្នាតដែលស្ដែងអំពីវិជ្ជានោះៗ ឲ្យចប់សព្វគ្រប់ កាល ណាមិនទាន់ចាំ ត្រូវមើលទៀតឲ្យទាល់តែចាំបាន នឹក ឃើញបានយ៉ាងស្ទាត់ជំនាញ, ត្រូវអត់ធន់សេចក្ដីលំបាក

ដែលកើតអំពីការអន្តយសរសេរ, អន្តយអានសៀវភៅយូរៗ ត្រូវធន់ទ្រាំសេចក្ដីងងុយ, ការចុកស្រពន់រួយដៃជើង, ការក្ដៅត្រជាក់, ត្រូវអត់ទ្រាំលះបង់សេចក្ដីសប្បាយ ក្នុងការដើរលេងកំសាន្តជាមួយពួកមិត្រ ។ ទោះជាអាកាសត្រជាក់ ក៏ត្រូវក្រោកឡើងមើលសៀវភៅ ទៅសាលារៀន, បើសិនជាដល់វេលា ទោះជាមេឃកំពុងធ្លាក់ភ្លៀង អាកាសកំពុងក្ដៅ ក៏ត្រូវតែត្រឡប់មកលំនៅដើមរបស់ខ្លួនវិញ, លុះដល់វេលាប្រឡងធ្លាក់ ឬ អស់ដើមទុនរៀនទៀត ក៏មិនត្រូវលះបង់ការសិក្សាព្យាយាមរកលុយកាក់រៀនសូត្រ ដរាបដល់ប្រឡងជាប់ថ្ងៃណាមួយ ។

ពុទ្ធភាសិត បានពោលដល់សេចក្ដីឧស្សាហ៍ក្នុងការងារក្នុងអាជីវកម្មថា: **“វីរិយេន ទុក្ខមច្ចេតិ”** គេរួចចាកទុក្ខបានព្រោះសេចក្ដីព្យាយាម ។ **“ឧដ្ឋាតា វិន្ទតេ ធនំ”** អ្នកស្ទុះស្ទាព្យាយាមរមែងរកទ្រព្យបាន ។

"វាយមេថេវ បុរិសោ យាវ អត្ថស្ស និប្ប-ត្តិ" ជាបុរសជាស្ត្រីគប្បីព្យាយាមធ្វើការលុះត្រាតែបានសម្រេចប្រយោជន៍ ។

២) អារក្ខសម្បទា ដល់ព្រមដោយការរក្សា គឺរក្សាផលប្រយោជន៍របស់ខ្លួនដែលរកបានមកហើយ មិនឲ្យបាត់បង់ខូចខាតទៅវិញ ជាចំណេះវិជ្ជាក្តី, ជាទ្រព្យសម្បត្តិក្តី, ជាតំណែងការងារក្តី, ដែលជាវត្ថុជាតុសម្រាប់ធ្វើឲ្យខ្លួនបានសេចក្តីសុខ ។ ត្រូវរក្សាខ្លួនមិនឲ្យមានរោគភ័យវិ-បត្តិអន្តរាយនានា ទាំងខាងក្នុង ខាងក្រៅ, រក្សាសុខភាព អនាម័យរបស់ខ្លួនឲ្យតាំងនៅជាប្រក្រតី, កាលណាបរិភោគអាហារឲ្យដឹងប្រមាណច្រើន តិច, ដឹងថាអាហារណាមានប្រយោជន៍, អាហារណាមិនមានប្រយោជន៍ ដើម្បីទំនុកបម្រុងរូបកាយរបស់ខ្លួនឲ្យមានសមត្ថភាពក្នុងការងារ ។ ជាជនមានសេចក្តីព្យាយាមរក្សាថែទាំទ្រព្យសម្បត្តិ, តំណែងការ

ងារ, វិជ្ជាចំណេះត្រឹមត្រូវតាមក្បួនតម្រា, របស់ណាដែលបាត់បង់ព្យាយាមរកឲ្យឃើញមកវិញ ដែលទ្រុឌទ្រោមបាក់បែកដាច់រហែកព្យាយាមជួសជុល ដេរប៉ះផ្សារភ្ជិតឲ្យល្អឡើងវិញ, ស្គាល់ប្រមាណក្នុងការចាយវាយទ្រព្យសម្បត្តិ, មិនប្រគល់ទ្រព្យសម្បត្តិឲ្យមនុស្សគ្មានសីលធម៌ទុកដាក់ ។

៣) **កល្យាណមិត្តតា** ភាពជាជនមានសេចក្តីរាប់អានល្អនូវជនមានសីលមានធម៌មានចិត្តសប្បុរស មានខ្លួនតាំងនៅក្នុងសច្ចធម៌ ក្នុងកតញ្ញូកតវេទិតាធម៌ ។ មិនមានសេចក្តីស្អប់ខ្ពើមនូវជនមិនមានសីលធម៌, មិនមានមនុស្សធម៌, មានខ្លួនមិនតម្កល់នៅក្នុងសច្ចធម៌, ក្នុងកតញ្ញូកតវេ-ទិតាធម៌តែក៏មិនសម្តែងសេចក្តីស្និទ្ធស្នាលរាប់អានយកជាភៀនបន មុនដែលរកមធ្យោបាយអប់រំឲ្យមនុស្សនោះប្រែជាមានសីលធម៌, មនុស្សធម៌, មានចិត្តស្មោះត្រង់, មានខ្លួនតម្កល់នៅក្នុងសច្ចធម៌, ក្នុងកតញ្ញូកតវេទិតាធម៌ ។ ភាព

ជាបុគ្គលចេះសាងមនុស្សល្អឲ្យរឹងរឹតតែល្អឡើង ដោយមានគំនិតនៅក្នុងឧត្តមគតិថា: ការរស់នៅម្នាក់ឯងពុំមានភៀនបនក៏ពុំមានកម្លាំងការពារគ្រោះថ្នាក់ ដែលកើតអំពីធម្មជាតិ ឬ អំពីសត្វសាហាវ ឬ អំពីហេតុការណ៍ ប្រែប្រួលមានសង្គ្រាមជាដើម ។ តែការនៅជាមួយមនុស្សអាក្រក់រមែងមានសេចក្ដីទុក្ខគ្រប់កាល ដែលល្អបំផុតគឺធ្វើឲ្យមនុស្សទាំងអស់ក្នុងសង្គមមានចរិយាមារយាទល្អ ហើយយកជាមិត្រទាំងអស់គ្នា ទើបការពារសន្តិសុខបាន ។

(៤) **សមជីវិតា** ភាពជាបុគ្គលរស់នៅស្មើៗ គឺបើមានទ្រព្យសម្បត្តិច្រើន ចាយវាយប្រើប្រាស់តិច, បើមានទ្រព្យសម្បត្តិតិច ចាយវាយឲ្យតិចចុះមកទៀត ឲ្យល្មមតែរស់នៅបាន ដើម្បីធ្វើការបម្រើជីវិតខ្លួន, ជីវិតគ្រួសារ ជីវិតប្រទេសជាតិ ។ ជាបុគ្គលនៅក្នុងឧត្តមគតិថា: “រស់នៅត្រឹមតែរស់” មិនរស់នៅហ៊ឺកហ៊ាក់ហ៊ឺហាពេកចុះក្នុងតម្រា

ថា "ជាអ្នកស៊ីចាយខ្ជះខ្ជាយស្វែងរកសេចក្ដីសប្បាយឥតប្រ-យោជន៍" ឬ ចុះក្នុងតម្រាថា: "ជាអ្នកស៊ីចាយថាំពេកនាំឲ្យរូបកាយមានសុខភាពមិនល្អ" ។ ជាជនចេះចាយវាយទ្រព្យសម្បត្តិឲ្យមានប្រយោជន៍ដល់ខ្លួន, ដល់គ្រួសាររបស់ខ្លួន, ដល់ប្រទេសជាតិនៃខ្លួន ។

សម្បទាទាំង ៤ យ៉ាងនេះ ជាសម្បទាសម្រាប់ប្រយុទ្ធតស៊ូដណ្ដើមយកវិជ្ជាចំណេះ ទ្រព្យសម្បត្តិតំណែងការងារ ។ ល ។ សម្រាប់រក្សាស្ងួនគ្រងនូវចំណេះវិជ្ជា, ទ្រព្យ-សម្បត្តិ, តំណែងការងារ ។ ល ។ សម្រាប់រួបរួមមនុស្សក្នុងសង្គមឲ្យបានជាមិត្រល្អ, មានសីលធម៌, មនុស្សធម៌ ។ ល ។ សម្រាប់រៀបចំជីវភាពឲ្យមានសុខភាពល្អ, អនាម័យល្អ ។ ល ។

កាលណាគេបានតស៊ូតាមសម្បទា ៤ យ៉ាងនេះ គេនឹងបានសម្រេចប្រយោជន៍ក្នុងបច្ចុប្បន្ន មានជីវភាពថ្លៃថ្នូរ

ប្រកបព្រមដោយសេចក្ដីសុខចម្រើន ជាជំនួយឲ្យជីវិតមានកម្លាំងមានពន្លឺ ឈានឡើងទៅកាន់ប្រយោជន៍ជាន់កណ្ដាលបាន ។

អ្នកអានបានដឹងហើយថា ជីវិតជាគូតស៊ូ, ជាគូប្រ-ណាំងប្រជែងដណ្ដើមរស់, ដណ្ដើមអំណាច, ដណ្ដើមកេរ្តិ៍ឈ្មោះ ។ល។ ឲ្យបានខ្ពង់ខ្ពស់ជាងគ្នា ការដណ្ដើមប្រជែងនេះ, មិនមែនមានតែក្នុងលោកនេះទេ សូម្បីដំណើរទៅកាន់បរលោកក៏មានការដណ្ដើមប្រជែងយកអំណាច យកតំណែង, យកកេរ្តិ៍ឈ្មោះ ។ល។ ដូចគ្នាដែរ ។

ក្នុងលោកយើងនេះមានមនុស្សសម្បូណ៌ទ្រព្យ, ខ្វះទ្រព្យ, មានបញ្ញា, ឥតបញ្ញា, មានយសស័ក្តិ, ឥតយសស័ក្តិ, មានអំណាច, ឥតអំណាច, មានត្រកូលទាបខ្ពស់, មានយសស័ក្តិតូច, មានយសស័ក្តិធំ ។ល។ ក្នុងលោកដទៃក៏មានតំណែងនាទីធំតូចជាងគ្នាជាអាទិ៍គឺៈ មានព្រះឥន្ទ្រ,

ព្រះព្រហ្ម, ទេវតា, រុក្ខទេវតា, ភូម្មដ្ឋទេវតា ។ ល ។ តំ-ណែងទាំងអស់នេះសុទ្ធតែបានមកអំពីការតស៊ូ ដណ្ដើមប្រ-ជែងដោយបុណ្យកុសលដោយការងារ, ជនណាប្រយុទ្ធឈ្នះគេ គឺបានធ្វើការច្រើន ឬ ធ្វើបុណ្យកុសលច្រើន ជននោះបានទទួលតំណែងខ្ពស់, ជនណាប្រយុទ្ធចាញ់គេ គឺធ្វើការតិចជាងគេ ឬ ធ្វើបុណ្យកុសលតិចជាងគេ ឬ មានស-កម្មប្រយុទ្ធមិនត្រឹមត្រូវតាមកម្មវិធីសាសនា ឬ កម្មវិធីរបស់ជាតិ, ជននោះបានទទួលតំណែងតូចទាប ។ ឯជនមិនមានការតស៊ូ នឹងធ្លាក់ខ្លួនទៅជាខ្ញុំគេ ឬ ទៅជាមនុស្សបម្រើគេយកថ្លៃឈ្នួលតាមតែគេឲ្យ, អំណោយនេះបានត្រឹមតែធ្វើខ្លួនឲ្យរស់ តែពុំមានសេចក្ដីថ្លៃថ្នូរឡើយ ។

ព្រះពុទ្ធបរមគ្រូ ទ្រង់យល់ឃើញថា: ជីវិតជាគូតស៊ូទាំងលោកនេះនឹងលោកខាងមុខ, ដូច្នេះហើយបានជាទ្រង់សម្ដែងនូវសម្បទាបរលោក ៤ យ៉ាងសម្រាប់អ្នកតស៊ូទៅយកតំណែងក្នុងអនាគតជាតិ ។

---

# ការតស៊ូដើម្បីជីវភាពបរលោក

១-) **សទ្ធាសម្បទា** បំពេញជំនឿឲ្យមានក្នុងខ្លួនថា: មនុស្សលោក បានទទួលតំណែងខ្ពស់ទាបជាងគ្នា ឬ មានភ័ព្វវាសនាច្រើនតិចជាងគ្នាទៅអំពីកម្ម គឺការងារដែលខ្លួនធ្វើច្រើនតិច មិនមែនមកអំពីជំនួយរបស់ទេវតារបស់ព្រះជាម្ចាស់សួគ៌ តែទេវតានិងព្រះជាម្ចាស់សួគ៌ តែងតែជួយសង្គ្រោះមនុស្សអ្នកតស៊ូ អ្នកធ្វើការដោយត្រឹមត្រូវនុ៎ះឯង ។

២-) **សីលសម្បទា** បំពេញសីលគឺធ្វើខ្លួនឲ្យមានចរិយាមារយាទល្អវៀរចាក ការជិះជាន់បៀតបៀនអ្នកដទៃដោយប្រើកម្លាំងណាមួយមានកម្លាំងយសស័ក្តិជាដើម ។

៣-) **ចាគសម្បទា** ការបំពេញទានគឺចាយទ្រព្យបូជា, សាង, សង្គ្រោះ, ដូចជាបូជាមាតាបិតា, សាងបុណ្យកុសល សង្គ្រោះអ្នកក្រក្សត់ ។

(៤-) **បញ្ញាសម្បទា** បំពេញបញ្ញាគឺពិចារណារកហេតុខុសត្រូវ, ស្តាប់ច្រើន, រៀនច្រើន, ភាវនាធម៌ដែលត្រូវភាវនាមានកម្មដ្ឋាននិងវិបស្សនាជាដើម ។

ការប្រកួតប្រណាំង ដើម្បីរស់នៅក្នុងបច្ចុប្បន្នដោយសិក្សាចំណេះវិជ្ជា, ដោយស្វែងរកទ្រព្យសម្បត្តិ ។ ល ។ គូប្រកួតប្រណាំងត្រូវចៀសវាងឲ្យផុតអំពីការជិះជាន់ សង្កត់សង្កិនអ្នកដទៃ ហើយឲ្យខ្លួនបានរស់នៅដោយថ្លៃថ្នូរ គឺប្រឹងប្រែងធ្វើការងារដោយខ្លួនឯង ឲ្យអស់អំពីកម្លាំងកាយកម្លាំងចិត្តនិងកម្លាំងបញ្ញាយ៉ាងណា, ការប្រកួតប្រណាំងដើម្បីរស់នៅក្នុងបរលោកដោយបំពេញបុណ្យកុសល ក៏ត្រូវចៀសវាងឲ្យផុតអំពីការជិះជាន់សង្កត់សង្កិនអ្នកដទៃ យ៉ាងនោះដែរ។ អ្នកសាងបុណ្យកុសលត្រូវនៅក្នុងឧត្តមគតិថា: "បុណ្យកុសលជាអំពើល្អ, ជាសភាពស្អាតបរិសុទ្ធ, ជាធម៌សម្រាប់ដុះលាងចិត្តវិញ្ញាណឲ្យបានស្អាត ឲ្យហ្មត់ចត់ផូរផង់, កាលណាចិត្ត

ស្អាតបរិសុទ្ធ និងមានសុគតិប្រព្រឹត្តទៅក្នុងខាងមុខ ដូច្នេះ បុណ្យកុសលនេះ អ្នកណាគេមិនធ្វើ ខ្លួនអញត្រូវធ្វើ គេធ្វើដោយយឺតយូរ អញធ្វើឲ្យបានឆាប់រហ័ស ធ្វើឲ្យបានមុនគេ ធ្វើដោយមិនចាំបាច់មានអ្នកដឹកនាំ ធ្វើដោយពេញចិត្ត ធ្វើដោយសេចក្ដីវៃឆ្លាត ដោយសំអាងយកច្បាប់ព្រះពុទ្ធសាសនាជាគោលគំនិត ។ ការធ្វើបុណ្យកុសលជាអំពើសម្រេចអំពីចិត្ត មានចិត្តជាសភាពផ្ដួចផ្ដើម មានចិត្តជាសភាពខាត់រំលីង ឲ្យថ្លាស្អាត ចិត្តស្អាត ចិត្តភ្លឺ ប្រាសចាកមន្ទិល ប្រាសចាកងងឹតជាចិត្តគួរដល់បុណ្យកុសល ។

អ្នកធ្វើបុណ្យកុសល ត្រូវសំរាំងចិត្តទៅលើបុណ្យកុសលមិនគប្បីសំរាំងទៅក្នុងកេរ្តិ៍ឈ្មោះ ទៅក្នុងការអួតល្អទៅក្នុងការយកមុខមាត់ ព្រោះថាសេចក្ដីល្អដែលខ្លួនអ្នកបានដឹងជាប្រាកដ ទោះជាមិនមានអ្នកណាប្រោសប្រាណក៏គង់ព្រះពុទ្ធណាមួយ ព្រះអង្គនឹងប្រោសប្រាណជាមិនខាន ។

កាលណាអ្នកបានធ្វើបុណ្យកុសលក្នុងឧត្តមគតិ ដូចបានពោលមក នេះអ្នកបានកប់ប្រសព្វវាសនាខ្ពង់ខ្ពស់ក្នុងអនាគតជាពុំខានឡើយ ។

អ្នកអានបានជួបការតស៊ូដើម្បីរស់នៅក្នុងលោកបច្ចុប្បន្ន និងលោកអនាគតមកហើយ តែមនុស្សនៅមានការតស៊ូមួយទៀតដែលជាការតស៊ូធំបំផុត គឺការប្រយុទ្ធនឹងកងទ័ពចាស់ឈឺ ស្លាប់ ដែលមានអវិជ្ជានិងតណ្ហាជាមេដឹកនាំ ការតស៊ូនេះហៅថាការតស៊ូខាងក្នុង ឬ ហៅថាចម្បាំងក្នុងខ្លួនឯងក៏បានគឺច្បាំងនឹងសេចក្តីល្ងង់ សេចក្តីលោភ សេចក្តីក្រោធ សេចក្តីសប្បាយបោកប្រាស សេចក្តីសប្បាយបន្ទំ កាលណាគេច្បាំងឈ្នះសេចក្តីសៅហ្មងរបស់ខ្លួន គេនឹងឈ្នះសេចក្តីព្រាត់ប្រាសឈ្នះលោកដែលជាទីលំនៅនៃទុក្ខគ្រប់ជាន់ ហើយគេនឹងបានសម្រេចនូវព្រះនិព្វាន ។

# ការតស៊ូដើម្បីជីវភាពក្នុងព្រះនិព្វាន

*ដើម្បីឲ្យបានសម្រេចនូវជីវភាពព្រះនិព្វាន ពុទ្ធសាសនាបានដឹកនាំឲ្យតស៊ូដោយបរមត្ថសម្បទា ៤ យ៉ាងគឺ៖*

១) **ទុក្ខ** *សិក្សាឲ្យស្គាល់នូវសេចក្ដីទុក្ខ ហើយកំណត់ថាជាទុក្ខ ។*

២) **សមុទយ** *សិក្សាឲ្យស្គាល់នូវមូលហេតុឲ្យកើតសេចក្ដីទុក្ខហើយលះបង់នូវមូលហេតុនៃសេចក្ដីទុក្ខ ។*

៣) **និរោធ** *សិក្សាឲ្យស្គាល់នូវព្រះនិព្វាន ហើយធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។*

៤) **មគ្គ** *សិក្សាឲ្យស្គាល់ផ្លូវទៅព្រះនិព្វាន ហើយដើរទៅតាមផ្លូវដែលត្រង់ចំពោះព្រះនិព្វាន ។*

*ពាក្យថា "ទុក្ខ" ដោយកសេចក្ដីកើត ចាស់ ឈឺ ស្លាប់ ដែលជាសភាពមាននៅគ្រប់មនុស្ស សត្វ គ្រប់ធម្មជាតិ ជាសភាពមិនមានសេចក្ដីខ្ជាប់ខ្ជួន មិនតាំងនៅក្នុងដំណាក់មួយៗ*

មានសេចក្តីប្រែប្រួលអំពីសភាពមួយទៅសភាពមួយ បន្ត បន្ទាប់គ្នា នាំឲ្យមនុស្សសត្វនិងធម្មជាតិទ្រាំទ្រនៅមិនបាន ។

ពាក្យថា "សមុទយ" ដោយកចលនាចង់កើត ចង់សប្បាយ ចង់ធំ ចង់សូន្យ របស់មនុស្ស របស់សត្វ របស់ធម្មជាតិ ។

ពាក្យថា "និរោធ" ដោយកព្រះនិព្វានដែលជាគុណធម៌ មិនមាននៅក្នុងលោកណាមួយ តែមាននៅជាមួយនឹងលោក ដែលអស់បុណ្យបាប ។

ពាក្យថា "មគ្គ" ដោយកផ្លូវ៨ប្រការគឺ សម្មាទិដ្ឋិ សម្មាសង្កប្ប សម្មាវាចា សម្មាកម្មន្ត សម្មាអាជីវ សម្មាវាយាម សម្មាសតិ សម្មាសមាធិ ជាផ្លូវទៅកាន់ព្រះនិព្វាន ។

ព្រះនិព្វានជាគុណធម៌ ដែលមនុស្សត្រូវស្គាល់ បើមិនស្គាល់ច្បាស់នូវព្រះនិព្វាន ក៏រមែងមិនស្គាល់នូវបញ្ហាជីវិត ព្រោះព្រះពុទ្ធសាសនាបាននិយាយ អំពីរឿងជីវិតយ៉ាងត្រឹម

ត្រូវតាមសេចក្តីពិត ព្រះនិញ្វានជាទីបំផុតនៃជីវិតជាទីបំផុតរបស់ព្រះពុទ្ធសាសនា បើមិនសិក្សាឲ្យដល់ទីបំផុតក៏មិនអាចនឹងធ្វើជីវិត ឲ្យដល់ទីបរមសុខបានឡើយ ។ ដូច្នេះអ្នកតស៊ូគ្រប់រូប ត្រូវសិក្សាអំពីព្រះនិញ្វានឲ្យច្រើន ដើម្បីដឹកនាំខ្លួនទៅកាន់ទីដៅចុងបំផុតនៃព្រះពុទ្ធសាសនា ដែលជាទីរាប់អាននៃយើងទាំងអស់គ្នាកុំខាន ។ ដើម្បីឲ្យសៀវភៅនេះមានទំព័រតិចល្មម សមគួរដល់កម្លាំងទុន អ្នកបាត់ការបោះពុម្ព ខ្ញុំសូមបញ្ចប់នូវការតស៊ូក្នុងជីវិតអនាគតនិងព្រះនិញ្វាន ។ អ្នកសិក្សាគប្បីតាមមើលបញ្ហាអនាគត និងបញ្ហាព្រះនិញ្វានក្នុងគម្ពីរព្រះត្រៃបិដក និងសៀវភៅនានាដែលលោកអ្នកប្រាជ្ញបានសរសេរហើយផងចុះ ។ ក្នុងវគ្គនៃសៀវភៅនេះ ខ្ញុំសូមអញ្ជើញអ្នកអានមើលជាថ្មីទៀតនូវបញ្ហារស់ក្នុងបច្ចុប្បន្ន ដែលជាបញ្ហាមាននៅចំពោះមុខយើង ហើយជាបញ្ហា មានការចាំបាច់ត្រូវដោះស្រាយជា

បន្ទាន់ ដើម្បីកែទម្រង់ជីវភាពនៃជនជាតិយើងឲ្យមានល្បឿន

ទាន់នានាជាតិ ។

# ការតស៊ូក្នុងនាទី

នាទីជាការមួយដែលអ្នករស់នៅ ក្នុងលោកនេះ ត្រូវស្គាល់ ត្រូវប្រព្រឹត្តឲ្យបានម៉ត់ចត់ ជនម្នាក់ៗ បើមិនស្គាល់នាទី មិនប្រព្រឹត្តតាមនាទីដោយទៀងទាត់ ក៏មិនអាចនឹងធ្វើជីវិតរបស់ខ្លួនឲ្យរស់នៅដោយថ្លៃថ្នូរ ប្រកបដោយសេចក្ដីសុខស្ងប់បានឡើយ ។ ពាក្យថា "នាទី" ដោយកករណីយកិច្ចដែលអ្នកផងត្រូវធ្វើ ត្រូវកាន់ ត្រូវប្រព្រឹត្តជាគូនឹងពាក្យមួយទៀតហៅថា សិទ្ធិ ដែលមានន័យថា "សម្រេចការ ឬសម្រេចផល" ។

# នាទីពលរដ្ឋ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រខ្មែរ ដែលព្រះរាជទានដោយព្រះករុណាជាម្ចាស់ជីវិត ឲ្យប្រជាជនមានសិទ្ធិនៅក្នុង

ក្របខណ្ឌនៃច្បាប់ បានដល់សេរីភាពក្នុងការសិក្សាវិជ្ជានានា ។ល។ រដ្ឋធម្មនុញ្ញជាច្បាប់ខ្ពង់ខ្ពស់ជាងច្បាប់ដទៃៗទាំងអស់ អ្នកណាក៏មិនអាចទម្លាយនូវសេរីភាព ដែលរដ្ឋធម្មនុញ្ញនេះប្រគល់ឲ្យប្រជាជន ប្រសិនណាបើបានទទួលសេចក្តីរំលោភជិះជាន់សេរីភាពរបស់ខ្លួនអំពីជនណាមួយ ខ្លួនអ្នកមានសិទ្ធិចោទប្រកាន់អ្នករំលោកទៅតុលាការរដ្ឋ សូមឲ្យប្រើអំណាចរដ្ឋធម្មនុញ្ញនោះៗ បញ្ឈប់នូវអំពើល្មើសដែលជននោះបានប្រព្រឹត្ត ។ តែពលរដ្ឋម្នាក់ៗ ត្រូវចេះប្រើសិទ្ធិរបស់ខ្លួននៅក្នុងព្រំដែននៃច្បាប់ ត្រូវស្គាល់នាទីរបស់ខ្លួនច្បាស់មុននឹងធ្វើការគ្រប់យ៉ាង ឲ្យរលឹកដល់នាទីជានិច្ច ។ រដ្ឋបានឲ្យសិទ្ធិដល់ប្រជាជន ប្រជាជនត្រូវប្រតិបត្តិនាទីស្នងរដ្ឋវិញគឺ៖

១-ជាពលរដ្ឋមាននាទីត្រូវការពារប្រទេសជាតិ

២-ជាពលរដ្ឋមាននាទីត្រូវបង់ពន្ធអាករ

៣-ជាពលរដ្ឋមាននាទីត្រូវគោរពច្បាប់

៤-ជាពលរដ្ឋមាននាទីត្រូវសិក្សាវិជ្ជានានា

៥-ជាពលរដ្ឋមាននាទីត្រូវរក្សាទុករបបគ្រប់គ្រងរដ្ឋតាមរដ្ឋធម្មនុញ្ញ

៦-ជាពលរដ្ឋមាននាទីត្រូវជួយទំនុកបម្រុងរាជការ

៧-ជាពលរដ្ឋមាននាទីត្រូវប្រើសិទ្ធិបោះឆ្នោតរើសតំណាងរាស្ត្រ សិទ្ធិធ្វើបេក្ខជន សិទ្ធិធ្វើប្រជាមតិ ដោយសេចក្តីសុចរិត ដោយសម្លឹងឃើញប្រយោជន៍របស់ជាតិ ។ល។

ក្នុងនាទីទាំងអស់នេះ ខ្ញុំសូមបញ្ជាក់តែនាទី ទី២ ដែលថាត្រូវបង់ពន្ធអាករ ប្រទេសជាតិយើងរស់នៅបានចម្រើនរុងរឿងទៅកើត ព្រោះមានព្រះរាជរដ្ឋាភិបាលគ្រប់គ្រងរក្សាការគ្រប់គ្រងនោះ ត្រូវចាយប្រាក់ជួលកម្មករធ្វើការរាជការខ្លះចាយក្នុងការកសាងសាធារណប្រយោជន៍ខ្លះ ស្រេចហើយតែព្រះរាជរដ្ឋាភិបាលយល់ឃើញថាធ្វើឡើង ឲ្យបានសេចក្តីសុខចម្រើនដល់ជាតិទាំងមូល ប្រាក់ដែលព្រះរាជរដ្ឋាភិបាល

យកមកចាយវាយនោះបានមកអំពីពន្ធអាករ ដែលប្រជារាស្ត្រ បានបង់អំពីជំនួញ ដែលព្រះរាជរដ្ឋាភិបាលបានធ្វើ ។ល។ កាលណាយើងដឹងថា ប្រាក់ពន្ធអាករ ដែលព្រះរាជរដ្ឋា-ភិបាលបានទៅអំពីប្រជាពលរដ្ឋ យកទៅចាត់ចែងការរបស់ជាតិ ឲ្យប្រជាជនបានរស់នៅជាសុខ យើងជាពលរដ្ឋគ្រប់គ្នាមាននាទីត្រូវបង់ពន្ធអាករ តាមបញ្ញត្តិច្បាប់ដើម្បីឲ្យព្រះរាជរដ្ឋាភិបាលមានប្រាក់គ្រប់គ្រាន់ យកទៅទំនុកបម្រុងជាតិ គឺទំនុកបម្រុងយើងនោះឯង ។ អំពើនេះពលរដ្ឋត្រូវធ្វើដោយចាំបាច់ខានមិនបាន ព្រោះព្រះពុទ្ធសាសនា ក៏មានរំលឹកឲ្យពុទ្ធសាសនិកគ្រប់រូបធ្វើពលិកម្មដល់រដ្ឋ ឬ ធ្វើពលិកម្មដល់ព្រះមហាក្សត្រ ដែលហៅថា រាជពលី ។

ពលរដ្ឋក្នុងប្រទេសខ្មែរយើង នៅប្រទាំក្នុងរឿងប្រើសិទ្ធិនិងនាទី ដោយមានអ្នកខ្លះយល់ថា ប្រទេសយើងបានឯករាជ្យហើយ ព្រះករុណាជាម្ចាស់ជីវិតលើត្បូងបានព្រះរាជទានរដ្ឋធម្ម

នុញ្ញឲ្យប្រជាជនមានសិទ្ធិស្មើគ្នា ដូច្នេះអញនឹងធ្វើអ្វីក៏បាន មិនធ្វើអ្វីក៏បាន ស្រេចហើយតែនឹងចិត្តរបស់អញ ។ សេចក្ដីយល់ឃើញនេះពុំត្រូវទេ ព្រោះសិទ្ធិនិងនាទី គេត្រូវប្រើនៅក្នុងព្រំដែននៃវដ្ដធម្មនុញ្ញ គឺជនម្នាក់ៗមាននាទីធ្វើតាមច្បាប់តែមានសិទ្ធិបោះឆ្នោតរើសតំណាងរាស្ដ្រ មានសិទ្ធិសិក្សាវិជ្ជា តែមាននាទីបង់ពន្ធអាករ ។ ការប្រើសិទ្ធិនិងនាទីនេះត្រូវលៃលកប្រើឲ្យនៅក្នុងក្របខណ្ឌនៃច្បាប់ នៅក្នុងព្រំដែននៃសិទ្ធិនិងនាទីនោះឯង ។ ធ្វើដូច្នេះទើបប្រទេសជាតិមានវឌ្ឍនធម៌រុងរឿងមានអារ្យធម៌ខ្ពង់ខ្ពស់ទៅបាន ។

## នាទីសីលធម៌

ជនម្នាក់ៗត្រូវស្គាល់អំពើល្អ ចរិយាល្អ គឺមានចិត្តមេត្តាករុណា ជួយទំនុកបម្រុងជនដទៃ ជួយសម្រាលទុក្ខមនុស្សចាស់

ជរា មិនប្រព្រឹត្តខុសច្បាប់រដ្ឋ មិនប្រព្រឹត្តនូវអំពើដែលនាំឲ្យអ្នកដទៃស្អប់ មិនឃើញប្រយោជន៍របស់ខ្លួនច្រើនជាងប្រយោជន៍សង្គម មិនលើកតម្កើងខ្លួនឯង ដាក់បន្ទាបអ្នកឯទៀត មានវាចាសុភាពរៀបរយ មានខ្លួនទន់ភ្លន់ មានសេចក្តីគោរពជនដទៃ មានខ្លួននៅក្នុងសីល មានធម៌នៅក្នុងចិត្ត ជនមានសភាពដូច្នេះហៅថាអ្នកមានសីលធម៌ឬមានចរិយាល្អ សភាពជននេះ បើធ្វើដំណើរតាមរថយន្ត រថភ្លើង នាវា ។ល។ គេមិនដណ្តើមដើងឡើងចុះ គេចុះឡើងតាមលំដាប់មុនក្រោយ វេលានៅក្នុងយន្តយានពាហនៈ បើមិនមានកន្លែងអង្គុយ គេមិនឈរប្រជែងប្រជាងឲ្យទើសទែងអ្នកដទៃ បើមានកន្លែងអង្គុយគេចេះរៀបអង្គុយឲ្យមានរបៀបរៀបរយ មិនឲ្យទង្គិចទង្គុកអ្នកដទៃ បើកន្លែងអង្គុយមានមិនគ្រាន់ល្មម គេចេះក្រោកឈរឲ្យកន្លែងទៅអ្នកមានរាងកាយទន់ខ្សោយអង្គុយ គឺក្មេងតូចៗ

មនុស្សចាស់ជរា មនុស្សមានជំងឺ ស្ត្រីភេទ ។ល។ គេចេះជួយលែលកឲ្យបុគ្គលពួកនេះបានឡើងស្រួល អង្គុយស្រួល ចុះទៅវិញស្រួល ។

បើជាអ្នកបើកបររថយន្ត រថភ្លើង នាវា ។ល។ គេចេះបើកបរឲ្យមានសភាពរៀបរយ មានសម្បជញ្ញៈជាប់ជានិច្ចថាខ្លួនអញជាអ្នកដឹកនាំអ្នកដំណើរឲ្យបានដល់ទៅទីកន្លែង ដោយមិនមានគ្រោះថ្នាក់ ដូច្នេះអញនឹងមិនបើកបរលឿនពេកវេលាចតឬចេញមិនប្រញាប់ប្រញាល់ពេក ចេញចតក្នុងពេលដែលអ្នកដំណើរឡើងចុះហើយ ។ បើជាអ្នកយកថ្លៃឈ្នួលអ្នកដំណើរ ត្រូវពោលវាចាសុភាពរាបសាទៅរកអ្នកដំណើរ ។

អ្នកមានសីលធម៌ គេមិនជក់បារីក្នុងរថយន្ត រថភ្លើង ទូក នាវា ។ល។ ដែលមានអ្នកដំណើរជិះណែនណាន់តាន់តាប់ តែបើអត់ទ្រាំមិនបាន គេសូមអនុញ្ញាតអំពីអ្នកអង្គុយជិតជាមុនទើបជក់ ក្នុងពេលបរិភោគអាហាររួមគ្នា អ្នកមានសីលធម៌គេ

ទទួលទានស្អាតរៀបរយ មិនធ្វើមាត់បូញបាញ មិនចោលឆ្អឹងក្នុងទីផ្តេសផ្តាស មិនទំពាអាហារឮចុបចាប់ៗ មិនហុតទឹកសម្លឲ្យឮសូរគ្រូកគ្រាក មិនខ្ជាក់ខាកអាហារ ឬញើសស្ទើស្ទើសម្បោរក្នុងពេលបរិភោគ បើមានការចាំបាច់គេក្រោកទៅខាកខ្ជាក់ក្នុងទីដទៃ គេមិននិយាយគ្នាខ្ទាំងៗក្នុងពេលកំពុងបរិភោគ នាំឲ្យអ្នកដទៃរំខាន គេមិននិយាយវាចាជ្រោកជ្រាកទៅរកអ្នកបម្រើ គេមិនផឹកស្រាឲ្យស្រវឹងជ្រុលបាត់ស្មារតីធម្មតារបស់ខ្លួន គេមិនចូកចាក់សមស្វាបព្រោឲ្យឮធឹងធាំង គេមិនអង្គុយលើកជើងដាក់លើកៅអី ឬតុ គេមិនប្រើសំលៀកបំពាក់ឥតរបៀបរៀបរយ ។ល។

អ្នកមានសីលធម៌ វេលាចូលទៅមើលមហោស្រព បើជាកន្លែងកណ្តាលវាល គេមិនជ្រៀតជ្រែកចូលទៅឈរបាំងមុខអ្នកដទៃដែលគេឈរមុនខ្លួន បើមើលមហោស្រពតាមរោង គេចូលទៅទិញសំបុត្រតាមលំដាប់មុនក្រោយ វេលាឆ្លងកាត់ទ្វារ

គេចូលតាមលំដាប់អ្នកមកមុនមកក្រោយ គេអង្គុយក្នុងកន្លែងដែលគេចាត់ចែងទទួលតាមជាន់ថ្នាក់តម្លៃសំបុត្រ វេលាអង្គុយគេមិនស្ដែងកិរិយាដោយប្រវាចារចេបរចប កាលបើមិនពេញចិត្ត គេក៏មិនសម្ដែងកាយវិការងាកចុះងាកឡើងនាំឲ្យរំខានអ្នកដទៃ បើគាប់ចិត្តគេសើចត្រឹមបន្តិចៗនិងទះដៃផ្សំតាមសមគួរ ។ ការបញ្ចេញសំឡេងឡូឡា ការបញ្ចាំងពិល ឬផ្ទុំអ្វីៗ ក្នុងទីនោះរាប់ថាជាមារយាទមិនល្អ អ្នកមានសីលធម៌ គេរមែងមិនប្រព្រឹត្តអាកប្បកិរិយាដូចពោលមកនេះឡើយ ។

អ្នកមានសីលធម៌ វេលាចូលទៅកាន់ទីប្រជុំ មានប្រជុំស្ដាប់បាឋកថាជាដើម គេរៀបចំស្លៀកពាក់តែងកាយឲ្យសុភាពតាមសម័យនិយម បើជាពិធីកម្មមានកិត្តិយស គេពាក់អាវជាន់ក្រៅថែមទៅលើអាវជាន់ក្នុង ហើយពាក់ស្រោមជើងផង ពេលនៅក្នុងទីប្រជុំគេសង្រួមសំងំមាត់ បើមានការចាំបាច់គេនិយាយតិចៗ គេមិនធ្វើឲ្យមានសំឡេងអ្វីលាន់ឮឡើង បើ

ពេញចិត្តគេទះដៃឲ្យកិត្តិយស បើមិនពេញចិត្តគេអង្គុយស្ងៀមស្ងាត់ គេមិនសម្តែងអាការៈក្រោកចេញទៅព្រងើយៗ បើមានការចាំបាច់នឹងចេញទៅមុនពេលបិទប្រជុំ គេក្រោកឡើងស្តែងអាការៈសូមអភ័យអំពីអ្នកសម្តែង ឬប្រធានទីប្រជុំដោយការសំពះឬគំនាប់ហើយ ទើបដើរចេញទៅយ៉ាងស្ងៀមស្ងាត់ បើក្នុងទីនោះមានហាមមិនឲ្យជក់បារី គេក៏ប្រព្រឹត្តតាមយ៉ាងទៀងទាត់ ។

អ្នកមានសីលធម៌ វេលាចូលទៅក្នុងកន្លែងគោរពបូជាបានដល់ព្រះវិហាររបស់សាសនានានា សាលាយុត្តិធម៌ដែលមានចៅក្រមកំពុងវិនិច្ឆ័យសេចក្តី ទីស្តីការរដ្ឋាភិបាល ព្រះរាជវាំងជាទីគង់ប្រថាប់ព្រះមហាក្សត្រ មន្ទីរវុឌ្ឍិសភា មន្ទីររដ្ឋសភា មន្ទីរសភាប្រជារាស្ត្រ វត្តអារាមគ្រប់សាសនា គេចូលទៅដោយអាកប្បកិរិយាគោរពលំអុតលំអោន ចំពោះបូជនីយដ្ឋាននោះៗ ។ បើចូលព្រះវិហារខ្មែរ គេបើកមួក ដោះស្បែកជើង

ជាមុន បើវិហារកាតូលិកគេមិនដោះស្បែកជើង តែគេដោះមួក គេមិនឈរ ឬ ដើរក្រពាត់ដៃ បើខ្លួនគេមិនមែនជាបរិស័ទសាសនាមុយស៊ុលម៉ង់ គេមិនចូលទៅក្នុងវិហារនៃសាសនានោះ វេលាចូលទៅក្នុងវិហារសាសនាទាំងអស់ គេមិនយកដៃស្ទាបអង្អែលវត្ថុនានា ឬ ថតរូបក្នុងវិហារនោះ លើកលែងតែអ្នកថែរក្សាអនុញ្ញាតឲ្យចាប់កាន់ឬឲ្យថតរូប ទើបគេធ្វើតាមសេចក្ដីអនុញ្ញាតនោះ ។

ក្នុងបរិវេណវត្តគេមិនពាក់មួក មិនសម្ដែងអាការៈគ្មានគារវៈគោរពដូចជាបញ្ចោញសំលេងគឹកកង ឈ្លោះប្រកែកលោតឡើងលេងលើព្រះចេតិយ បេះផ្លែឈើ បេះផ្កាឈើ កាច់ស្លឹកឈើ ត្រួយឈើ ដែលគេរៀបចំដាំលម្អអារាម ។

អ្នកមានសីលធម៌ វេលាទៅក្នុងពិធីមង្គល បានដល់មង្គលអាពាហ៍ពិពាហ៍ មង្គលឧបសម្បទជាភិក្ខុ មង្គលសម្ពោធឆ្លងព្រះពុទ្ធរូប ព្រះចេតិយ ព្រះស្តូប ធម្មមន្ទីរ វិហារ ។ល។ គេ

តែងកាយឲ្យស្អាតបាតសមរម្យល្អ គេប្រយ័ត្នមិនឲ្យមានទាស់ពាក្យសម្តីវិវាទឆ្លើយឆ្លងគ្នា គេមិនយករឿងមិនល្អមកនិយាយ គេសម្តែងអាការៈជ្រះថ្លារីករាយ ធ្វើមុខមាត់ឲ្យមានសម្រស់ គ្រឿងប្រដាប់តែងកាយក្តី គ្រឿងប្រដាប់ប្រើប្រាស់ក្តី គេប្រើពណ៌សម្បុរ ដែលសង្គមនិយមថាជាពណ៌មង្គល មានពណ៌ផ្ទៃជម្ពូជាដើម គេស្គាល់កិត្តិយសនៃពិធីមង្គលដែលគេចាត់ចែងឡើង មានថ្នាក់ជាន់យ៉ាងណាគេក៏រៀបចំខ្លួនប្រាណឲ្យមានកិត្តិយស ដល់ការមង្គលនោះៗ ។

អ្នកមានសីលធម៌ វេលាទៅក្នុងពិធីសង្វេគក្រៀមក្រំដូចពិធីបុណ្យសព ពិធីរំលឹកគុណដល់បុព្វបុរសដែលអស់ជីវិតទៅ ក្នុងពិធីសម្តែងនៅក្នុងសេចក្តីទុក្ខអាល័យ គេមិនសម្តែងកិរិយារីករាយក្អាកក្អាយ គេស្លៀកពាក់តែងកាយដោយមិនប្រើសំពត់ពណ៌ខ្ចីស្រស់ឆើតឆាយពេក គ្រឿងប្រដាប់ប្រើប្រាស់ ដែលយកទៅជាមួយខ្លួន គេរៀបចំទូវរបស់ហ៊ឹក

ហ៊ាក់ហ៊ឺហា, ជាពិសេសបុណ្យបូជាសព, គេជួយកាន់ទុក្ខ, បុរសពាក់អាវជាន់ក្រៅ ចងក្រវាត់ពណ៌ខ្មៅ, នៅដៃខាងឆ្វេងគេខ្ទាស់ភ្ជាប់ដោយកំណាត់សំពត់ មានពណ៌ខ្មៅដែលសម្គាល់ថាជាពណ៌កាន់ទុក្ខ, ស្ត្រីស្លៀកពាក់ខ្មៅ, កាន់ក្របូបពណ៌ខ្មៅ, គេមិននិយាយសម្តីត្លុកកំប្លែង, គេមិននិន្ទាអ្នកស្លាប់ ឬនិយាយពាក្យមិនល្អ ជាពាក្យស្ញែងចិត្តគ្រួសារអ្នកស្លាប់, គេធ្វើខ្លួនគេឲ្យជាភ្ញៀវមានឧត្តមគតិខ្ពង់ខ្ពស់ក្នុងដំណើរ ដែលមកជួយសម្រាលទុក្ខនៃគ្រួសាររបស់អ្នកស្លាប់ ។

## ក្នុងនាទីរួមរស់ក្នុងបច្ចុប្បន្ន

ព្រះពុទ្ធសាសនា មានធម៌មួយដែលត្រូវនាំយកមកប្រើក្នុងការរួមរស់ជាមួយគ្នាឈ្មោះថា **"សង្គហវត្ថុ"** មាន ៤ យ៉ាងគឺ :

១) **ទានៈ** បានដល់ការបែងចាន់ទ្រព្យសម្បត្តិឲ្យដល់មនុស្សគួរឲ្យ, គួរបូជា, គួរសង្គ្រោះ

២) **បិយវាចា** បានដល់ការនិយាយពាក្យពិរោះទន់ភ្លន់, មិននិយាយកុហក មិនជេរប្រទេច, មិនញុះញង់, មិននិយាយផ្ដេសផ្ដាស,

៣) **អត្ថចរិយា** បានដល់ការប្រព្រឹត្តអំពើការឲ្យជាប្រយោជន៍ដល់ខ្លួន, គ្រួសាររបស់ខ្លួន, ជាតិរបស់ខ្លួន និង នានាជាតិ,

៤) **សមានត្តតា** បានដល់សភាពនៃជន ដែលមានខ្លួនស្មើៗ មិនប្រកាន់ខ្លួន, មិនអាងជាតិ, ទ្រព្យសម្បត្តិ ។ល។

ពាក្យថា "សង្គហវត្ថុ" ប្រែថា "វត្ថុជាគ្រឿងសង្គ្រោះដល់គ្នានិងគ្នា, វត្ថុជាគ្រឿងចងមិត្រ, វត្ថុជាគ្រឿងរួមរស់ រួមប្រាស្រ័យទាក់ទងការងារ" ។ **ទានៈ**

ចែកជាពីរ, ការឲ្យចំពោះបុគ្គលម្នាក់ៗ ដែលខ្លួនស្រឡាញ់ពេញចិត្តហៅថា "បុគ្គលិកទាន", ការឲ្យដោយសង្គ្រោះ ឬសាធារណប្រយោជន៍ ដល់មនុស្សទូទៅ មិនចំពោះជាតិ, ត្រកូល, វណ្ណៈ, ពណ៌សម្បុរ, លទ្ធិសាសនា ។ ល ។ ហៅថា "**ធម្មទាន**" ឬ "**សម្បុរិសទាន**" ជាទានដែលគេឲ្យតាមធម៌, តាមចិត្តសប្បុរស ។ **បិយវាចា** ចែកជាពីរ, វាចាដែលគេនិយាយពិរោះប្រាសចាកវចីទុច្ចរិតបួន ហៅថា "**បិយវាចា**", វាចាដែលគេនិយាយឲ្យបានផលប្រយោជន៍ដល់មនុស្សទូទៅ ហៅថា "**អត្ថសញ្ហិតា វាចា**" ។ អត្ថចរិយា ចែកជាពីរគឺ, ការជួយខ្វល់ខ្វាយ កិច្ចការរបស់អ្នកដទៃឲ្យបានសម្រេចហៅថា "**វេយ្យាវច្ច**", ការដឹកនាំអ្នកដទៃឲ្យប្រព្រឹត្តធម៌ មានឲ្យធ្វើបុណ្យទានជាដើមហៅថា "**ធម្មសមាទបនា**" ។ **សមានត្តតា** ចែកជាពីរ គឺ:

ខ្លួនយើងមានអំណាច, មានស័ក្តិយសធំ, មានទ្រព្យ-សម្បត្តិច្រើន ក៏មិនប្រកាន់ខ្លួនប្រាណ, កាលអំពីដើមធ្លាប់រាប់អានជនដទៃយ៉ាងណា ក៏នៅសម្តែងសេចក្តីរាប់អានគោរពយ៉ាងនោះដដែលហៅថា "បុគ្គលាធិដ្ឋាន" ។ យើងកើតមកជាមនុស្សមានរូបកាយដូចគ្នា, មានចិត្តវិញ្ញាណដូចគ្នា, ខ្លះជាអ្នកសិក្សា, ខ្លះជាអ្នកបួស, មានសាលារៀនជាមួយគ្នា, មានវត្តនៅរួមគ្នា, ទុកដាក់ខ្លួនស្មើៗគ្នា, មិនប្រកាន់ថាខ្លួនខ្ពស់, អ្នកដទៃទាប, ឲ្យខុសអំពីប្រពៃណី, ពួកគណៈ ឬធម្មជាតិនិយម, ហៅថា "ធម្មាធិដ្ឋាន" ។ កាលណាគេព្រមរស់នៅជាមួយគ្នាដោយសង្គហធម៌ទាំង ៤ នេះគេនឹងមានសាមគ្គីរាប់អានស្រឡាញ់គ្នា, នៅគ្រប់គ្រួសារគ្រប់លទ្ធិ, គ្រប់សាសនា, គ្រប់វណ្ណៈ, គ្រប់ពណ៌សម្បុរគ្រប់ជាតិ, ប្រជាពលលោកនឹងអាចរស់នៅដោយសុខសាន្ត, ពិភពលោកនឹងអស់សង្គ្រាម, សន្តិភាពនឹងឋិតថេរនៅក្នុង

លោកអស់កាលមិនមានទីបំផុត, តែបើគេរួមរស់នៅក្នុងសង្គ-ហធម៌នេះបានតែត្រឹមគ្រួសារមួយ, ជាតិមួយ, លទ្ធិមួយ សាសនាមួយ ។ ល ។ គេក៏បានសេចក្ដីសុខសាន្តតែក្នុងគ្រួសារមួយៗ, ជាតិមួយៗ, សាសនាមួយៗ ។ ល ។ តែប៉ុណ្ណោះ, ហើយសេចក្ដីសុខសាន្តនេះក៏មិនសូវទៀងទាត់ប៉ុន្មានឡើយ ព្រោះថាការរួមរស់នៅជាមួយគ្នា ដែលយើងធ្លាប់ហៅថាសាមគ្គីតាមឧត្ដមគតិព្រះពុទ្ធសាសនានោះ មានន័យធំទូលាយជាងសេចក្ដីសាមគ្គីដែលជាតិមួយៗ, លទ្ធិមួយៗ,សាសនាមួយៗ, បានបង្កើតឡើង ។

ដើម្បីឲ្យអ្នកអានបានយល់ នូវសេចក្ដីសាមគ្គីតាមគតិនៃព្រះពុទ្ធសាសនា, ខ្ញុំសូមបំភ្លឺអ្នកអានដោយភាសិតថា:

"សុខោ ពុទ្ធានមុប្បាទោ
សុខា សទ្ធម្មទេសនា
សុខា សង្ឃស្ស សាមគ្គី

សមគ្គានំ តបោ សុខោ”

ប្រែថា “ការកើតឡើងនៃព្រះពុទ្ធទាំងឡាយ នាំមកនូវសេចក្តីសុខ, ការសម្តែងចេញនូវធម៌សប្បុរស នាំមកនូវសេចក្តីសុខ, សេចក្តីព្រមព្រៀងគ្នានៃពួកមនុស្សនាំមកនូវសេចក្តីសុខ, អំណាចនៃសេចក្តីព្រមព្រៀងគ្នា នៃមនុស្សទាំងឡាយនាំមកនូវសេចក្តីសុខ” ។ ភាសិតនេះបញ្ជាក់ឲ្យឃើញថា ព្រះពុទ្ធ ព្រះអង្គទ្រង់កើតឡើងនាំមកនូវសេចក្តីសុខ គឺថាព្រះពុទ្ធទាំងអស់អង្គ ពុំបានអាងជាតិត្រកូល, អំណាចស័ក្តិយស, គោត្រ សៃ ដែលមនុស្សលោកគេធ្លាប់អាង, ធ្លាប់ប្រកាន់យកមកធ្វើជាគ្រឿងជិះជាន់សង្កត់សង្កិននូវមនុស្សគ្នាឯង, ព្រះអង្គបានលះបង់នូវជាតិដើម្បីជាតិមនុស្សទាំងអស់, បានលះបង់អំណាចយសស័ក្តិដើម្បីបម្រើនូវអ្នកមានអំណាចយសស័ក្តិទាំងអស់ ។ល។ ព្រះអង្គទ្រង់កើតមកស្រោចស្រង់មនុស្សលោក, មកធ្វើជាមិត្រនឹងមនុស្សជាតិ

គ្រប់វណ្ណៈពណ៌សម្បុរ ។ ល ។ ដូច្នេះឃើញថា មិនមានសេចក្ដីទុក្ខឯណា ដែលកើតមកអំពីព្រះពុទ្ធទៀតទេ ។ បើព្រះពុទ្ធជាបុគ្គលនាំមកនូវសេចក្ដីសុខ ដល់មនុស្សលោក, ការសម្ដែងចេញនូវធម៌សប្បុរសគឺធម៌ព្រះពុទ្ធ ក៏សម្ដែងឡើងដើម្បីឲ្យមនុស្សលោកបានសេចក្ដីសុខ បើធម៌ព្រះពុទ្ធសម្ដែងឡើង ដើម្បីឲ្យមនុស្សលោកបានសេចក្ដីសុខទាំងអស់គ្នា, ការព្រមព្រៀងគ្នានៃពួកមនុស្ស ក៏គឺការព្រមព្រៀងគ្នាគ្រប់ជាតិទាំងអស់ទើបនាំមកនូវសេចក្ដីសុខ, ក្នុងទីបំផុតអំណាចនៃសេចក្ដីសាមគ្គីរបស់មនុស្សលោកនឹងនាំមកនូវសេចក្ដីសុខជាស្ថាពរនៅក្នុងពិភពលោក ។

អ្នកអានបានដឹងហើយថា សង្គ្រាមមួយៗ, ទោះជាសង្គ្រាមក្នុងជាតិ, សង្គ្រាមអន្តរជាតិ ឬសង្គ្រាមលោករមែងកើតមកអំពីការបែកបាក់សាមគ្គីរបស់ជាតិ, របស់អន្តរជាតិ ឬរបស់ពិភពលោក ។ កាលណាជាតិមួយព្រមព្រៀង

គ្នា, ជាតិមួយទៀតក៏ព្រមព្រៀងគ្នា, សេចក្ដីព្រមព្រៀងដោយឡែកអំពីគ្នានេះហើយ ដែលកទៅជាកម្លាំងនៃចម្បាំង ។ ដូច្នេះពលរដ្ឋខ្មែរយើង ត្រូវធ្វើសេចក្ដីសាមគ្គីព្រមព្រៀងគ្នាឲ្យបានយ៉ាងតិចបំផុតត្រឹមសាមគ្គីរួមជាតិរបស់យើង បើមិនដល់ទៅសាមគ្គីជាមួយជាតិដទៃ, តែប្រសិនណាបើអាចធ្វើសាមគ្គីជាមួយជាតិទូទៅក្នុងពិភពលោកនេះបាន ជាការល្អបំផុតហើយសមតាមឧត្ដមគតិ របស់ព្រះពុទ្ធសាសនាយើង, ដែលព្រះពុទ្ធបរមគ្រូ ទ្រង់ដឹកនាំឲ្យមនុស្សសាមគ្គីរួបរួមគ្រប់ជាតិ, ព្រះអង្គទ្រង់ប្រដៅមិនឲ្យមនុស្សយកជាតិ, យកគោត្រ-សៃ, វណ្ណៈ, ពណ៌សម្បុរ ។ ល ។ មកប្រើជាគ្រឿងជិះជាន់សង្កត់សង្កិនបណ្ដាលឲ្យមានការឈ្លោះប្រកែកគ្នារហូតដល់មានសង្គ្រាមក្នុងជាតិមួយៗ ឬក្នុងអន្តរជាតិសោះឡើយ។ ព្រះអង្គទ្រង់ណែនាំឲ្យជាតិធំសង្គ្រោះជាតិតូច, អ្នកមានទ្រព្យសង្គ្រោះអ្នកក្រទ្រព្យ, អ្នកមានគោត្រ-សៃខ្ពស់ សង្គ្រោះ

អ្នកមានគោត្រ-សែទាប ដូចពុទ្ធភាសិតថា

"ជនណារឹងរូសដោយជាតិ, រឹងរូសដោយទ្រព្យ, រឹងរូសដោយគោត្រ-សែ, មើលងាយជនឯទៀតដោយអាង ជាតិទ្រព្យ, គោត្រ-សែ, ជននោះនឹងត្រូវបានសេចក្តីវិនាស" ។ នៅក្នុងព្រហ្មវិហារធម៌, ព្រះអង្គទ្រង់ដាស់តឿនមនុស្សឲ្យចម្រើនចំពោះខ្លួនឯង, ចំពោះមនុស្សម្នាក់ ៗ ដែលខ្លួនស្រឡាញ់, ចំពោះមនុស្សម្នាក់ៗ ដែលខ្លួនស្អប់ គឺឲ្យបណ្តុះចិត្តឲ្យមេត្តាករុណាខ្លួនឯងជាមុន ខ្លួនអ្នកឯទៀត ជាបន្តបន្ទាប់គ្នារហូតដល់ទីបំផុត ទ្រង់ឲ្យផ្សាយមេត្តាចិត្តដល់សត្វទាំងអស់ មនុស្សទាំងអស់ ដែលមាននៅគ្រប់ទិសទាំងដប់ គឺគ្រប់ពិភពលោក គ្រប់ចក្រវាឡនានា ដែលមានមនុស្ស មានសត្វនៅអាស្រ័យ ។

ដូច្នេះខ្លួនយើងម្នាក់ៗ គប្បីរៀនរស់នៅជាមួយគ្នាឲ្យបានតាំងអំពីរស់នៅក្នុងគ្រួសារមួយៗ រហូតដល់ជាតិទាំង

មូល, លោកទាំងមូល, ដោយប្រកាន់ខ្ជាប់នូវនាទីរបស់-ខ្លួន គឺនាទីជាមាតាបិតា នាទីជាបុត្រធីតា នាទីជាស្វាមីភរិ-យា នាទីជាមិត្រសម្លាញ់ នាទីជាគ្រូសិស្ស នាទីជាបព្វជិតគ្រហស្ថ នាទីជាមន្ត្រីរាស្ត្រ ។ ល ។ គឺបើខ្លួនអ្នកជាប្តីរបស់ស្ត្រីណា ត្រូវសង្គ្រោះរាប់អានស្ត្រីនោះ ដោយរៀបចំឲ្យមានសម្លៀកបំពាក់, គ្រឿងតែងកាយ, គ្រឿងសម្អាង, ឲ្យសិទ្ធិពេញទីជាស្ត្រីមេផ្ទះ, ជាស្ត្រីថែទាំទុកដាក់ទ្រព្យសម្បត្តិជាគូស្នេហាយ៉ាងស្មោះអស់ពីពោះ, មិនប្រព្រឹត្តក្បត់ចិត្ត, ក្បត់នាទីជាប្តី យកសេចក្តីស្នេហារបស់ខ្លួនទៅឲ្យស្ត្រីឯទៀតដែលមិនមែនជាភរិយា, ត្រូវមានសម្បជញ្ញៈនៅក្នុងនាទីជាប្តីរបស់គេដោយពិតប្រាកដ ។ ឯភរិយាវិញក៏ត្រូវកាន់ខ្ជាប់នូវនាទីរបស់ខ្លួន ថាជាប្រពន្ធរបស់គេដោយព្យាយាមធ្វើការផ្ទះ មានការចម្អិនអាហារ, ការបោសប្រាស, ការទទួលភ្ញៀវរបស់ស្វាមី, ការទុកដាក់ទ្រព្យសម្បត្តិមិនឲ្យបាត់បង់,

មិនប្រព្រឹត្តក្បត់ចិត្តស្វាមី, ក្បត់នាទីរបស់ខ្លួនយកសេចក្ដីស្នេ-
ហាទៅបូជាបុរសដទៃ ។ កាលណាខ្លួនអ្នកបានធ្វើការតាមនា-
ទីទៀងទាត់ដូច្នេះហើយ, ជីវិតរបស់អ្នកនឹងបានសេចក្ដីសុខ
ក្សេមក្សាន្តនៅក្នុងលោកនេះ, លោកនេះក៏ទៅជាសួគ៌នៃជីវិត
របស់អ្នក, កាលណាអ្នកធ្វើការតាមនាទីនេះពុំបានទេ, ជី-
វិតរបស់អ្នក នឹងមានសេចក្ដីទុក្ខក្ដៅក្រហាយអស់កាលជានិច្ច
នៅក្នុងលោកនេះ ។ លោកនេះក៏ទៅជានរកនៃជីវិតរបស់
អ្នក, អ្នកកុំគិតថា បើអាត្មាអញមានសេចក្ដីស្នេហា មិន
ប្រកបដោយសេចក្ដីសុខក្នុងជីវិតនេះ គង់តែនឹងបានសេចក្ដី
សុខ ដោយសេចក្ដីស្នេហានៅក្នុងសួគ៌វិមាននៃលោកខាង
មុខព្រោះថាសេចក្ដីស្នេហា ដែលខ្លួនអ្នករកបានមកហើយអ្នក
មិនចេះប្រើសេចក្ដីស្នេហានោះឲ្យទៅជាសួគ៌របស់ជីវិត, អ្នក
បែរជាធ្វើឲ្យសេចក្ដីស្នេហាក្លាយទៅជានរក របស់ជីវិតហើយ
គិតលះបង់ ស្នេហាបច្ចុប្បន្ននេះចោល ហើយទៅយក

ប្រពន្ធ យកប្តីក្នុងឋានសួគ៌នោះពុំបានសោះឡើយ ។

ខ្ញុំបាននិយាយអំពីនាទីរបស់ស្វាមី និងរបស់ភរិយាមកជាបែបយ៉ាងត្រឹមប៉ុណ្ណេះ ។ ឯនាទីឯទៀតក្រៅពីនេះក៏មានសេចក្តីស្រដៀងគ្នានឹងនាទីនេះដែរ ។ នាទីទាំងអស់នោះមាននៅក្នុងសៀវភៅនានា ដែលលោកអ្នកប្រាជ្ញបាននិពន្ធមកហើយ សូមអញ្ជើញរកយកមកអាន ហើយប្រតិបត្តិនាទីនោះៗ គ្រប់គ្នាដើម្បីសេចក្តីសុខចម្រើន ក្នុងជាតិនេះជាតិខាងមុខនិងបច្ឆិមជាតិ គឺជាតិជាទីបំផុត ដែលត្រូវបានសម្រេចនូវមគ្គផលនិព្វាននោះឯង ។

ដើម្បីឲ្យអ្នកអានមានពន្លឺខាងផ្លូវគំនិត ក្នុងការដោះស្រាយបញ្ហាជីវិតរបស់ខ្លួនឲ្យបានល្អប្រពៃ ប្រកបដោយកេរ្តិ៍ឈ្មោះថ្លៃថ្នូរក្នុងមុខងាររបស់ខ្លួនគ្រប់ពេលវេលា ។ ខ្ញុំសូមស្រង់យកប្រវត្តិនៃបុគ្គលខ្លះ ដែលគេបានដោះស្រាយបញ្ហាជីវិតរបស់គេ មកសរសេរបន្ថែមក្នុងគ្រាបោះពុម្ពលើកទីពីរ

នៃសៀវភៅនេះ សម្រាប់អ្នកអានពិចារណា ។ តែការយកតម្រាប់តាម ឬ មិនយកនោះ ស្រេចហើយលើការវិនិច្ឆ័យរបស់អ្នកអានចុះ ព្រោះជីវប្បវត្តិនៃមនុស្សក្នុងពិភពលោកយើងនេះ មិនមែនមានសុទ្ធតែសេចក្ដីល្អមិនមានសេចក្ដីអាក្រក់ទេ គឺមានអាក្រក់មានល្អលាយគ្នា តិចខ្លះច្រើនខ្លះតាមរឿងរ៉ាវរបស់ខ្លួននៃមនុស្សម្នាក់ៗ ដោយអាស្រ័យហេតុនេះ ទើបក្នុងទំព័រប្រវត្តិសាស្ត្រ ខាងផ្លូវនយោបាយក្ដី ខាងផ្លូវសាសនាក្ដី ខាងផ្លូវសេដ្ឋកិច្ចក្ដី ។ ល ។ គេបានឃើញរឿងរបស់មនុស្សអាក្រក់, មនុស្សល្អនៅជាប់ជាមួយគ្នា ដូចព្រះពុទ្ធបរមគ្រូ និង ទេវទត្ត, ឡេនីន និងហ៊ីត្លែរ (ល) នេះគឺជាសេចក្ដីប្រាថ្នារបស់អ្នកចងរឿង ចង់ឲ្យយើងឃើញសេចក្ដីប្រព្រឹត្តរបស់មនុស្សអាក្រក់, មនុស្សល្អព្រមគ្នា ហើយនៅខាងចុងបំផុតនៃចរិយាអាក្រក់ល្អ របស់មនុស្សនោះ, អ្នកចងរឿងទាំងឡាយពុំសូវដែលបានភ្លេច

ណែនាំ ឬ ដាស់តឿនស្មារតីរបស់យើង កុំឲ្យត្រាប់មនុស្ស អាក្រក់ ឲ្យត្រាប់តែមនុស្សល្អឲ្យជ្រើសរើសយកតែកិរិយាល្អ របស់មនុស្សមកប្រព្រឹត្ត កុំយកកិរិយាអាក្រក់របស់មនុស្ស មកប្រព្រឹត្ត ព្រោះហេតុអ្វី? ព្រោះហេតុថា មនុស្សម្នាក់ៗ មានទាំងសេចក្តីអាក្រក់សេចក្តីល្អលាយគ្នា ។ ដូច្នេះអ្នក អានទាំងឡាយសូមមេត្តាអានប្រវត្តិរបស់បុគ្គលទាំងឡាយនេះ ហើយសូមធ្វើនូវសេចក្តីចូលចិត្ត តាមសេចក្តីយល់ឃើញ របស់ខ្លួនដោយសេរីចុះ ។

## ត្លយ៉ាងជីវិតគស្ស

ការសិក្សារឿងជីវិត គឺជាការសិក្សាអំពីរឿងរបស់ម-នុស្ស ។ ដូច្នេះ ចំណុចសំខាន់សម្រាប់សិក្សា ក៏គឺ រឿងដែលមនុស្សម្នាក់បានបង្កើតឡើង ឬ រឿងដែលមាន

នៅក្នុងខ្លួនរបស់មនុស្ស ។ ការសិក្សាអំពីបញ្ហាជីវិតខាងផ្លូវតស៊ូ, យើងចាំបាច់ត្រូវសិក្សាចាកជីវិតដែលគេតស៊ូមកឲ្យយើងមើលជាតួយ៉ាង, ការសិក្សាអំពីជីវិតតួយ៉ាងនេះ ឲ្យផលល្អដល់យើង ២ ប្រការ ។ ប្រការ ១ គឺយើងរៀនយកបែបយ៉ាងរបស់គេ ឲ្យដឹងថា គេធ្លាប់តស៊ូមកយ៉ាងណា? វិធីតស៊ូនោះបានផលល្អអាក្រក់យ៉ាងម៉េច? ជាសិទ្ធ បានសម្រេច ឬ ពុំបានសម្រេច? ជាសិទ្ធ បានទទួលបរាជ័យ ឬ បានទទួលជ័យជម្នះ ? យើងនឹងបានចាំតួយ៉ាង ឬយកតួយ៉ាងរបស់គេ, ទោះជាព្រឹត្តិការណ៍កើតឡើងមិនដូចគ្នា ឬ សភាពនៃជីវិតនិងឋានៈរបស់យើងខុសប្លែកអំពីបុគ្គលអស់ទាំងនោះ តែវិធីការតស៊ូក៏ពុំបានខុសគ្នាប៉ុន្មានទេ ។ ប្រការ ២ ការសិក្សាអំពីជីវិតតួយ៉ាងនោះជាការមួយជួយឲ្យយើងមានសេចក្ដីមានះ ព្យាយាមមិនរុញរាមានកម្លាំងចិត្តតស៊ូដូចគេធ្លាប់ធ្វើមក ។

ការពិតគេមិនត្រូវសង្ស័យឡើយថា ជីវិតគឺការតស៊ូ ប្រសិនបើមនុស្សយើងមិនមានការតស៊ូ មនុស្សយើងក៏មិនអាចរស់នៅបាន, ខ្លួនមនុស្សម្នាក់ៗ នឹងត្រូវស្លាប់បាត់បង់ទៅ, ឈ្មោះ សំឡេង សម្រាប់ខ្លួន ឬ សម្រាប់ត្រកូលក៏ត្រូវវិនាសសូន្យទៅ ។ បើមនុស្សទាំងជាតិមិនមានលក្ខណៈជាអ្នកតស៊ូ ជាតិទាំងជាតិក៏ត្រូវរលាយសូន្យទៅ ។ មនុស្សម្នាក់ៗ ឬ ជាតិមួយៗ ដែលរស់នៅបាន រស់នៅបានល្អ គឺជាផលរបស់ការតស៊ូ អ្នកដែលបានឡើងកាន់ឋានៈ រឹតតែធំឡើង ក៏ជាផលនៃការតស៊ូដែលគេបានធ្វើកាន់តែខ្លាំងឡើងនោះឯង ។

ការសិក្សាអំពីជីវិតតួយ៉ាងនេះ យើងមិនអាចរៀនឲ្យហួសអំពីព្រំដែនបានទេ គឺត្រូវរៀនចំពោះតែជីវិតរបស់បុគ្គលដែលមានលិខិតឯកសារឬសេចក្ដីប្រវត្តិរបស់គេ សម្រាប់ឲ្យយើងអាន, ឲ្យយើងសិក្សា ។ បុគ្គលដែលមិនមានជីវប្ប-

វត្តិសរសេរដោយច្បាស់លាស់ យើងក៏មិនអាចសិក្សាបាន ឡើយ ។ ក៏បុគ្គលដែលមានជីវប្បវត្តិសរសេរដោយជាក់លាក់ នោះ ច្រើនតែជាមនុស្សមានអំណាចធំដុំខាងផ្លូវនយោបាយ ឬខាងផ្លូវសាសនា ឬ ខាងផ្លូវសេដ្ឋកិច្ច ។ ល ។ ដូច្នេះជីវិតតួយ៉ាង ដែលយើងត្រូវរៀននោះទើបមានច្រើន គឺជីវិតអ្នកនយោបាយធំៗ ឬជីវិតសាស្តាចារ្យធំៗ ក្នុងសាសនាមួយៗ តែយើងមិនត្រូវដៅសេចក្តីថា ជីវិតអ្នកតស៊ូ មានតែអ្នកនយោបាយធំៗ ឬសាស្តាចារ្យធំៗ ប៉ុណ្ណោះទេ ។ ដែលពិត ការតស៊ូនោះ គឺជាការចាំបាច់សម្រាប់ជីវិតរាល់ប្រភេទ, តែជីវិតរបស់បុគ្គលប្រភេទដទៃៗ យើងមិនងាយនឹងសិក្សាបានទេ ព្រោះខ្វះលិខិតឯកសាររឿងរ៉ាវសម្រាប់ជីវិតរបស់គេ ។

ជីវិតអ្នកដឹកនាំប្រទេសម្នាក់ៗ នោះទៀតសោត ក៏ជារឿងក្រ លំបាកនឹងវិនិច្ឆ័យថា អ្នកណាជាបុគ្គលល្អ អ្នក

ណាជាបុគ្គលអាក្រក់ ព្រោះបុគ្គលពួកនេះអាចប្រព្រឹត្តទៅបាន ទាំងពីរយ៉ាង, បុគ្គលពួកមួយឃើញថាល្អ, តែបុគ្គលពួកមួយទៀតអាចឃើញថាមិនល្អ ។ ខាងឧត្តមគតិក៏ដូចគ្នា ពួកមួយឃើញថាល្អ ពួកមួយឃើញថាមិនល្អ ។ ប្រការមួយទៀតអ្នកដឹកនាំប្រទេសខាងនយោបាយនោះ មានពេលខ្លះជោគវាសនាត្រូវធ្លាក់ចុះ មានពេលខ្លះ ដោយវាសនាត្រូវឡើង កម្រនឹងបានរុងរឿងអស់មួយជីវិត ។ ជួនកាលការធ្លាក់ចុះនៃជោគវាសនារបស់បុគ្គលនោះ អាចធ្វើឲ្យមានផលអាក្រក់ដល់ប្រទេសជាតិរបស់ខ្លួនផង ដូចការធ្លាក់ចុះនៃជោគវាសនារបស់ហ៊ីត្លែរ៍ និងមុស្សូលិនី សឹងនាំមកនូវបរាជ័យដល់ប្រជាជាតិអាល្លឺម៉ង់ និងអ៊ីតាលីក្នុងសម័យសង្គ្រាមលោកលើកទី ២ ។ ក្នុងខាងក្រោយ ដែលបុគ្គលនេះអស់ជីវិតសង្ខារទៅហើយ មតិប្រជាជនមានសេចក្ដីឃើញផ្សេងគ្នាខ្លះឃើញថា បុគ្គលនេះមានសេចក្ដីល្អនៅក្នុងសន្ដានចិត្តច្រើន

ខ្វះឃើញថាអាក្រក់ទៅវិញ ។ ចំណែកខាងសាស្តាចារ្យក្នុងសាសនាមួយៗ ក៏មានរឿងរ៉ាវដូចអ្នកដឹកនាំប្រទេសដែរ ។

តែការសិក្សារបស់យើងក្នុងសៀវភៅនេះ មិនមែនសិក្សាអំពីសេចក្តីអាក្រក់ល្អរបស់មនុស្សទេ តែយើងសិក្សាខាងការតស៊ូក្នុងជីវិតរបស់មនុស្ស ។ យើងត្រូវទទួលដឹងថា បុគ្គលដែលបានឡើងកាន់អំណាចខ្ពង់ខ្ពស់បំផុត ខាងផ្លូវនយោបាយក្តី ខាងផ្លូវសាសនាក្តី ខាងផ្លូវសេដ្ឋកិច្ចក្តី បានមកដោយផលគឺការតស៊ូរបស់គេ ។ យើងសិក្សាត្រឹមតែរឿងតស៊ូ យើងមិនសិក្សាហួសទៅដល់ផលអាក្រក់ល្អសឹងកើតឡើងក្នុងទីបំផុតនៃជីវិតអ្នកតស៊ូឡើយ ។ កាលណាយើងបានកម្រិតព្រំដែននៃការសិក្សារបស់យើងត្រឹមប៉ុននេះ យើងក៏អាចសិក្សាបានច្រើន សូម្បីក្នុងជីវិតរបស់មនុស្ស ដែលក្នុងសម័យខ្វះ និងឧត្តមគតិខ្វះ មិនឃើញថាល្អ មិននិយមរាប់អានក៏ដោយ ។

តែអ្នកសិក្សាកុំភ្លេចថា ការរៀនប្រវត្តិជីវិតមនុស្សអ្នកតស៊ូ ដោយមិនគិតដល់ផលអាក្រក់ល្អនោះ មិនមែនមានន័យថា កំហុសដែលបុគ្គលម្នាក់ ៗ បានប្រព្រឹត្តមកហើយនោះ ជាអំពើល្អ ជាករណីយ៍សម្រាប់ខ្លួនរបស់យើងទេ គឺអំពើអស់ទាំងនោះត្រឹមតែជាមេរៀនរបស់យើងប៉ុណ្ណោះ ។ ប្រវត្តិជីវិតមនុស្សអ្នកតស៊ូ ដែលយើងត្រូវស្គាល់ក្នុងសៀវភៅនេះ មិនមែនជាជីវប្បវត្តិពិស្តារស្ដីដោយការងាររបស់មនុស្សម្នាក់ៗ ចប់ចុងចប់ដើមទេ គឺជាសេចក្ដីដកស្រង់នៃជីវប្បវត្តិរបស់បុគ្គលសំខាន់ៗ ចំពោះត្រង់ការតស៊ូរបស់គេ ជាពិសេសគឺស្រង់យកតែចំណុចធំៗ ដែលយល់ឃើញថាមានប្រយោជន៍ហើយដែលជាមេរៀនល្អ សម្រាប់អ្នកធ្វើការតស៊ូ ។ អ្នកអានប្រសិនបើត្រូវការចង់ដឹងរឿងទាំងមូលរបស់មនុស្សម្នាក់ៗ នោះ គប្បីស្វែងរកមើលក្នុងជីវប្បវត្តិពិស្តារនៃបុគ្គលនោះៗ ចុះ តែបើចង់ដឹងត្រឹមតែចំណុចសំខាន់ៗ

របស់អ្នកតស៊ូខ្វះនោះ   ក្នុងសៀវភៅនេះមានគ្រប់គ្រាន់ល្មម ដល់សេចក្តីត្រូវការរបស់អ្នកអានហើយ ។

# ជីវិត

## សិទ្ធត្ថគោតម

អ្នកអានបានស្គាល់ជីវិតរបស់មហាបុរសនេះ ដោយពុទ្ធជីវប្បវត្តិហើយ ។ ចំពោះការតស៊ូដែលមហាបុរសបានធ្វើ ក៏មិនមែនជារបស់កំបាំងទេ គឺអ្នកណាៗ ក៏សឹងតែបានដឹងហើយថា ព្រះអង្គទ្រង់បានធ្វើសង្គ្រាមឈ្នះមារទាំង ៥ ពួក (កិលេស, ខន្ធ, ទេពបុត្រ, អភិសង្ខារ, មច្ចុ) អ្វីជាកិលេស? គ្រឿងធ្វើចិត្តឲ្យសៅហ្មង (លោភៈ, ទោសៈ មោហៈ) អ្វីជាខន្ធ? គ្រឿងប្រមូលផ្តុំជាខន្ធ (រូប, វេទនា, សញ្ញា, សង្ខារ, វិញ្ញាណ) អ្វីជាទេពបុត្រ? កូនអ្នកលេងកាម (រូប, សំឡេង, ក្លិន, រស, សម្ផស្ស) អ្វីជាអ-ភិសង្ខារ? កុសលាកុសលចេតនាសម្រាប់ចាត់ចែងឲ្យមនុស្សសត្វមានជាតិ, ភព.......... អ្វីជាមច្ចុ? ការស្លាប់ជីវិតតាមភាវៈប្រែប្រួលនៃធម្មជាតិ ។

កូនមារទាំង ៥ ពួកនេះ មានតែទេពបុត្រមារនិងមច្ចុមារទេ ដែលមានអាថិកំបាំងលំបាកយល់ ដើម្បីជាពន្ទឺនៃគំនិត ខ្ញុំសូមឲ្យអ្នកអានគិតថា ជាធម្មតានៃមនុស្សលោក, បុគ្គលណាមានវាសនាថោកទាប ឬ មានវាសនាតិច បុគ្គលនោះតែងមានសេចក្ដីប្រណែន មិនចង់ឲ្យបុគ្គលមានវាសនាខ្ពស់ ឬមានវាសនាច្រើនបានសម្រេចនូវគោលបំណងល្អ ឬប្រយោជន៍ខ្ពង់ខ្ពស់ជាងខ្លួនទេ ។ សេចក្ដីប្រណែននេះ, បានបង្ខំឲ្យគេព្យាយាមធ្វើការគ្រប់យ៉ាង ដើម្បីទាញទប់នូវវិរិយកម្មរបស់មនុស្ស ដែលកំពុងធ្វើការដើម្បីឆ្លងកាត់ចាកវិស័យរបស់គេ ។ មនុស្សនេះហើយដែលគម្ពីរពុទ្ធប្បវត្តិឲ្យឈ្មោះថា: "ទេពបុត្រមារ" សព្ទនេះញែកបានជាបីគឺ "ទេព" ប្រែថា "លេង" "បុត្ត" ប្រែថា "កូន" "មារ" ប្រែថា "ស្លាប់" ឬ "សម្លាប់" រួមចូលជា "ទេពបុត្តមារ" ប្រែថា "អ្នកស្លាប់គោលបំណងដោយឧបាយបោកបញ្ឆោត

នៃកូនអ្នកលេង ឬ ពួកអ្នកលេង" ។ ចំពោះរឿងនេះ មិនមែនជារឿងប្លែកទេ គឺជាធម្មតានៃមនុស្ស អ្នកខ្លះកើតមកខំប្រឹងធ្វើការបម្រើពិភពលោក មិនមានគិតដល់សេចក្ដីនឿយហត់និងប្រយោជន៍របស់ខ្លួនឡើយ ។ អ្នកខ្លះកើតមកដើម្បីសប្បាយនៅលើកម្រៃនៃកិច្ចការរបស់អ្នកដទៃ ខ្លួនឯងមិនខំប្រឹងធ្វើការទេ ។ អ្នកខ្លះកើតមកស្រឡាញ់កេរ្ដិ៍ឈ្មោះ ហើយមិនខំធ្វើការខ្លួនឯងទេ មិនជួយទំនុកបម្រុងអ្នកធ្វើការទេ ឃើញអ្នកណាគេធ្វើការមានកេរ្ដិ៍ឈ្មោះល្អ ព្យាយាមសម្លាប់អ្នកនោះចោលដើម្បីកេរ្ដិ៍ឈ្មោះរបស់ខ្លួន ។

បើតាមន័យនេះ មារបំផ្លាញគេមិនមែនមានតែព្រះពុទ្ធបរមគ្រូយើងទេ ព្រះឯទៀតៗ និងបុគ្គលដទៃៗ ដែលជាអ្នកធ្វើការពិតៗ សុទ្ធតែមានមារជ្រែកដូចៗ គ្នា ។ ចំណែកមច្ចុមារ ពាក្យនេះ មានសព្ទដល់ទៅពីរ ហើយសព្ទទាំងពីរនេះ មានសេចក្ដីប្រែដូចគ្នាគឺ "មច្ចុ" ក៏ប្រែថា

"ស្លាប់" "មារៈ" ក៏ប្រែថា "ស្លាប់" ក្នុងគម្ពីរពុទ្ធប្បវត្តិត្រង់ចំណុចថា មារបាននិមន្តព្រះរបស់យើងឲ្យចូលនិព្វាននោះ បើនិយាយជាបុគ្គលាធិដ្ឋាន ក៏បានដល់មនុស្សដែលសម្លាប់ប្រយោជន៍របស់ខ្លួន ឬ មានប្រយោជន៍របស់ខ្លួនស្លាប់អស់ហើយ, ហើយមានសេចក្តីឈឺចិត្ត, មានសេចក្តីប្រណែននឹងមនុស្សដែលមានសេចក្តីចម្រើន, មានកេរ្តិ៍ឈ្មោះល្អជាងខ្លួន, តែរកធ្វើម៉េចមិនកើត ព្រោះខ្លួនមានកម្លាំងតិចជាងគេ ៗ មធ្យោបាយទាល់គំនិតនៃមនុស្សនេះ មានតែមួយគឺសូមឲ្យគេស្លាប់ ដើម្បីកុំឲ្យទើសទែងខ្លួន, តែបើនិយាយជាធម្មាធិដ្ឋាន ក៏បានដល់ការសម្រេចចិត្តរបស់ព្រះពុទ្ធបរមគ្រូរបស់យើង ដែលទ្រង់រកឃើញថា វត្ថុធាតុទាំងអស់សុទ្ធតែត្រូវស្លាប់ ព្រោះវត្ថុធាតុទាំងអស់មានស្លាប់នៅក្នុងស្លាប់គឺស្លាប់ដូចៗ គ្នា មិនមានអ្នកណាអាចយករបស់ស្លាប់ មកកែស្លាប់ឲ្យរស់បានទេ នេះហើយដែលហៅថា "មច្ចុមារ"

ប្រែថា "ស្លាប់ព្រោះស្លាប់" ឬ "ស្លាប់ដោយស្លាប់" ។ បើតាមន័យនេះឃើញថា ព្រះសម្មាសម្ពុទ្ធរបស់យើង ពុំមានជ័យជម្នះលើមច្ចុមារនេះទេ ព្រោះព្រះអង្គត្រូវស្លាប់តាមភាវៈនៃធម្មជាតិ ដូចមនុស្សដទៃៗ ដែរ, តែតាមសេចក្ដីពិតនោះ ព្រះពុទ្ធបរមគ្រូរបស់យើង ព្រះអង្គពុំមែនស្លាប់ទេ គឺព្រះអង្គនិព្វាន ។ ពាក្យថា "និព្វាន" និងពាក្យថា "ស្លាប់" សឹងមានន័យខុសគ្នា "ស្លាប់មានន័យថា "រលត់ជីវិតចាស់ហើយកើតជីវិតថ្មីទៀត" "និព្វាន" មានន័យថា "រំលាយជីវិតចាស់របស់ធម្មជាតិ ហើយសាងជីវិតថ្មីទៀត ដោយប្រាសចាកការចាត់ចែងរបស់ធម្មជាតិ, ការរលត់ជីវិតហើយកើតទៀត ដោយការចាត់ចែងរបស់ធម្មជាតិ ហៅថា "ស្លាប់" បានដល់សេចក្ដីស្លាប់នៃមនុស្សធម្មតាដែលពុំទាន់មានជ័យជម្នះលើមច្ចុមារ ។ ការរលត់ជីវិតហើយពុំបានកើតទៀត ដោយការចាត់ចែងរបស់ធម្មជាតិ ហៅថា:

"និព្វាន" បានដល់សេចក្តីស្លាប់របស់ព្រះអរហន្តទាំងឡាយ មានព្រះពុទ្ធជាដើម នេះហើយដែលគម្ពីរពុទ្ធប្បវត្តិបានដៅបញ្ជាក់ថា ព្រះសម្មាសម្ពុទ្ធរបស់យើងបានធ្វើសង្គ្រាមឈ្នះមច្ចុមារ ។

សង្គ្រាមជីវិតដែលព្រះសិទ្ធត្ថគោតមៈ បានធ្វើនោះ មានដូចនេះគឺ ៖

១) ទ្រង់រំដោះជំនឿរបស់ព្រះអង្គ ដែលធ្លាប់មានក្នុងប្រពៃណីសម្រាប់ត្រកូល ។

២) ទ្រង់ពង្រឹងស្មារតីរបស់ព្រះអង្គក្នុងសច្ចធម៌នៃធម្មជាតិ ។

៣) ទ្រង់រំលាយសេចក្តីស្នេហាក្នុងសន្តានចិត្តរបស់ព្រះអង្គ ដែលសាងឡើងដោយធម្មជាតិ ។

៤) ទ្រង់លះបង់សេចក្តីសុខបន្ទំ ដែលកើតឡើងដោយតណ្ហា ។

៥) ទ្រង់ប្រទានសេចក្ដីព្យាយាមរបស់ព្រះអង្គ ទៅក្នុងការងារប្រកបដោយសេចក្ដីទុក្ខ ដែលមនុស្សធម្មតាតែងគ្រាកចិត្ត ។

ព្រះសិទ្ធត្ថគោតមៈ ដែលក្រោយមកគេផ្លាស់ព្រះនាមជាព្រះសមណគោតមៈ ហើយដែលទ្រង់បានបង្កើតពុទ្ធសាសនាឡើងក្នុងលោកនោះ ព្រះអង្គជាបុត្ររបស់ក្សត្រគ្រងរាជ្យក្រុងកបិលពស្តុ នៅជិតបរិវេណព្រៃហេមពាន្ត ព្រះអង្គកើតក្នុងដែនសក្កៈ មានជាតិជាអរិយកៈ, ព្រះបិតារបស់ព្រះអង្គព្រះនាមសុទ្ធោទនៈ ព្រះមាតាព្រះនាមសិរិមហាមាយា ។ វេលាកើតហើយបាន ៥ ថ្ងៃ ព្រះបិតាបានអញ្ជើញព្រាហ្មណ៍ ១០៨ នាក់មកលៀងភោជនាហារ ដែលពេលនោះមានធ្វើពិធីឲ្យនាមព្រះរាជបុត្រថា "សិទ្ធត្ថៈ" ។ កាលព្រះសិទ្ធត្ថកុមារមានព្រះជន្ម ៧ ឆ្នាំ ព្រះបិតាបានចាត់ឲ្យគេជីកស្រះបោក្ខរណី ៣ ក្នុងព្រះបរមរាជវាំង ដើម្បីកំសាន្តសប្បាយនៃព្រះ

រាជបុត្រ ។ លុះព្រះសិទ្ធត្ថកុមារ មានវ័យគួរដល់ការសិក្សា ហើយ ព្រះបិតាបាននាំទៅឲ្យនៅក្នុងសំណាក់អាចារ្យឈ្មោះ វិស្វមិត្រ ។ លុះព្រះសិទ្ធត្ថកុមារមានព្រះជន្ម ១៦ ឆ្នាំ ព្រះបិតា បានចាត់ឲ្យជាងសាងប្រាសាទ ៣ ខ្នង ។ មួយខ្នងសម្រាប់ ព្រះរាជបុត្រប្រថាប់ក្នុងរដូវត្រជាក់ មួយខ្នងសម្រាប់រដូវក្ដៅ និងមួយខ្នងទៀតសម្រាប់រដូវភ្លៀង ហើយព្រះបិតាទ្រង់ បានសូមនាងយសោធរា ជាព្រះរាជធីតាព្រះបាទសុប្បពុទ្ធ ជាក្សត្រគ្រងរាជ្យក្រុងទេវទហៈ ព្រះមាតាព្រះនាមអមិតាជា ប្អូនស្រីនៃព្រះអង្គ មកអភិសេកជាព្រះជាយានៃព្រះរាជបុត្រ ។

ព្រះសិទ្ធត្ថទ្រង់សោយរាជសម្បត្តិ ជាសុខសប្បាយជា មួយព្រះជាយា នៅក្នុងកណ្ដាលពួកស្ត្រីបម្រើ ពុំដែលមាន សេចក្ដីទុក្ខព្រួយសោះឡើយ អស់រយៈវេលា ១៣ ឆ្នាំ ។ ដោយសេចក្ដីស្នេហាក្នុងព្រះរាជបុត្ររកអ្វីប្រៀបពុំបាន ព្រះ បិតារបស់ព្រះអង្គ ទ្រង់ចេះតែបន្ថែមគ្រឿងឧបករណ៍សម្រាប់

ជួយគាំទ្រ និងជួយពង្រីកសេចក្តីសប្បាយរបស់ព្រះរាជបុត្រ ជានារីមានរូបល្អៗ ខ្លះ, ជាក្មេងពិរោះៗ ខ្លះ, ជារបស់ ផ្អែកៗ ដែលមិនធ្លាប់មានខ្លះ ។ ល ។ លុះព្រះសិទ្ធត្ថមាន ព្រះជន្ម ២៩ ឆ្នាំ ព្រះនាងពិម្ពាទ្រង់ប្រសូត្រព្រះឱរសមួយព្រះ អង្គទ្រង់ព្រះនាមថា "រាហុល" ។ ក្នុងពេលនោះព្រះសិទ្ធត្ថមាន គំនិតថ្មីកើតឡើងថា សេចក្តីកើត, សេចក្តីឈឺ, សេច-ក្តីស្លាប់ គឺភាពប្រែប្រួលផ្លាស់ប្តូរនៃរូបកាយជាសេចក្តីទុក្ខ ។ ការរស់នៅលើកម្លាំងអ្នកដទៃ ជាកសិករ, ជាឧស្សាហករ, ជាហត្ថករ, ជាបសុសត្វករ មិនមែនជាការរស់នៅសម្រាប់ មនុស្សអ្នកមានមនុស្សធម៌ មិនមែនជាចរិយាសម្រាប់មនុស្ស អ្នកតស៊ូ ដើម្បីរំដោះទុក្ខរបស់ខ្លួន និងប្រជាសត្វលោកទេ ។ ព្រះសិទ្ធត្ថទ្រង់គិតជញ្ជឹងរកផ្លូវរំដោះទុក្ខ ហើយទ្រង់យល់ ឃើញថា ការស្រាវជ្រាវរកផ្លូវរំដោះទុក្ខនោះ ពុំអាចធ្វើ ក្នុងព្រះបរមរាជវាំង ក្នុងវិស័យនៃខ្លួនជាយរាវាសបានទេ ។

ក្នុងពេលមួយ ជាពេលពាក់កណ្តាលយប់ស្ងាត់ ពួកអ្នកក្រុង និងពួកស្ត្រីរបាំ ដេកលក់អស់គ្មានសល់ម្នាក់ ។ ព្រះសិទ្ធត្ថៈ ទ្រង់ដោះព្រះអង្គចេញចាកព្រះរាជវាំង ដោយមានសេះឈ្មោះ កណ្ឋកៈ ជាយានជាមួយបុរសកំសត់កម្រម្នាក់ឈ្មោះឆន្នៈ ។ ព្រះអង្គបានទៅដល់ត្រើយស្ទឹងអនោមាក្នុងចុងរាត្រីនោះ ហើយទ្រង់កោរសក់អធិដ្ឋានផ្នួសក្នុងពេលនោះ ។ ព្រះអង្គបានបញ្ជាឲ្យឆន្នៈ នាំសេះកណ្ឋកៈ និងគ្រឿងប្រដាប់តែងកាយ ព្រមមួយអន្ទើដោយដំណឹងទៅថ្វាយព្រះបិតា ។ រហូតមកដល់ត្រឹមនេះ យើងឃើញថា មហាបុរសទ្រង់បានតស៊ូឈ្នះបំណងបិតារបស់ព្រះអង្គ ដែលទ្រង់មានព្រះរាជហឫទ័យស្នេហាក្នុងព្រះរាជបុត្រ បានទ្រង់ចាត់វិធានការការពារដោយមធ្យោបាយយ៉ាងប៉ិនប្រសប់ ។ ទ្រង់ឈ្នះជីវិតស្នេហាក្នុងករិយា ដែលព្រះនាងកំពុងបរិបូរដោយវ័យ មានរូបកាយល្អសមរម្យឥតខ្ចោះ ប្រៀបបាននឹងទេព-

កញ្ញា មានសំឡេងពិរោះប្រៀបបាននឹងតន្ត្រីទិព្វ ។ ទ្រង់ឈ្មោះជីវិតស្នេហាក្នុងរាជនិវេស ដែលទើបនឹងប្រសូត្រហើយថ្មីៗ ហើយដែលព្រះអង្គពុំទាន់បានឃើញមុខ ជាពិសេសគឺទ្រង់ឈ្មោះវត្ថុជាគ្រឿងញៀន ដែលគេបានចាត់ចែងឡើងដើម្បីបោកគំនិត ដើម្បីពង្វាងផ្លូវពិត និងដើម្បីរំលាយចោលនូវឧត្តមគតិរបស់ព្រះអង្គ ។

ព្រះសិទ្ធត្ថៈ ក្រោយអំពីបានទ្រង់ផ្នួសស្រេចហើយ ព្រះអង្គ ទ្រង់ឈានចូលព្រៃដោយព្រះបាទ ទ្រង់វែកស្មឹកឈើដោយព្រះហស្ត ទ្រង់សឹងលើផែនដី មានស្មឹកឈើជាកម្រាលមានឫសឈើជាខ្នើយ មានដើមឈើជាដំបូល មានព្រៃស្បាតជាជញ្ជាំង មានផ្លែឈើជាអាហារ ។ ជាដម្បូងព្រះអង្គចូលសិក្សាវិជ្ជាសមាបត្តិក្នុងសំណាក់អាចារ្យឈ្មោះអាឡារកា-លាមគោត្រ និងឧទករាមបុត្រ ។ បន្ទាប់មកទ្រង់ធ្វើទុក្ករកិរិយា ដើម្បីបន្ថយកម្លាំងកាយ ដោយអត់នូវអាហារ

ដោយអត់នូវខ្យល់ចេញចូល ។ តែការសិក្សា និងការប្រតិបត្តិទាំងអស់នេះ ពុំអាចធ្វើឲ្យព្រះអង្គបានសម្រេចនូវការត្រាស់ដឹងឡើយ ។ ចុងក្រោយបង្អស់ ព្រះអង្គទ្រង់សិក្សាវិជ្ជាចិត្តសាស្ត្រ (វិបស្សនាកម្មដ្ឋាន) ដោយព្រះអង្គឯង ក្នុងទីបំផុតនៃការសិក្សានេះ ព្រះអង្គក៏បានត្រាស់ដឹងនូវសច្ចធម៌ ។ រហូតមកដល់ត្រង់នេះ យើងឃើញថា មហាបុរសទ្រង់បានតស៊ូឈ្នះធម្មជាតិក្តៅត្រជាក់... ឈ្នះសេចក្តីខ្ជិលប្រអូស, ឈ្នះសេចក្តីសុខមិនពិត, ឈ្នះប្រពៃណីនិយមរបស់មនុស្សទាំងឡាយ ។

ព្រះសមណគោតម ក្រោយអំពីបានត្រាស់ដឹងនូវសច្ចធម៌, ក្នុងខាងចុងឆ្នាំទី ៦ នៃទុក្ករកិរិយា ព្រះអង្គបានបំពេញពុទ្ធកិច្ច ដើម្បីប្រជាសត្វលោកគឺ :

១) បិណ្ឌបាត្រ

២) ទេសនា

៣) បង្រៀន

៤) ស្រាយបញ្ហា

៥) ពិនិត្យវាសនា

បិណ្ឌបាត បានសេចក្ដីថា ព្រះអង្គព្រមទទួលរស់នៅជាមួយមនុស្សគ្រប់វណ្ណៈ.... ដោយដុំបាយដុំសិំនី គេរស់នៅយ៉ាងណា ព្រះអង្គក៏រស់នៅយ៉ាងនោះ ។ ទេសនា, ពេលថ្ងៃរសៀល ព្រះអង្គទ្រង់សម្ដែងធម៌ឲ្យមនុស្សទាំងឡាយស្ដាប់, ការសម្ដែងធម៌នេះ ជួនកាលធ្វើឡើងដោយគេនិមន្ត ជួនកាលធ្វើឡើងដោយការជួបប្រទះក្នុងទីផ្សេងៗ ដោយឥតមានគេនិមន្ត ។

បង្រៀនពេលយប់ចាប់ពីត្រឹមម៉ោង ៦-៧ ទៅដល់ម៉ោង ១១-១២ ព្រះអង្គទ្រង់បង្រៀនបព្វជិតនូវធម្មវិន័យ ។ ការបង្រៀននេះជួនកាលធ្វើនៅក្នុងវត្ត ជួនកាលធ្វើនៅទីក្រៅវត្ត ជួនកាលធ្វើតាមដំណើរ (កណ្ដាលផ្លូវ) ។

ស្រាយបញ្ហា ពេលពាក់កណ្ដាលយប់ប្រហែលម៉ោង ១២ ទៅដល់ម៉ោង ៥ ព្រះអង្គទ្រង់ស្រាយបញ្ហាដែលចោទឡើងដោយពួកទេព, ពួកក្សត្រនិងពួកឥស្សរជនៗ ការស្រាយបញ្ហាចែកជា ៣ ។ ១) ដោយឆ្លើយសំនួរ, ២) ដោយកែតម្រូវ, ៣) ដោយសម្ដែងសេចក្ដីយល់ព្រម ។

ពិនិត្យវាសនា ពេលជិតភ្លឺប្រហែលពីម៉ោង៥ ទៅម៉ោង ៦ ព្រះអង្គទ្រង់ពិនិត្យវាសនាមនុស្សទូទៅ។ ការពិនិត្យវាសនានេះ ទ្រង់បែងពេលជា ២ គឺ ពេលពិនិត្យចេញ និងពេលពិនិត្យចូល ។ ពេលពិនិត្យចេញបានដល់ពេលពិនិត្យដែលទ្រង់ចាប់ផ្ដើមអំពីទីលំនៅដែលព្រះអង្គទ្រង់គង់ចេញទៅ។ ពេលពិនិត្យចូល បានដល់ពេលពិនិត្យ ដែលទ្រង់ចាប់ផ្ដើមអំពីទីខាងក្រៅចូលមកដល់លំនៅដែលព្រះអង្គគង់នៅ ។

ព្រះសមណគោតមបរមគ្រូរបស់យើង ទ្រង់បានស្រាយបញ្ហាជីវិតរបស់ព្រះអង្គរួចហើយ ទ្រង់ឈ្នះសង្គ្រាមជីវិតរបស់

ព្រះអង្គហើយ ទ្រង់បានជួយស្រាយបញ្ហាជីវិតរបស់ប្រជាសត្វលោកដោយពុទ្ធកិច្ចចប់ហើយ វត្តបំណងនិងឧត្តមគតិរបស់ព្រះអង្គ បានដល់ទីបំផុតហើយ ។ ព្រះអង្គទ្រង់ប្រាប់ថាៈ អ្នកណាក៏ដោយបើចង់ស្រាយញ្ហាជីវិតរបស់ខ្លួន ក្នុងវិស័យសេដ្ឋកិច្ចក្តី ក្នុងវិស័យសិក្សាក្តី ក្នុងវិស័យកសិកម្មក្តី ក្នុងវិស័យមគ្គផលព្រះនិព្វានក្តី ។ល។ កុំភ្លេចបណ្តុះជំនឿ, ពង្រឹងស្មារតី, ពង្រីកព្យាយាម, និងបង្កើនគំនិតបញ្ហារបស់ខ្លួនទៅក្នុងវិស័យនោះៗ ។ ព្រមគ្នានេះ ព្រះអង្គបានប្រាប់ថាការស្រាយបញ្ហាជីវិត ពិតជាគេត្រូវស្រាយដោយការតស៊ូក៏មែនតែអ្នកតស៊ូណាមិនមានយុត្តិធម៌ក្នុងមុខការរបស់ខ្លួន អ្នកតស៊ូនោះពុំបានឈ្មោះថាជាអ្នកតស៊ូត្រឹមត្រូវទេ ។ ចំពោះរឿងតស៊ូនេះ, ព្រះពុទ្ធបរមគ្រូរបស់យើង ព្រះអង្គជាជើងឯកខាងការតស៊ូដោយមានសេចក្តីយុត្តិធម៌ក្នុងការងារ ។ ក្នុងសម័យពុទ្ធកាល, មានលទ្ធិសាសនាជាច្រើន បានត្រូវបរិស័ទរបស់

ខ្លួនវត់បោល ដោយមកអំពីអស់ជំនឿ ក្នុងទ្រឹស្តីនៃលទ្ធិសា-សនានោះៗ ហើយបានចូលខ្លួនមកធ្វើជាបរិស័ទនៃពុទ្ធសា-សនាវិញ ។ ពួកគ្រូអាចារ្យនៃសាសនាទាំងឡាយនោះមិនគិតនាំគ្នារកមធ្យោបាយរៀបចំសាសនារបស់ខ្លួនឲ្យបានល្អ ដើម្បីទាញយកបរិស័ទរបស់ខ្លួនវិញទេ, គេបែរជានាំគ្នាសំអុយកេរ្តិ៍ឈ្មោះព្រះសម្មាសម្ពុទ្ធរបស់យើង ដើម្បីសម្រេចនូវជ័យជម្នះរបស់ខ្លួន ការតស៊ូដោយប្រានរំលំនូវជំហរអ្នកដទៃ ដើម្បីសាងជំហររបស់ខ្លួនមិនមែនជាការតស៊ូត្រឹមត្រូវទេ ។ មិនមែនជាការតស៊ូប្រកបដោយសេចក្តីយុត្តិធម៌ឡើយ ។ ព្រះពុទ្ធបរមគ្រូរបស់យើង ព្រះអង្គបានដឹកនាំមនុស្សឲ្យតស៊ូដោយធ្វើការងារនិងយកឈ្នះអ្នកដទៃដោយកម្លាំងការងាររបស់ខ្លួន ដោយព្រះអង្គទ្រង់បញ្ជាក់ថាមានតែការឈ្នះខ្លួនឯងទេ ដែលចាត់ថាជាការឈ្នះប្រសើបំផុត ។

ជីវិត

## ហេ្វរ៍ឌីណង់ដ៍ដឺលេសេ្សបស៍

*ហេ្វរ៍ឌីណង់ដ៍ដឺលេសេ្សបស៍, ជាបុគ្គលដែលបានផ្ដើមជីកព្រែកស៊ុអេស៍, ព្រែកនេះមានប្រយោជន៍សំខាន់ ដល់ប្រជាជនក្នុងពិភពលោក ការនាំទំនិញចេញចូល និងគមនាគមន៍ខាងផ្លូវទឹក ត្រូវបានអាស្រ័យព្រែកនេះ, គេបានធ្វើអស់ពេលយ៉ាងយូរហើយយ៉ាងលំបាកផង ។*

*លេសេ្សបស៍ ជាមនុស្សចូលចិត្តស្ងប់ស្ងៀម មិនសូវចេះនិយាយច្រើន ។ គេចូលចិត្តនិយាយតែការណាដែលមានសេចក្ដីចាំបាច់ត្រូវនិយាយ សូម្បីតែរឿងជីកព្រែកស៊ុអេស៍នេះ ក៏គេពុំធ្លាប់បាននិយាយថាជារឿងពិតប្រាកដ ឬ ជារឿងធំដុំក្នុងជីវិតរបស់គេឡើយ ។*

*ពេលមួយ គេបានអានសៀវភៅរាយការណ៍របស់បុរសម្នាក់ឈ្មោះឡឺប៉ែរ៍ នៅក្នុងនាវាមួយក្នុងដំណើរទៅធ្វើជាកុង*

ស៊ីលរេងនៃប្រទេសបារាំងប្រចាំក្រុងអាឡេក្សសង់ដ្រី ។ លេ-សេប្រស៍, មានសេចក្តីចាប់ចិត្តក្នុងសេចក្តីរាយការរបស់លោកឡឺប៉ែរ៍យ៉ាងច្រើន ។ គេគិតភ្លាមថា, ខ្លួនគេនឹងត្រូវធ្វើការនេះឲ្យបានសម្រេច ទោះជាមានឧបសគ្គយ៉ាងណាក៏ដោយ ។ បិតាលេសេប្រស៍និងខ្លួនលេសេប្រស៍ ក៏ធ្លាប់ធ្វើការនៅក្នុងប្រទេសអេស៊ីប្ត៍ជាច្រើនឆ្នាំ មានមិត្តស្និទ្ធស្នាលក្នុងប្រទេសនោះច្រើន ។ ក្នុងពេលមកដល់ប្រទេសអេហ្ស៊ីប្ត៍គេបានទទួលការជានាវ៉ាប់រងជាច្រើនអំពីភៀននៃបិតារបស់គេ ដែលសុទ្ធតែជាពាណិជ្ជករធំៗ មានពាណិជ្ជករថ្នាំជក់ជាដើម ។

ក្នុងខណៈ ដែលកំពុងតែគិតរកមធ្យោបាយ ដើម្បីនឹងជីកព្រែកនេះលេសេប្រស៍ ក៏ត្រូវផ្លាស់ទៅអឺរ៉ុបទៅនៅធ្វើការក្នុងក្រុងរ៉ូម ។ ក្រោយមកត្រូវចេញចាកតំណែងការងាររបស់ខ្លួន ហើយបានមកនៅធ្វើការក្នុងគ្រួសាររបស់ខ្លួន ។ ក្នុងពេលនោះ លេសេប្រស៍ពុំបានលះបង់ការតស៊ូរបស់គេ

ទេ, តែពេលណាទំនេរការងារ គេក៏គិតដល់ផែនការណ៍ដីព្រៃកស៊ីអេស៍ ។

តមក, គេបានទទួលដំណឹងថា, ក្មៀនៃបិតារបស់គេម្នាក់ឈ្មោះមហាម៉ាត់អាលី បានលាចេញចាកតំណែងរាជការក្នុងប្រទេសអេហ្សិប្ត៍ហើយ ។ លេសេប្រស៍បានផ្ញើសំបុត្រទៅសួរមិត្តស្និទ្ធស្នាលម្នាក់ជាកុងស៊ុលហ៊ុលឡង់ដ៍ ដើម្បីចង់ដឹងការពិតនៃមរណកម្មរបស់បុគ្គលនោះ ព្រមទាំងបញ្ជាក់ឲ្យឆ្លើយនូវសំនួរមួយថា ការជីកព្រែកស៊ីអេស៍ល្មមធ្វើបានឬទេក្នុងពេលនេះ ។ ចំពោះសំនួររឿងជីកព្រែកនេះ បានត្រូវមិត្តរបស់គេឆ្លើយបដិសេធ ។

ច្រើនឆ្នាំមកទៀត, លេសេប្រស៍បានទទួលសំបុត្រចាកព្រះអង្គម្ចាស់សាអ៊ីតថា ព្រះអង្គត្រូវការចង់ជួបលេសេប្រស៍ក្នុងក្រុងគែរ៍ ព្រោះព្រះអង្គបានទទួលតំណែងជំនួសព្រះរាមរបស់ព្រះអង្គហើយ ។ លេសេប្រស៍មានសេចក្តីត្រេក

អរច្រើន, គេក៏បានធ្វើដំណើរទៅកាន់ប្រទេសអេសិប្ត៍ភ្លាម ។ គេបានអធិប្បាយអំពីរឿងជីកព្រែកស៊ុអេស៍ថ្វាយព្រះអង្គម្ចាស់សាអ៊ីតស្ដាប់, តែព្រះអង្គម្ចាស់សាអ៊ីតមិនហ៊ានសន្យាជាមួយលេសេប្សថា កិច្ចការទាំងអស់នឹងមិនមានបញ្ហាចោទមកលើឡើយ ។

ហេតុដែលនាំឲ្យព្រះអង្គម្ចាស់សាអ៊ីតរាប់អានលេសេប្ស-បស៍ ក៏ដោយសេចក្ដីទំនុកបម្រុង ដែលលេសេប្សបស៍ធ្លាប់បានធ្វើឲ្យព្រះអង្គក្នុងវ័យកុមារ ។ វេលាដែលលេសេប្សបស៍ផ្ដើមជីកព្រែកស៊ុអេស៍ ព្រះអង្គមិនហ៊ានឲ្យសម្បទានដោយអំ-ណាចរបស់ព្រះអង្គដោយដាច់ខាតឡើយ ព្រោះព្រះអង្គមានសេចក្ដីបារម្ភខ្លាចក្រែងស៊ុលតង់នៃទុរគីមិនយល់ព្រមផង ។

លេសេប្សបស៍, ត្រូវចេញធ្វើដំណើរទៅក្នុងប្រទេសច្រើនទៀត ។ ការផ្ដើមជីកព្រែកស៊ុអេស៍របស់គេស្ទើរតែនឹងរលំរលាយក្នុងពេលនោះ ព្រោះលេសេប្សបស៍ បានជួប

ឧបសគ្គគ្រប់ផ្លូវទាំងអស់ ។ ខ្លួនលេសេប្រស៍រកកល់នឹងត្រូវចោទថាជាអ្នកគៃបន្លំប្រាក់ហ៊ុន ដែលប្រទេសទាំងឡាយបានចូលក្នុងរឿងជីកព្រែកនេះ ។

នាយករដ្ឋមន្ត្រីអង់គ្លេសក្នុងសម័យនោះ បានប្រកាសដំណឹងមិនឲ្យជឿសម្ដីបោកប្រាសរបស់លេសេប្រស៍ រហូតដល់អ្នកកាន់អំណាចក្នុងប្រទេសដទៃៗ ខ្លះ ក៏មានយោបល់ដូចនាយករដ្ឋមន្ត្រីអង់គ្លេសដែរ ។ ចំណែកខាងស៊ុលតង់ក៏មិនយល់ព្រមឲ្យជីកព្រែកនេះឡើយ ។

សេចក្ដីព្យាយាមប្រកបដោយសេចក្ដីមានះ អត់ធន់នៃលេសេប្រស៍ពុំបានថយក្រោយទេ, ក្នុងពេលដែលគេបានទទួលសេចក្ដីលំបាកដល់ខ្នាតយ៉ាងនេះហើយ កិត្តិសព្ទរឿងជីកព្រែករបស់គេបានឮដល់ព្រះនាងអឺយ៉េនី ជាព្រះមហេសីនៃព្រះចៅណាប៉ូលេអុងទី ៣ ហើយត្រូវជាញាតិនឹងលេសេប្រស៍ផង, ព្រះនាងទ្រង់អង្វរព្រះរាជស្វាមី សូមឲ្យមានព្រះ

រាជសាសន៍ទៅកាន់ស៊ុលតង់ទួរគី ដើម្បីសូមឲ្យស៊ុលតង់ប្រគល់សម្បទានដល់លេសេប្រស ។

ដោយមានសេចក្ដីទំនុកបម្រុងអំពីមនុស្សចំនួនតិច ហើយមានសេចក្ដីព្យាបាទ អំពីមនុស្សមានចំនួនច្រើន លេស្សេបស៍ទើបបានត្រូវជួបប្រទះគ្រោះថ្នាក់ច្រើន ។ ក្នុងពេលនោះ អ្នកណានឹងធ្វើ ឬ មិនធ្វើយ៉ាងណាៗ នោះ មិនជាការនាំឲ្យកង្វល់ដល់ព្រះនាងអឺយេនីប៉ុន្មានទេ, ព្រះនាងគិតតែល្បួងលោមអង្វរព្រះរាជស្វាមីឲ្យជួយទំនុកបម្រុងអង្គការលេសេប្រស៍ឲ្យបានសម្រេចប៉ុណ្ណោះ, ក្នុងពេលនោះ ព្រះចៅណាប៉ូឡេអុងទី ៣ ព្រះអង្គទ្រង់ទំនុកបម្រុងតាមពាក្យស្នើសុំនៃព្រះមហេសី ដោយអាស្រ័យការទំនុកបម្រុងនៃព្រះចៅណាប៉ូលេអុងនេះ លេសេប្រស៍ក៏បានចាត់តាំងសហគ្រាស (ក្រុមហ៊ុន) ជីកព្រែកក្នុងកាលនោះឯង ។

ខាងក្រោយដែលរដ្ឋាភិបាលបារាំងសេស បានទទួល

ស្គាល់សហគ្រាសនេះជាផ្លូវការហើយ លេសេប្សស៍ក៏ចាប់ផ្ដើមធ្វើការភ្លាម ។ ក្នុងពេលកំពុងធ្វើការព្រះនាងអឺយ៉េនីបានទ្រង់ជួយទំនុកបម្រុងពេញកម្លាំងរបស់ព្រះនាង ។ ដូច្នេះហើយបានជាក្នុងឱកាស សម្ពោធបើកឲ្យប្រើប្រាស់ព្រែកជីកនេះ, លេសេប្សស៍បានថ្លែងសុន្ទរកថា បើកក្នុងនាមរបស់ព្រះនាងអឺយ៉េនី និងព្រះអង្គម្ចាស់សាអ៊ីត ព្រោះកិច្ចការដែលជាសិល្បសំខាន់ខាងគំនិតរបស់គេ បានសម្រេចដោយការឧបត្ថម្ភរបស់មនុស្សសំខាន់ទាំងពីរនេះ ។

ព្រែកជីកស៊ុអេស៍ ត្រូវបានគេធ្វើហើយស្រេចកាលអំពីថ្ងៃទី ១៧ ខែ ឧសភា គ.ស. ១៨៦៩ ។ លេសេប្សស៍ជាជាតិបារាំងសេសកើតក្នុង គ.ស. ១៨០៤ ស្លាប់ក្នុងឆ្នាំ១៨៩៤ រួមអាយុបាន ៨៩ ឆ្នាំ ។ លេសេប្សស៍បានតាំងចិត្តថានឹងជីកព្រែកប៉ាណាម៉ាទៀត, តែពុំទាន់បានជីកគាត់ក៏បានអស់ជីវិតទៅ ។ ព្រែកជីកស៊ុអេស៍ជាគមនាគមន៍ខាងផ្លូវទឹក, ជា

គមនាគមន៍ដែលគេសាងឡើង ដើម្បីធ្វើដំណើរខាងផ្លូវទឹកឲ្យបានឆាប់រហ័ស, ជាគមនាគមន៍ភ្ជាប់សមុទ្រម៉េឌីតេរ៉ាណេនិងសមុទ្រក្រហម នៅក្នុងទ្វីបអាហ្វ្រិកភាគខាងលិច ជាដែនដីនៃប្រទេសអេហ្សីប្ត៍ ។ ពួកនាវាចរក៏អាចធ្វើដំណើរតាមផ្លូវនេះបានដោយស្រួល ដោយមិនចាំបាច់ធ្វើដំណើរវាងទ្វីបអាហ្វ្រិកដូចពីដើម ។ នេះគឺជាការតស៊ូមួយ ដែលជីវិតលេសេប្រស៍បានធ្វើឲ្យសម្រេចដើម្បីជាប្រយោជន៍របស់ខ្លួន និងជាប្រយោជន៍នៃប្រជាជនក្នុងពិភពលោក ។

ព្រែកជីកស៊ុអេស៍ ជាគមនាគមន៍ភ្ជាប់សមុទ្រម៉េឌីតេរ៉ាណេទៅក្នុងសមុទ្រក្រហម រហូតទៅដល់មហាសមុទ្រឥណ្ឌា ដើមទុនជីកព្រែកនេះមានចំនួន ៨,០០០,០០០ ប៉នដ៍ ក្នុងលើកដម្បូង ។ គម្រោងការជីកព្រែកនេះចាប់ផ្តើមតាំងអំពីក្នុងឆ្នាំគ.ស. ១៨៥២ ជីកហើយស្រេចក្នុង ឆ្នាំ គ.ស. ១៨៦៩ រួមវេលា ១៧ ឆ្នាំ ។

ព្រែកនេះមានបណ្តោយ ១០០ ម៉ៃល៍ ជម្រៅក្នុងអតីតកាល២៧ ហ្វុត ។ ក្នុងបច្ចុប្បន្នកាល ៣០ ហ្វុត ។ ទទឹងក្នុងអតីតកាលមាន ៧២ ហ្វុត ។ ក្នុងបច្ចុប្បន្នកាល ១៤៧ ហ្វុត ។ ក្នុងអតីតកាលនាវាបន្ទុក មានកម្រិតទម្ងន់ ២.៧.០០០ តោន ។ ក្នុងអតីតកាលរយៈវេលាបើកបរនាវាក្នុងផ្ទៃព្រែក ៤៨ ម៉ោង ។ ក្នុងបច្ចុប្បន្នកាល ១៥ ម៉ោង ។ កាលអំពីក្នុងឆ្នាំ គ.ស. ១៩-២៧ មាននាវាឆ្លងកាត់ព្រែកនេះ រួមទាំងអស់ ៥,៥០០ ក្បាល រួមទម្ងន់ទាំងអស់ ២៩ លានតោន ។

ជីវិត

## ហ៊ីត្លែរ៍

ការឡើងកាន់អំណាចក្តី ការគ្រប់គ្រងអំណាចក្តី ហ៊ីត្លែរ៍មានសេចក្តីលំបាកច្រើន ព្រោះក្នុងប្រទេសអល្លឺម៉ង់ ជាប្រទេសមានសេចក្តីនិយមទំនៀមទម្លាប់ប្រពៃណីខ្លាំង ។ ទាហានអល្លឺម៉ង់មានវណ្ណៈមួយផ្សេងអំពីប្រជាជនធម្មតា , ការប្រកាន់វណ្ណៈខ្ពស់ទាបជាការនាំឲ្យអ្នកដឹកនាំ មានសេចក្តីកង្វល់ក្នុងរបៀបគ្រប់គ្រងឥតស្រាកស្រាន្ត ។ ហ៊ីត្លែរ៍ (អ្នកផ្តាច់ការអល្លឺម៉ង់) ធ្វើការបានសម្រេចដូចបំណង ក៏ព្រោះអាស្រ័យមនុស្សអ្នកជំនាញការល្អៗ ជាដៃគូ ។ អ្នកសង្កេតការណ៍ទាំងឡាយបាននិយាយថា ហ៊ីត្លែរ៍មានមនុស្សបម្រើល្អៗ ជាងរដ្ឋបុរសដទៃៗ ក្នុងសម័យផងគ្នា ។ សម្រាប់ភ្នាក់ងាររដ្ឋការប្រចាំតំណែង, គេសង្កេតឃើញមានមនុស្សល្អបំផុត ដែលប្រទេសទាំងឡាយក្នុងអឺរ៉ុបដូចគ្នាមិនមាន ។ កម្មវិធី

គ្រប់គ្រងរបស់ហ៊ីត្លែរ៍ និងកម្មវិធីនៃរដ្ឋបុរសដទៃៗ មានរបៀបខុសគ្នា ។ រដ្ឋបុរសខ្លះធ្លាប់បាននិយាយថា ខ្លួននឹងកាន់អំណាចឲ្យបានដល់ទីបំផុត ឬ ឲ្យបានយ៉ាងយូរតាមដែលអាចធ្វើបាន ។ បំណងហ៊ីត្លែរ៍ធ្លាប់និយាយថា អ្នកដឹកនាំមានពេលអាចស្លាប់បាន, អាចផ្លាស់ប្តូរបាន, តែគណៈបក្សណាស៊ីត្រូវតាំងនៅជាប់រហូតមិនមានពេលផ្លាស់ប្តូរទេ ។

រដ្ឋបុរសខ្លះ, ធ្លាប់និយាយថា កាលណាខ្លួនអស់បុណ្យទៅនឹងបានអ្នកណាជាអ្នកតំណាង? តែហ៊ីត្លែរ៍បានតាំងអ្នកតំណាងជាស្រេចតាំងអំពីខ្លួនមានជីវិតរស់នៅ ។ ការដែលហ៊ីត្លែរ៍មានមនុស្សល្អៗ ជាដៃគូ អ្នកសង្កេតការណ៍យល់ឃើញដោយហេតុពីរប្រការគឺៈ

១) ការជ្រើសរើសសមត្ថភាពរបស់មនុស្ស, គេធ្វើឡើងដោយស្រាវជ្រាវប្រវត្តិយ៉ាងល្អិតល្អន់ ជាពិសេសគឺច្រើនតែហ៊ីត្លែរ៍ទទួលជម្រើស អំពីគណៈកម្មការហើយវិនិច្ឆ័យផ្ទាល់ខ្លួន

មួងទៀត ។

២) ភ្នាក់ងាររដ្ឋការដែលហ៊ីត្ល៊ែរបានជ្រើសសម្រេចខ្លួនឯងហើយ, បានតែងតាំងជាស្រេចហើយនោះ ប្រសិនបើមានសមត្ថភាពទន់ខ្សោយឬប្រព្រឹត្តទុច្ចរិតក្នុងនាទីនោះក្រៅអំពីត្រូវដកហូត ឬ បណ្តេញចេញតាមវិន័យភ្នាក់ងាររដ្ឋការទាំងពីរយ៉ាងនេះហើយ, ច្រើនត្រូវធ្វើឃាត (លបសម្លាប់) ហើយថែមទាំងចាប់ខ្លួនឃាតករមិនបានទៀតផង ។

ខាងផ្លូវសាសនា គេមិនបានដឹងប្រាកដថា ហ៊ីត្ល៊ែរនិយមរាប់អាននិកាយណា ឬ សាខាណាទេ, តែហ៊ីត្ល៊ែរមានសេចក្តីជ្រះថ្លាចំពោះព្រះម្ចាស់សួគ៌ ។ ហ៊ីត្ល៊ែរចូលចិត្តនិយាយជាមួយអ្នកតំណាងការសែតផ្សេងៗ ថា ខ្លួនគេមានសេចក្តីជឿជានិច្ចថា ព្រះជាម្ចាស់សួគ៌ នឹងមិនលះបង់ចោលប្រទេសអល្លឺម៉ង់ឡើយ, ព្រះជាម្ចាស់នឹងរក្សាថែទាំខ្លួនដើម្បីឲ្យមានជីវិតរស់នៅ សម្រាប់ដឹកនាំប្រទេសអល្លឺម៉ង់

ឲ្យបានទទួលសេចក្ដីស្មើមុខជាមួយប្រទេសដទៃៗ ។ ហ៊ីត្ល័រមិនទទួលទានសាច់ដូចរដ្ឋបុរសដទៃខ្លះៗ ទទួលទានតែបាយ (នំប៉័ង) បន្លែ មិនផឹកសុរា មិនជក់បារី ។ ក្រៅអំពីមិនផឹកសុរា មិនជក់បារី មានការមិនផឹកកាហ្វេនិងទឹកតែទៀតផង ។ ការហាត់ប្រាណរបស់ហ៊ីត្ល័រមិនដូចរដ្ឋបុរសខ្លះៗ ទេ គឺក្រៅអំពីដើរកំសាន្ដបន្ដិចបន្ដួចនោះហើយ ហ៊ីត្ល័រ ក៏មិនលេងកីឡាដទៃៗ មិនជិះសេះមិនបររថយន្ដខ្លួនឯង ។ រដ្ឋបុរសខ្លះទទួលទានដំណេកអំពីក្បាលល្ងាចក្រោកចាកដំណេកអំពីពេលព្រឹកភ្លឺស្រាង ។ តែហ៊ីត្ល័រ ទទួលទានដំណេកយប់ជ្រៅ ភ្ញាក់ពេលថ្ងៃយ៉ាងចាស់ ។ តាមធម្មតា ហ៊ីត្ល័រច្រើនទទួលទានដំណេកមោង ២ ភ្ញាក់ពេលជិតថ្ងៃត្រង់ វៀរលែងតែមានធុរៈ ជាចំបាច់ ទើបក្រោកអំពីព្រឹក ។ កិច្ចការផ្សេងៗ ហ៊ីត្ល័រធ្វើក្នុងពេលថ្ងៃរសៀល ការប្រជុំ ឬសន្និសីទ ច្រើនធ្វើក្នុងពេលយប់ ។

តែយ៉ាងណាក៏ដោយ សម្រាប់សេចក្ដីធន់ទ្រាំខាងផ្លូវរូបកាយនោះ ហ៊ីត្លែរមានសេចក្ដីខ្លាំងពូកែដូចអ្នកផ្ដាច់ការឯទៀតៗ ដែរ ។ កាលហ៊ីត្លែរមានអាយុ ៥០ ឆ្នាំ សក់មិនស្កូវ ក្បាលមិនត្រងោល អាយុកាន់តែច្រើន រូបកាន់តែល្អ ប្រសិនបើគេយករូបថតរបស់ ហ៊ីត្លែរអំពីកាលអាយុ ២៥-២៦ ឆ្នាំទៅប្រៀបធៀបនឹងរូបថតកាលមានអាយុ ៥០ ឆ្នាំក៏មិនសូវប្លែកគ្នាប៉ុន្មាន ។ ហ៊ីត្លែរជាបុគ្គលម្នាក់មានការចាំសាច់មិនសូវចាស់តាមវ័យ សេចក្ដីធន់ទ្រាំក្នុងការងារធ្ងន់ៗ ក៏ពូកែមិនចាញ់រដ្ឋបុរសដទៃៗ ខ្លះ ។ ក្នុងពេលកើតបញ្ហារឿងផ្សាយអំណាចទៅក្នុងអាណាខេត្តរ៉ែន៍ ហ៊ីត្លែរអាចធ្វើការបានពីរយប់ពីរថ្ងៃ ដោយមិនបានទទួលទានដំណេក រហូតដល់យប់ទី ៣ ទើបចប់រឿងរ៉ាវទាំងអស់ ។ លុះអស់រឿងហើយក៏មិនបានទទួលទានដំណេក ត្រឡប់ជាមានការលៀងអាហារនិងបញ្ចាំងភាពយន្តជាប់តៗ គ្នា រហូតដល់ម៉ោង ២ យប់

ទើបសម្រាក ។

ហ៊ីត្លែរមិនចេះភាសាដទៃក្រៅអំពីភាសាអល្លឺម៉ង់ ។ សៀវភៅភាសាបរទេសអានមិនចេញ តែសៀវភៅភាសាអ-ល្លឺម៉ង់ ហ៊ីត្លែរអានច្រើនណាស់ ។ ប្រភេទសៀវភៅដែលហ៊ីត្លែរចូលចិត្តជាទីបំផុត គឺទស្សនវិជ្ជា និងប្រវត្តិសាស្ត្រ ហ៊ីត្លែរមិនចេះភ្លេងច្រើនដូចរដ្ឋបុរសខ្លះៗទេ តែជាបុគ្គលចូលចិត្តភ្លេងច្រើនបំផុត ។ ហ៊ីត្លែរចូលចិត្តអាងថា ខ្លួនជាអ្នកតន្ត្រី ។ រឿងខ្លះក្នុងល្ខោនអូប៉េរ៉ា ហ៊ីត្លែរធ្លាប់និយាយប្រាប់គេថាខ្លួនបានមើល ១០០ ដងមកហើយ បទភ្លេងរបស់វ៉ាគ្នឺរ ជាបទភ្លេងមានឥទ្ធិពលលើជីវិតរបស់ហ៊ីត្លែរច្រើន ។ ក្នុងថ្ងៃដែលមានធ្វើការសំខាន់ៗ ហើយរង់ចាំស្ដាប់លទ្ធផលនៃការងារថានឹងបានសម្រេច ឬ ពុំបានសម្រេចនោះ ហ៊ីត្លែរច្រើនទៅមើលល្ខោនអូប៉េរ៉ា ។ ការប្រជុំរដ្ឋសភាតាមប្រក្រតីច្រើនប្រជុំក្នុងរោងល្ខោន វេលាប្រជុំហើយ ក៏ចាប់បើកឆាក

ស្ដេងល្ខោនអូប៉េរ៉ា ឲ្យសមាជិករដ្ឋសភាមើល ។ យប់ណា ដែលមានសេចក្ដីព្រួយច្រើន, មានរឿងស្មុគស្មាញក្នុងចិត្ត ដេកមិនលក់, ហ៊ីត្លែរហៅមនុស្សមកកូតវីអូលីនឲ្យស្ដាប់ ទើបដេកលក់ ។

សេចក្ដីពិត, ហ៊ីត្លែរជាអ្នកសិល្បៈគ្រប់វិស័យ ។ យើង ធ្លាប់ដឹងហើយថា បឋមសិក្សារបស់ហ៊ីត្លែរនោះគឺការសិក្សា ខាងហត្ថសិល្បៈ វិជ្ជាជាងគំនូរ ។ ក្នុងពេលកំពុងទាល់ក្រ ហ៊ីត្លែរចិញ្ចឹមពោះដោយគូររូបភាពលក់, តែសមត្ថភាពខាង ជាងគំនូរនោះ ពុំបានជាល្អប៉ុន្មានទេ ។ គ្រូម្នាក់បានណែនាំ ឲ្យហ៊ីត្លែររៀនវិជ្ជាស្ថាបត្យកម្ម សឹងក្រោយមកហ៊ីត្លែរក៏ពេញ ចិត្តច្រើនក្នុងវិជ្ជាផ្នែកនេះ ។ ការសាងផ្ទះឬធំៗ ឬ ស្ថាន ទីសំខាន់ៗ ក្នុងប្រទេសអាល្លឺម៉ង់ សម័យហ៊ីត្លែរមានអំណាច នោះ ភាគច្រើនហ៊ីត្លែរជាអ្នកឲ្យគំនិតក្នុងការចេញផែនទី និង ជាអ្នកត្រួតពិនិត្យមើលដោយខ្លួនឯង ដើម្បីឲ្យសំណង់នោះ

ត្រឹមត្រូវតាមផែនទី ។

ហ៊ីត្លែរ មានសេចក្ដីចេះចាំល្អ ដូចបុគ្គលសំខាន់ទាំងឡាយធ្លាប់ចេះចាំដែរ ។ ហ៊ីត្លែរ មិនបានទទួលប្រាក់ខែក្នុងតំណែងនាទីនៃកិច្ចការរបស់រដ្ឋទេ គឺធ្វើការឲ្យប្រទេសដោយមិនគិតតម្លៃឈ្នួល តែហ៊ីត្លែរមានចំណូលជាចំនួនច្រើនអំពីការលក់សៀវភៅ ជាពិសេសគឺសៀវភៅរឿង "ការតស៊ូរបស់ខ្ញុំ" សរសេរដោយដៃរបស់ហ៊ីត្លែរ ។ សៀវភៅនេះបានធ្វើឲ្យហ៊ីត្លែរ មានចំណូលគិតជាប្រាក់ខ្មែរយើងក្នុងមួយឆ្នាំប្រមាណជា ៥-៦ លានរៀល ។ ក្រៅអំពីនេះសុន្ទរកថា មួយៗ ដែលថ្លែងដោយហ៊ីត្លែរ កាលណាបោះពុម្ពចំណាយ ក៏បានប្រាក់មានចំនួនមិនតិចឡើយ, តែប្រាកដថា ចំណូលអស់ទាំងនេះមានភាគច្រើនដែលចាយទៅក្នុងកិច្ចការរបស់រដ្ឋ ។ ចំណែកផ្ទាល់ខ្លួនរបស់ហ៊ីត្លែរឯងស្ទើរតែមិនមានការចាំបាច់ត្រូវចាយប្រាក់ ឬ ទុកប្រាក់ ព្រោះហ៊ីត្លែរ

មានសេចក្ដីសន្ដោសនៅក្នុងខ្លួន ការតែងកាយរបស់ហ៊ីត្លែរ មានឯកសណ្ឋានតែមួយមិនមានផ្លាស់ប្ដូរច្រើនឡើយ ។

វដ្ឋបុរសខ្លះ មានប្រក្រតីជួយទំនុកបម្រុងបងប្អូនញាតិមិត្ត ។ ការងារសំខាន់ ៗ លើកឲ្យបក្សពួក ឬ គ្រួសាររបស់ខ្លួន ។ ចំណែកហ៊ីត្លែរមិនយ៉ាងដូច្នោះទេ ឋានៈនៃញាតិមិត្តបងប្អូនរបស់ខ្លួន ធ្លាប់ទាល់ក្រមកអំពីដើមយ៉ាងណា វេលាហ៊ីត្លែរបានឡើងកាន់ឋានៈធំដុំហើយ ក៏គង់មានឋានៈយ៉ាងនោះ ដូចប្រក្រតីដើមទាំងអស់គ្នា ។ ការហ៊ឹកហ៊ាក់ហ៊ឺហារបស់ហ៊ីត្លែរមានតិចជាងវដ្ឋបុរសដទៃៗខ្លះ ។ មុស្សូលិនីបានឲ្យមនុស្សទាំងឡាយនូវរូបថតរបស់ខ្លួនមានចំនួនរាប់ពាន់ តែជនដែលបានរូបថតរបស់ហ៊ីត្លែរ អំពីហ៊ីត្លែរនោះមានចំនួនមិនដល់ ១៥ នាក់ទេ ។

លក្ខណៈសំខាន់ក្នុងខ្លួនហ៊ីត្លែរ គឺការគិតពិតប្រាកដមានសេចក្ដីគួសដៅទៀងទាត់ ។ ហ៊ីត្លែរធ្លាប់ផ្លាស់ប្ដូរកុស-

លោបាយ, ផ្លាស់ប្តូរកម្មវិធី, តែសេចក្តីគួសដៅពុំដែលផ្លាស់ប្តូរទេ ។ សត្រូវរបស់ហ៊ីត្លែរចូលចិត្តនិយាយថា ហ៊ីត្លែរ ជាមនុស្សប្រចូលចិត្តនិយាយកុហក ។ ការពិតហ៊ីត្លែរធ្លាប់ធ្វើការខុសពាក្យសន្យា (សញ្ញា) របស់ខ្លួនច្រើនដងមែន, តែជាការកុហកដោយផ្លាស់ប្តូរកុសលោបាយ និងកម្មវិធីប៉ុណ្ណោះទេ, ចំណែកសំដីគួសដៅ ឬ ឧត្តមគតិដ៏ពិតប្រាកដក្នុងការសាងកម្លាំងនៃប្រទេសអល្លឺម៉ង់ដ៏នោះ ហ៊ីត្លែរមិនធ្លាប់បានផ្លាស់ប្តូរឡើយ ។

ការផុតរលត់នៃជោគវាសនារបស់រដ្ឋបុរសខ្លះ បានប្រព្រឹត្តទៅដោយមិនដឹងខ្លួន មិនមានការប្រុងប្រៀបទុកជាមុន ទើបមិនមានមេរៀនល្អសម្រាប់អ្នកសិក្សា តែការផុតរលត់នៃជោគវាសនារបស់ហ៊ីត្លែរ មានមេរៀនល្អៗ សម្រាប់អ្នកសិក្សាជាច្រើន ព្រោះហ៊ីត្លែរបានដឹងខ្លួនមុន ហើយបានកំណត់ថ្ងៃនិងពេលស្លាប់របស់ខ្លួន ទាំងបានធ្វើឃាតខ្លួនឯង

តាមពេលដែលបានកំណត់ទុក ។

ដោយសៀវភៅនេះ មិនមែនជាសៀវភៅនយោបាយ (ការរដ្ឋ) អ្នកសិក្សាទើបគួរដឹងត្រឹមតែការតស៊ូរបស់ហ៊ីតៃ្លរ៍ ដើម្បីបំពេញមេរៀនខាងផ្នែកតស៊ូរបស់ខ្លួន ។ ចំណែកផលអាក្រក់ល្អខាងផ្លូវនយោបាយរបស់ហ៊ីតៃ្លរ៍នោះ មិនមែនជានាទីដែលសៀវភៅនេះត្រូវនិយាយដល់ឡើយ ។ កាលណាយើងបានកំណត់ព្រំដែននៃការសិក្សាត្រឹមតែរឿងការតស៊ូ ក្នុងជីវិតប៉ុណ្ណោះ សេចក្ដីផុតរលត់នៃជោគវាសនារបស់ហ៊ីតៃ្លរ៍ក៏ទៅជារឿងមួយ គួរឲ្យយើងយកចិត្តទុកដាក់សិក្សាយ៉ាងក្រៃលែង ព្រោះហ៊ីតៃ្លរ៍ជារដ្ឋបុរសម្នាក់ដែលបានតស៊ូលុះដល់វារៈចុងក្រោយបង្អស់របស់គេ ។

ហ៊ីតៃ្លរ៍ធ្លាប់បាននិយាយថា ខ្លួននឹងលះបង់ជីវភាពនយោបាយក្នុងខាងចុងនៃជីវិត ។ ក្នុងសម័យសង្គ្រាមលោកលើកទី ២ ហ៊ីតៃ្លរ៍បាននិយាយទៅកាន់ឯកអគ្គរាជទូតអង់គ្លេស

ថា សេចក្ដីប្រាថ្នាចុងក្រោយបង្អស់របស់ខ្ញុំ គឺទៅសង់ផ្ទះមួយខ្នងនៅក្នុងស្រុកលីនស៍ ខ្ញុំចូលចិត្តនៅស្ងាត់ៗ ម្នាក់ឯងខ្ញុំនឹងមិនទាក់ទងជាមួយការរដ្ឋតទៅទៀតឡើយ ។ ក្នុងពេលដែលសង្គ្រាមកំពុងប្រព្រឹត្តទៅ ហ៊ីត្លែរ៍ធ្លាប់បាននិយាយរឿយៗ ថា កាលណាសង្គ្រាមចប់, ខ្ញុំនឹងលាលោកនយោបាយទៅមានជីវិតនៅស្ងាត់ៗ ។ សម្ដីនេះស្ដែងឲ្យឃើញថា អំណាចក្នុងផ្លូវនយោបាយនោះ មិនមែនជាសេចក្ដីសុខសប្បាយ មិនមានអ្នកណាប្រាថ្នាចង់បានអស់មួយជីវិតឡើយ តែជោគជតាជារបស់មានពុតត្បុត បុគ្គលដែលចូលចិត្តនិយាយយ៉ាងនេះ ច្រើនតែត្រូវស្លាប់ក្នុងការរដ្ឋរបស់ខ្លួនទ្រនុះឯង ។

ក្នុងជីវិតរុងរោចន៍របស់ហ៊ីត្លែរ៍ (ក្នុងសម័យមានអំណាច) គេបានឮឈ្មោះជនសំខាន់ៗ នៅក្បែរខាងហ៊ីត្លែរ៍ ៤ នាក់គឺ៖

គេរិង, ជាអ្នកបញ្ជាការកងទ័ពអាកាស, ជាប្រធានរដ្ឋ-

សភា.... , ជាទាយាទ[១] របស់ហ៊ីត្លែរ គឺក្នុងវិន័យកម្មជាផ្លូវការបានចែងថា បើហ៊ីត្លែរស្លាប់ទៅ, គេរិងត្រូវបានជាប្រមុខណាស៊ីស៍......តទៅ ។

ហ៊ីស, ជាបុគ្គលដែលហ៊ីត្លែរមានសេចក្ដីស្រឡាញ់រាប់អាន, មានសេចក្ដីស្និទ្ធស្នាលនិងមានសេចក្ដីទុកចិត្តជាទី ២ ក្នុងវិន័យកម្មបានចែងថា បើហ៊ីត្លែរស្លាប់ទៅ បុគ្គលនេះត្រូវបានជាទាយាទទី ២ ។

អ៊ិមលែរ, ជាចាងហ្វាងប៉ូលីសនគរបាល, មាននាទីការពារសន្តិសុខប្រជារាស្ត្រ ហ៊ីត្លែរបានឲ្យអំណាចពិសេសដើម្បីគ្រប់គ្រងរក្សារបបណាស៊ីស៍ ។ ដោយអាស្រ័យអំណាចពិសេស, បុគ្គលនេះចង់សម្លាប់អ្នកណាក៏បាន ។

គោបែលស៍, ឃោសកជនអណ្ដាតមាស, បុគ្គលនេះបានធ្វើប្រយោជន៍ឲ្យហ៊ីត្លែរយ៉ាងច្រើន តែជាមនុស្សដែល

---

១- ទាយាទ ប្រើជំនួសពាក្យមត៌ក បើនឹងហៅថា រជ្ជទាយាទវិញក៏បាន ។

ហ៊ីត្ល័រមានសេចក្ដីសរសើរយ៉ាងតិចបំផុត ព្រោះគោបេលស៍ជាអ្នកធ្វើការជំនួសហ៊ីត្ល័រខាងសម្ដី ការណាដែលហ៊ីត្ល័រមិនហ៊ាននិយាយគោបែលស៍និយាយជំនួស ទើបមានគេស្អប់ច្រើន ហើយគេព្រះញាត់ឲ្យហ៊ីត្ល័រស្អប់ផង ។ ហ៊ីត្ល័រដឹងថា មានមនុស្សស្អប់គោបែលស៍ច្រើន បានជាមិនហ៊ានសរសើរគោ-បែលស៍ ដូចជនដទៃៗ, តែសំអប់ដែលមានមកលើគោ-បែលស៍ ក៏កើតមកតែអំពីបម្រើហ៊ីត្ល័រដោយសេចក្ដីស្មោះត្រង់ ។ គោបែលស៍ទើបទៅជាជនម្នាក់មានសេចក្ដីអក័ព្វ ក្នុងជីវភាពនយោបាយរបស់ខ្លួន ។

សង្គ្រាមកន្លងទៅបានពីរឆ្នាំ, ហ៊ីសរត់ទៅនៅជ្រកក្នុងប្រទេសអង់គ្លេស ។ គេរិង និង អិមលែរ៍ បែកចិត្តអំពីហ៊ីត្ល័រដោយទាំងអស់គ្នាមើលឃើញថា សង្គ្រាមរបស់ខ្លួនមានបរា-ជ័យកាន់តែខិតជិតមកបន្ដិចម្ដងៗ ។ គោបែលស៍ម្នាក់ឯងនៅមានចិត្តស្មោះត្រង់ជាមួយហ៊ីត្ល័រ លុះដល់វារៈចុងក្រោយ

បង្អស់ ។ ក្នុងខណៈដែលហ៊ីត្ល័រត្រូវស្លាប់ដោយបាញ់ខ្លួន គោបែលស៍ ព្រមទាំងភរិយានិងបុត្រ ៦ នាក់ក៏សុខចិត្តស្លាប់ ជាមួយហ៊ីត្ល័រដោយគ្រាប់កាំភ្លើង និងថ្នាំបំពុល ។

ព្រឹត្តិការណ៍ដូចនេះ, មានច្រើនក្នុងជីវប្រវត្តិនៃឥស្សរ-ជនធំៗ ។ ការធ្លាក់ចុះនៃជោគវាសនារបស់ឥស្សរជនធំៗ ច្រើនកើតឡើងអំពីការមើលមនុស្សខុស, អ្នកធ្វើការបាន ច្រើនៗ លះបង់ប្រយោជន៍ផ្ទាល់ខ្លួនធំៗ ច្រើនតែពុំសូវ បានទទួលសេចក្ដីសរសើរ ។ ចំណែកបុគ្គលដែលធ្វើការ តិច គិតប្រយោជន៍ផ្ទាល់ខ្លួនច្រើន ហើយដែលត្រូវបាន ទទួលលើកតម្កើង ឬ សរសើរនោះ ចុងក្រោយបង្អស់ច្រើន តែកើតចិត្តមិនត្រង់ ឬ រត់ចោលជារឿយៗ ។

លក្ខណៈ រឹងប៉ឹងរបស់មនុស្ស គេសង្កេតបានដោយ សមត្ថភាព ម៉្យាងទៀត គឺការរក្សាអាថ៌កំបាំង ។ មនុស្ស ទន់ខ្សោយដោយលក្ខណៈ ច្រើនរក្សាអាថ៌កំបាំងរបស់ខ្លួន

ពុំសូវបាន, ច្រើនទុកចិត្តអ្នកដទៃ, ច្រើនយកអាថ៌កំបាំង របស់ខ្លួនទៅប្រាប់អ្នកដទៃងាយៗ ។ តែហ៊ីត្ល័រជាមនុស្ស ម្នាក់មានសមត្ថភាពរក្សាសេចក្ដីស្ងាត់កំបាំងបានពិតៗ សូម្បី អ្នកសរសេរសៀវភៅ ឬ អ្នកយកដំណឹងដែលខំប្រឹងជ្រៀត ជ្រែក ចង់ដឹងចង់ឮ ក៏មិនប្រាកដថាមានអ្នកណាម្នាក់ដឹងថា ហ៊ីត្ល័រមានភរិយាលបលាក់ក្រៅអំពីមនុស្សជិតដិតនឹងហ៊ីត្ល័រ។ ហ៊ីត្ល័រមានស្ត្រីក្រមុំល្អម្នាក់ឈ្មោះ អ៊ីវ៉ា-បេរ៉ាន់, ជាភរិយា លបលាក់ តាំងតែអំពីឆ្នាំដែលហ៊ីត្ល័របានទទួលអំណាចជា នាយករដ្ឋមន្ត្រី មុនបានធ្វើជាប្រមុខរដ្ឋនៃប្រទេសអល្លឺម៉ង់ ។

ជីវប្បវត្តិរបស់ អ៊ីវ៉ា-បេរ៉ាន់ មានដូចម្ដេចខ្លះ មិន មានអ្នកណាដឹងដល់ទេ, គេដឹងត្រឹមតែក្មួយស្រីម្នាក់ឈ្មោះ ... ជាងថតរូបប្រចាំហ៊ីត្ល័រម្នាក់ បានដឹកនាំឲ្យស្គាល់គ្នា ដោយ ហ៊ីត្ល័រមិនធ្លាប់មានប្រពន្ធ ។ ក្នុងពេលជួបគ្នានោះ អ៊ីវ៉ា បេរ៉ាន់មានអាយុប៉ុន្មានហើយក៏មិនមានអ្នកណាដឹង តែហ៊ី-

ត្រៃមានអាយុ ៤៤ ឆ្នាំហើយ ។ អ៊ីវ៉ា-បេរ៉ាន់ ជាស្ត្រីមានរូបល្អ មានសេចក្ដីចេះដឹងខ្ពស់ទាំងអក្សរសាស្ត្រទាំងសិល្បៈ ពូកែរាំគូ ពូកែលេងកីឡា មានសេចក្ដីឆ្លៀវឆ្លាតច្រើន តែមានលក្ខណៈខុសប្លែក អំពីប្រពន្ធលបលាក់របស់ឥស្សរជនធំដុំទាំងឡាយ គឺ អ៊ីវ៉ា-បេរ៉ាន់មិនទាក់ទងជាមួយការនយោបាយ, មិនទុកដាក់ខ្លួនឲ្យទៅជាគុណ ឬ ទៅជាទោសដល់ជនអ្នកនយោបាយ ។ អ្នកណាមកពឹងឲ្យជួយកិច្ចការអ្វីៗ ឬ ប្ដឹងផ្ដល់ចោទទោសគ្នា ដើម្បីឲ្យដឹងដល់ហ៊ីត្លែរ៍ អ៊ីវ៉ា-បេរ៉ាន់មិនទទួលទាក់ទង និងមិនព្រមធ្វើជាអ្នកនាំសាសន៍ឲ្យឡើយ ។

ហ៊ីត្លែរ៍ បានជួលផ្ទះឲ្យ អ៊ីវ៉ា-បេរ៉ាន់ នៅស្ងាត់ៗ ក្នុងជនបទ, ទើបតែមកនៅជាមួយគ្នានៅក្រុងប៊ែរឡាំងក្នុងពីរឆ្នាំក្រោយបង្អស់នៃអវសានជីវិតរបស់ខ្លួន ។ អ៊ីវ៉ា-បេរ៉ាន់ ទទួលនាទីតែមួយ គឺធ្វើឲ្យហ៊ីត្លែរ៍ បានសម្រាកកំសាន្តសប្បាយ ។ កាលណាហ៊ីត្លែរ៍មកកាន់ផ្ទះក្នុងជនបទគឺក៏ដឹង

ថាហ៊ីតៃ្វត្រូវការសម្រាក ។ អ៊ីវ៉ា បេវ៉ាន់ ដឹកនាំឲ្យ ហ៊ីតៃ្វ សប្បាយក្នុងកីឡាផ្សេងៗ មានឡើងភ្នំខ្ពស់ៗ ជាដើម ។ អ៊ីវ៉ា បេវ៉ាន់ មិនមានប្រាថ្នាអ្វីក្រៅអំពីធ្វើខ្លួនឲ្យជាមិត្រជីវិតរបស់ហ៊ីតៃ្វ, នេះក៏ជាហេតុមួយទៀតធ្វើឲ្យការអាថ៌កំបាំងកាន់តែមានសេចក្ដីជិតមិតឡើង ។ ជាងនេះទៅទៀត, អ៊ីវ៉ា-បេវ៉ាន់ ពុំដែលបានទាមទារយកប្រយោជន៍អ្វីសោះឡើយ, ទាំងហ៊ីតៃ្វសោតទៀត, ក៏ពុំបានឲ្យប្រាក់ខែទេ, តែអ៊ីវ៉ា បេវ៉ាន់ បានរស់នៅដោយសារជាងថតរូបចិញ្ចឹម ។ ការពិតចំណូលនេះក៏មិនមែនតិចទេ ព្រោះរូបថតរបស់ហ៊ីតៃ្វមានមនុស្សនិយមទិញច្រើនណាស់ ។ ចំណែកហ៊ីតៃ្វឯង, ក៏ធ្វើខ្លួនជាស្វាមីលបលាក់ស្មោះត្រង់របស់ អ៊ីវ៉ា-បេវ៉ាន់ គឺមិនទាក់ទងជាមួយស្ត្រីដទៃទៀតឡើយ ទោះជាពួកមិត្តរបស់ខ្លួនមាន គោបែលស៍ជាដើម ព្យាយាមដឹកនាំយកស្ត្រីល្មោនល្អៗ មកឲ្យក៏ហ៊ីតៃ្វមិនត្រូវការ ប្រែថា ហ៊ីតៃ្វ និង អ៊ីវ៉ា-

ប៉ាន់ មានចិត្តស្មោះត្រង់នឹងគ្នាដូចស្វាមីភរិយាមានមង្គលការពិតៗ ។

តែបញ្ហាដែលចោទឡើងថា ហេតុដូចម្ដេចទើបមិនមានមង្គលការនោះ, ចំពោះបញ្ហានេះ ហ៊ីត្ល័រធ្លាប់និយាយប្រាប់ពួកមិត្តថា កិច្ចធុរៈរបស់ប្រទេសច្រើនហួសពេក មិនអាចយកការៈដទៃមកបន្ថែមទៀតបាន ។ តែគំនិតរបស់ជនទូទៅនោះ គេចូលចិត្តថា ជារឿងទាក់ទងទៅលើចិត្តសាស្ត្រ គឺអ្នកផ្ដាច់ការម្នាក់ៗ ត្រូវមានគុណសម្បត្តិអ្វីមួយខុសប្លែកអំពីមនុស្សទាំងឡាយ ។ ហ៊ីត្ល័រមិនផឹកសុរា មិនជក់បារី មិនទទួលទានសាច់នោះ ទុកជាការបំពេញសីលធម្មតាមួយហើយ ថែមនៅលីវមិនយកប្រពន្ធមួយទៀត នាំឲ្យមនុស្សទាំងឡាយឃើញថា ហ៊ីត្ល័រមិនមែនជាមនុស្សសាមញ្ញទេ គឺជាបុរសបរិសុទ្ធ, ជាព្រហ្មចារីយ៍ ។ កាលណាប្រជារាស្ត្រជឿយ៉ាងនេះហើយ គេក៏មិនគួរនឹងរៀបមង្គលការ ឲ្យ

ប្រជាជនឃើញខ្លួនគេថាជាមនុស្សធម្មតាទៅវិញឡើយ ។

សង្គ្រាមបានដើរមកដល់ថ្នាក់ចាញ់គេពិតប្រាកដហើយ ហ៊ីត្លែរក៏បានចូលទៅនៅក្នុងឧមង្គក្រោមដី, មាន ជម្រៅ ២៥ ម៉ែត្រ, គ្រាប់បែកគ្រប់ខ្នាតខាងមិនដល់ ។ ឧមង្គនេះនៅចំកណ្តាលក្រុងប៊ែរឡាំង, ក្នុងចន្លោះទីស្តីការនាយករដ្ឋមន្ត្រីនិងទីស្តីការក្រសួងការបរទេស ។ តួឧមង្គគេធ្វើជាពីរជាន់ ក្នុងជាន់លើមាន ១២ បន្ទប់, ជាបន្ទប់បាយ ជាបន្ទប់ទុកដាក់របស់ផ្សេងៗ ជាបន្ទប់អ្នកបម្រើ ... ជាន់ក្រោមមាន ១៧ បន្ទប់ ជាបន្ទប់ដេករបស់ អ៊ីវ៉ា-បេរ៉ាន៍, ជាបន្ទប់របស់ហ៊ីត្លែរ, ជាបន្ទប់ធ្វើការ ជាបន្ទប់ប្រជុំ ជាបន្ទប់ម៉ាស៊ីនអគ្គិសនី ......... នៅលើខ្នងឧមង្គ, មានសួនច្បារតូចៗ, ហើយមានខ្សែលួសបន្ទាព័ទ្ធជុំវិញ មិនឲ្យមនុស្សចេញចូលបាន ។ នៅក្នុងឧមង្គនេះ ហ៊ីត្លែរបានធ្វើការបញ្ជាកងទ័ពគ្រប់កន្លែងដោយទូរសព្ទ តែកងទ័ពអាល្លឺម៉ង់ បានត្រូវគេវាយប្រាន

គ្រប់កន្លែង, ទាហានអល្លឺម៉ង់ដ៏ពុំអាចទប់ទល់បានឡើយ ។ ពួកមិត្តជិតស្និទ្ធនឹងពួកយុវជនបានសូមឲ្យហ៊ីត្ល័រ ចេញចាកក្រុងប៊ែរឡាំងទៅនៅកន្លែងដទៃទៀត តែហ៊ីត្ល័រមិនព្រមចេញ ដោយសម្រេចចិត្តថា: សូមស្លាប់នៅក្នុងក្រុងប៊ែរឡាំង ។

អ្នកជិតស្និទ្ធសង្កេតឃើញថា ហ៊ីត្ល័រជឿបុណ្យរបស់ខ្លួន ដោយជិតមួយឆ្នាំកន្លងមកហើយ ត្រូវពួកក្បត់គប់គ្រាប់បែកដើម្បីសម្លាប់ហ៊ីត្ល័រ តែគ្រាប់បែកពុំបានផ្ទុះ ។ ហ៊ីត្ល័រជឿថា ឋានសួគ៌ជួយខ្លួន, កាលណាខ្លួននៅក្នុងក្រុងប៊ែរ-ឡាំង ក្រុងនេះក៏មិនត្រូវបាក់បែក ទោះជាសត្រូវចោមវាយដោយគ្រាប់កាំភ្លើងដល់ថ្នាក់ណាក៏ដោយ ។

អំពីឧមង្គក្រោមដី, ហ៊ីត្ល័របញ្ជាកងទ័ពតាមវិទ្យុទូរ-សព្ទឲ្យកងទ័ពនេះទៅខាងនោះ ឲ្យកងទ័ពនោះមកខាងនេះ តែកងទ័ពទាំងអស់នោះ មិនមានសំឡេងឆ្លើយតបវិញសោះ

សោះឡើយ ព្រោះកងទ័ពមួយៗ ត្រូវគេវាយបាក់បែកគ្រឿងវិទ្យុទូរស័ព្ទអស់ មិនអាចធ្វើការឆ្លើយឆ្លងបានឡើយ ។

ថ្ងៃទី ២០ ខែ មេសា (១០ថ្ងៃមុនអវសានជីវិតរបស់ហ៊ីត្លែរ) ជាថ្ងៃកំណើតរបស់ហ៊ីត្លែរ មានមនុស្សមកប្រជុំឲ្យពរតាំងអំពីព្រឹករហូតដល់ល្ងាច ហ៊ីត្លែរបានចេញមកទទួលភ្ញៀវលើខ្នងឧម្មង្គ ហើយបានបំពាក់គ្រឿងឥស្សរិយយសឲ្យពួកយុវជនដែលមានចិត្តស្មោះត្រង់ចំពោះខ្លួន ។ ក្រៅអំពីនេះមិនមានអ្វីឲ្យសង្ឃឹមបានទេ ពួកឥស្សរជនធំៗ បានក្បត់វត្តបំណងរបស់ហ៊ីត្លែរអស់រលីងហើយ ។ មានតែគោបែលស៍ម្នាក់ទេ ដែលមានចិត្តស្មោះត្រង់ បាននាំប្រពន្ធកូនមកនៅក្នុងឧម្មង្គជាមួយហ៊ីត្លែរ ។

ហ៊ីត្លែរ មានសេចក្តីសង្ឃឹមលើកម្លាំងកងទ័ពរបស់ឧត្តមសេនីយ៍វេនដ៍ថានឹងជួយក្រុងប៊ែរឡាំងបាន ។ ក្រោយអំពីបានបញ្ជាដោយវិទ្យុទូរស័ព្ទទៅកាន់កងទ័ពនោះហើយ វេង

ចាំស្ដាប់ក៏មិនឃើញមកមិនព្រមឆ្លើយតបសោះ ។ ពួកទាហាន ដែលមានចិត្តស្វាមីភក្តិ បានសូមជាថ្មីទៀត តាមវិទ្យុទូរសព្ទ ឲ្យហ៊ីត្លែរប្រញាប់ប្រញាល់ចេញចាកក្រុងបែរឡាំង តែនៅ យូរទៅទៀតនឹងមិនមានផ្លូវចេញបានឡើយ ។ ហ៊ីត្លែរ បាន ឆ្លើយថា រឿងចេញចេញចាកចោលក្រុងប៊ែរឡាំង ខ្ញុំមិន ចេញជាដាច់ខាត ។

ហ៊ីត្លែរ បានទទួលទូរលេខពួកក្បត់មានគេរិងជាដើម ដែលសូមឲ្យហ៊ីត្លែរប្រគល់អំណាចគ្រប់គ្រងឲ្យខ្លួន ដោយអាង ដល់វិន័យកម្ម ដែលបានទុកដាក់ខ្លួនគេថាជាទាយាទនៃគណៈ ណាស៊ីស ។ សេចក្ដីនៃទូរលេខនេះ ធ្វើឲ្យហ៊ីត្លែរមានទឹក ក្អែកជោរជន់ ដោយនឹកតូចចិត្តដល់មនុស្ស ដែលខ្លួនស្រ- ឡាញ់និងទុកចិត្តជាទីបំផុត មកដណ្ដើមអំណាចតាំងអំពីខ្លួន នៅមិនទាន់ស្លាប់ ។ ហ៊ីត្លែរបានទុកដាក់ទូរលេខរបស់គេ រិង ថាជាពាក្យប្រឆាំងយ៉ាងដាច់ខាត និងជាការក្បត់ចំពោះ

ខ្លួន ។ ហ៊ីត្លែរបានប្រកាសបញ្ជាដកហូតគេរិង ចាកតំណែង នាទីគ្រប់យ៉ាង រួមទាំងតំណែងទាយាទនៃប្រទេសអាល្លឺម៉ង់ ដែលហ៊ីត្លែរបានប្រកាសតែងតាំងក្នុងពេលផ្ដើមសង្គ្រាមផង ។

ក្រោយពេលដែលបានដឹងច្បាស់ នូវទង្វើក្បត់របស់មនុស្សដែលខ្លួនស្រឡាញ់ ដែលខ្លួនបានលើកតម្កើងទាំងអស់នោះហើយ ហ៊ីត្លែរក៏បាននិយាយទៅកាន់អ្នកនៅជាមួយថា ខ្ញុំចូលចិត្តហេតុការណ៍ ដែលនាំឲ្យកងទ័ពរបស់យើងបាត់បង់ទៅទាំងកងៗ និងបរាជ័យនៃកងទ័ពទាំងនោះហើយ ។

ថ្ងៃទី ២៩ ខែមេសា ហ៊ីត្លែរបានបញ្ជាឲ្យគោបែលស៍ ចាត់ពិធីមង្គលការរបស់ខ្លួន ជាមួយអ៊ីវ៉ា-បេរ៉ាន៍ តាមពាក្យដែល គឺបានសូមថា គឺសុខចិត្តស្លាប់ជាមួយហ៊ីត្លែរ តែសូមឲ្យស្លាប់ក្នុងឋានៈជាម៉ាដាមរបស់ហ៊ីត្លែរ (លោកស្រីរបស់ហ៊ីត្លែរ) ។ គោបែលស៍បានតាមរកខ្លួននាយកទេសមន្ត្រីក្រុងប៊ែឡាំង (ចៅហ្វាយក្រុងប៊ែរឡាំង) លុះបានជួប

ហើយក៏បាននាំចូលទៅក្នុងឧម្មង្គ ។ មង្គលការក៏បានចាប់ផ្ដើមធ្វើភ្លាមនៅក្នុងឧម្មង្គនោះ ដោយនាយកទេសមន្ត្រីនៃក្រុងប៊ែរឡាំងជាអ្នកប្រកបពិធី ។ វេលាចុះឈ្មោះក្នុងបញ្ជីអត្រានុកូលដ្ឋាន អ៊ីវ៉ា-បេរ៉ាន់ ភ្លេចស្មារតីបានសរសេរឈ្មោះខ្លួន (បកតិនាម) ហើយ ក៏ចាប់សរសេរនាមត្រកូល (គោ-តនាម) ចាស់ ដោយដាក់អក្សរ B ជាតួដើម, តែត្រូវអ្នកនៅជិតខាងកែ: ទើបលុបតួ B ចេញហើយសរសេរថា អ៊ីវ៉ា-ហ៊ីត្លែរជំនួសវិញ តួអក្សរនេះហើយដែលជាហត្ថលេខាលើកដំបូង ហើយជាចុងក្រោយបង្អស់នៃជីវិតរបស់ខ្លួន ។

លុះស្រេចពិធីមង្គលការនេះហើយ ហ៊ីត្លែរក៏នាំភរិយាទៅជួបនាយទាហានក្នុងឧម្មង្គ ដែលនៅលើខ្នងនៃឧម្មង្គនោះកំពុងរោយចុះដោយគ្រាប់កាំភ្លើងរបស់សត្រូវ ។ ក្រោយអំពីបានចាប់ដៃគ្នាស្ដែងសេចក្ដីមេត្រីរួចហើយ ទាំងអស់គ្នាក៏អង្គុយទទួលទានអាហារតាមតុ ដែលគេចាត់ចែងជាស្រេច ។

ក្នុងពេលនោះមានការសន្ទនា ប្រាស្រ័យគ្នាជាច្រើនម៉ោង រឿងដែលនិយាយគ្នាច្រើនតែរឿងចាស់ៗ ដែលជាអនុស្សាវរីយ៍កន្លងទៅហើយ ។ ក្នុងទីបំផុតនៃការសន្ទនានោះ ហ៊ីត្លែរ៍ក៏បានប្រាប់ពួកមិត្តថា ខ្លួនខ្ញុំនឹងករិយារបស់ខ្ញុំសម្រេចចិត្តថានឹងសម្លាប់ខ្លួនព្រមៗគ្នា ហើយហ៊ីត្លែរ៍ក៏ចូលទៅក្នុងបន្ទប់មួយទៀត ប្រាប់លេខានុការិនី ឲ្យរៀបចំសរសេរបញ្ជីវិន័យកម្ម ។ ក្នុងវិន័យកម្មនោះមាន ២ ច្បាប់ មួយច្បាប់ជាវិន័យកម្មខាងរដ្ឋការ មួយច្បាប់ទៀតជាវិន័យកម្មផ្ទាល់ខ្លួន ។ ក្នុងវិន័យកម្មជាផ្លូវការនោះ ហ៊ីត្លែរ៍បានបណ្ដេញ គេរិង និងអ៊ិមលែរ៍ ចេញចាកគណបក្សណាស៊ីស៍ ចេញចាកតំណែងការនានា, ហើយបានតែងតាំងសេនាប្រមុខ នាវាចរដឺនិត្ស៍ ឲ្យធ្វើជាប្រធានាធិបតីនៃប្រទេសអល្លឺម៉ង់ ឲ្យគោបែលស៍ធ្វើជានាយករដ្ឋមន្ត្រី ជាមួយរដ្ឋមន្ត្រី ១៩ ក្រសួងទៀត តាមការជ្រើសរើសរបស់គោបែលស៍ ប្រែថា

ហ៊ីត្លែរបានបញ្ជាតែងតាំងរដ្ឋាភិបាលថ្មីដោយខ្លួនឯង ហើយដែលមានសេចក្ដីទុកចិត្តលើគោបែលស៍ ថាជាមនុស្សម្នាក់ទទួលបម្រើខ្លួនយ៉ាងស្មោះត្រង់ ក្នុងពេលកិច្ចការទាំងអស់បានដើរមកដល់កន្លែងទាល់ច្រក ។

ក្នុងវិន័យកម្មផ្ទាល់ខ្លួនរបស់ហ៊ីត្លែរនោះមានចែងថា ទ្រព្យសម្បត្តិរបស់ខ្លួនទាំងអស់ ត្រូវបានជាទ្រព្យសម្បត្តិរបស់គណៈបក្សណាស៊ីស៍ បើគណបក្សណាស៊ីស៍ត្រូវរលំរលាយទៅ ត្រូវបានជាទ្រព្យសម្បត្តិរបស់រដ្ឋអល្លឺម៉ង់, បើរដ្ឋអល្លឺម៉ង់ត្រូវរលំរលាយទៅទៀត ក៏មិនមានរឿងអ្វីនឹងនិយាយគ្នាតទៅទៀតឡើយ ។ ចំណែករូបចម្លាក់និងរូបគំនូរផ្សេងៗ ដែលហ៊ីត្លែរបានទិញដោយតម្លៃច្រើនៗ ត្រូវដាក់ទៅជាសម្បត្តិនៃពិពិធភណ្ឌស្ថានក្រុងលីនស៍ ។ សេចក្ដីក្នុងចំណុចចុងបំផុតនៃវិន័យកម្មមានប្រាប់ថា កាលណាខ្លួនខ្ញុំនិងភរិយារបស់ខ្ញុំស្លាប់ទៅហើយ សូមឲ្យនាំគ្នាដុតសពឲ្យអស់ភ្លាម ដើម្បីកុំ

ឲ្យសពខ្ញុំបានទៅនៅក្នុងដៃរបស់សត្រូវ ។ ក្រោយអំពីបាន
ចាត់ឲ្យធ្វើវិន័យកម្មស្រេចហើយ ហ៊ីត្លែរជាមួយភរិយាក៏បាន
នាំគ្នាចូលបន្ទប់ដំណេក ហើយបានទទួលដំណេកជាមួយគ្នា
អស់រយៈកាលមួយយប់នៃជីវិតអាពាហ៍ពិពាហ៍ ត្រឹមត្រូវតាម
ច្បាប់របស់ខ្លួន ។

វត្ថុធាតុគ្រប់យ៉ាងរមែងដើរមកដល់គំនូសចុងបំផុត ជា
ធម្មតាមិនមានរបស់អ្វីមួយនៅក្រៅបទបញ្ញត្តិនៃធម្មជាតិ ។
ថ្ងៃទី ៣០ ខែមេសាពេលរសៀល ហ៊ីត្លែរបានបញ្ជាឲ្យចាក់
ថ្នាំបំណាយសុនខដែលខ្លួនស្រឡាញ់ ។ វេលាល្ងាចហ៊ីត្លែរ
និងភរិយាបានចេញមកលាពួកមិត្ត ហ៊ីត្លែរបានចាប់ដៃគេ
ទាំងឡាយដោយមិនមាននិយាយអ្វីសោះ ។ ចំណែកអ្នក
ដទៃៗ មាននិយាយខ្លះ តែស្តាប់គ្នាមិនកើតជាសព្ទ មិន
កើតជាសេចក្តីអ្វីឡើយ ។ លុះលាគ្នាស្រេចហើយ ហ៊ី
ត្លែរជាមួយភរិយា ក៏បានត្រឡប់ចូលទៅក្នុងបន្ទប់របស់ខ្លួនវិញ

មួយស្របក់ស្រាប់តែឮសូរកាំភ្លើងប៉ុងមួយគ្រាប់ ។ មនុស្ស ទាំងអស់គ្នាក្នុងឧមង្គ មិនមានអ្នកណាមួយមានចលនាយ៉ាង ណាទេ ទាំងអស់គ្នាសម្ងំស្ងៀមរង់ចាំមួយស្របក់ធំទើបនាំ គ្នាចូលទៅក្នុងបន្ទប់នោះ គេទាំងឡាយបានឃើញហ៊ីត្ល័រ ដេកនៅលើកៅអីវែង សើមជោកទៅដោយឈាម ហ៊ី-ត្ល័របានសម្លាប់ខ្លួនដោយបាញ់កាំភ្លើងចូលតាមមាត់ ។ ចំ-ណែកអ៊ីវ៉ា-បេរ៉ាន់ ដេកស្លាប់នៅលើកៅអីវែងក្បែរគ្នា នឹង ហ៊ីត្ល័រ មានកាំភ្លើងនៅក្បែរខ្លួន តែមិនបានបាញ់ទេ, គេ ចូលចិត្តថា អ៊ីវ៉ា-បេរ៉ាន់បានត្រូវស្លាប់ដោយលេបថ្នាំបំពុល ។

ជីវិត

## វិសាខា

សុភាពស្ត្រីមានបញ្ញាឆ្លៀវឆ្លាត មានរូបល្អ មានសំ-
រស់កាយថ្លាអណ្តែត មានឈ្មោះថា "វិសាខា" ជាអ្នក
ឧបត្ថម្ភនូវគណៈសង្ឃនៃព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួន ។ វិ-
សាខារស់នៅក្នុងលោកនៃមនុស្ស ក្នុងឋានៈជាស្ត្រីមានត្រកូល
ស្តុកស្តម្ភ, ជាស្ត្រីបរិច្ចាគឲ្យទស្សនវិទូ ឲ្យសាសនាចារ្យ
នូវបេះដូងរបស់នាង ដើម្បីប្តូរយកសេចក្តីស្ងប់សម្រាប់ជីវិត ។

គឺជាធីតារបស់ពលមិត្រ ជាធីតាក្រមុំតែម្នាក់របស់បិតានៃ
នាង ។ ក្នុងពេលនោះមានព្រាហ្មណ៍ម្នាក់បានទទួលបញ្ជាអំពី
មិគារៈជាសេនាបតីឃ្លាំងឲ្យដើរស្វែងរកនារីក្រមុំប្រកបដោយ
គុណសម្បត្តិដើម្បីយកមកធ្វើជាកូនប្រសានៃខ្លួន ព្រាហ្មណ៍
បានដើរឆ្លងកាត់លំនៅឋាន ដែលនាងវិសាខាឈប់សម្រាក
ក្នុងដំណើរកំសាន្តសម្រាប់សប្តាហ៍ ។ ដំបូងព្រាហ្មណ៍ចោល
ភ្នែកតាមមើលដោយមិនសូវជាយកចិត្តទុកដាក់ ព្រោះមិនទាន់

ឃើញនូវអ្វីឲ្យជាចម្លែក ។

ក្មេងនារីរបស់វិសាខាទាំងអស់នោះ ក៏ចាប់ផ្តើមលេង សប្បាយជាមួយគ្នា ដោយប្រាសចាកការប្រុងប្រយ័ត្នខាងចរិយាសម្រាប់ស្ត្រី ដូចជារត់បោះជើងយ៉ាងវែងៗ លោតផ្លោះកាយយ៉ាងខ្ពស់ៗ ពង្រីលខ្លួនទៅមកយ៉ាងញាប់ៗ ពន្ទេងតន្ត្រីឲ្យមានសូរយ៉ាងឮ ជាមួយទំនុកចំរៀងដែលបើកមាត់យ៉ាងធំ តែវិសាខាតែម្នាក់ឯងត្រឡប់ជាមានឥរិយាបថយ៉ាងស្ងប់ស្ងៀមស្ថិតនៅក្នុង អាកប្បកិរិយាជាប្រក្រតី ទោះជាក្មេងស្ត្រីរបស់ខ្លួន មានចលនាខុសធម្មតាយ៉ាងណាក៏ដោយ ។

លុះដល់ស្រះទឹកមួយ នារីដទៃៗ នាំគ្នាផ្លាស់សំពត់ចេញអស់ ទុកនៅតែសំពត់ធម្មជាតិ ដែលម៉ែបែកឲ្យអំពីកំណើត គឺយកទឹកធ្វើជាសំពត់ ហើយនាំគ្នាហែលលេងក្នុងទឹកថ្លាឈ្វេង មើលយល់ដី ។ ចំណែកវិសាខាគឺផ្លាស់សំ-

ពត់ដូចស្ត្រីឯទៀតដែរ, តែនាងចុះទៅក្នុងទឹកហើយសន្សើមៗ លាត់សំពត់ឡើងលើបន្តិចម្តងៗ លុះខ្លួនបានស្លៀកសំពត់ទឹកហើយ នាងក៏ពាក់សំពត់លើមែកឈើ ដែលខ្លួនបានដោតនៅជិតខ្លួន ដើម្បីងាយស្រួលដល់ការចាប់យកសំពត់មកផ្លាស់សំពត់ទឹក ដោយប្រកចូលបន្តិចម្តងៗ ដូចអំពីកាលដកចេញ ។ វិសាខា ពុំមានចលនាហែលទៅមុជចុះទេ ព្រោះនាងមានចរិយាសិក្ខាថា ទឹកថ្លាពេកណាស់មិនគួរណាសប្បាយក្មេចខ្លួនជាស្ត្រីទេ ។

ក្រោយអំពីងូតទឹកហើយ មានការបែងចែកអាហារគ្នាញុំាំ, ស្ត្រីដទៃ ៗ ថាតែញុំាំក៏ញុំាំគ្រប់ក្រាប់តែម្តង លុះឆ្អែតស្កប់ស្កល់ហើយទើបឲ្យអាហារសំណល់ស្ត្រីបម្រើរបស់ខ្លួន តែវិសាខាបានចាប់បែងអាហារ ថ្នោងឲ្យស្ត្រីបម្រើរបស់ខ្លួនញុំាំជាមុន ហើយនាងញុំាំខ្លួនឯងក្នុងកាលខាងក្រោយ ដោយបរិមាណយ៉ាងល្មមសមគួរ ។

ក្នុងពេលធ្វើដំណើរត្រឡប់ ក្នុងកន្លែងណាមានទឹកដក់, ស្ត្រីទាំងឡាយ សុទ្ធតែបានដោះស្បែកជើងរបស់ខ្លួនចេញ, តែវិសាខានាងពុំបានដោះស្បែកជើងរបស់នាងទេ ។ ក្នុងកន្លែងណាមានព្រៃស្រោង ស្ត្រីទាំងឡាយបានបើកមួករបស់ខ្លួនចេញ តែវិសាខា នាងពុំបានបើកមួករបស់នាងចេញទេ ។ ឥរិយាបថចម្លែករបស់វិសាខា មិនត្រឹមតែធ្វើឲ្យព្រាហ្មណ៍ទឹកចិត្តឆ្ងល់ក្នុងចិត្តប៉ុណ្ណោះទេ គឺថែមទាំងគាត់ធ្វើសំនួរដូចតទៅនេះ ៖

ព្រាហ្មណ៍: "កូនស្រីសម្លាញ់ចិត្ត គឺជាកូនចៅនរណាគេ?"

វិសាខា: "នាងខ្ញុំជាធីតារបស់ពល[១] មិត្រ ចា៎ះ"

ព្រាហ្មណ៍: "កូនក្រមុំសម្លាញ់ចិត្ត កុំមានសេចក្តីអាក់អន់ចិត្តអ្វីហ្ន៎:, បើកូនស្រីអត់ទោសឲ្យ, អ៊ំសូមសួរបន្តិចទៀតថា: "ដូចម្តេចក្នុងខណៈដែលស្ត្រីដ-

(១) ពលមិត្ត ក្នុងកន្លែងខ្លះថា ធនញ្ជយៈ

ទៃៗ រត់, លោត, ផ្លោះ, ពង្រីលខ្លួន, ដើរ
របាំព្រមទាំងសម្ដែងចេញនូវចលនាផ្សេងៗ ដែល
ជាកិរិយាមិនសមគួរ តែកូនស្រីត្រឡប់ ជានៅ
ស្ងៀមធ្វើព្រងើយ តើយ៉ាងណាកូនក្រមុំអើ?"

វិសាខា: "លោកអើ ស្ត្រីក្រមុំជាទំនិញរបស់ឪពុកម្ដាយ,
ប្រសិនបើយើងចេះតែ លោត, ផ្លោះ, រត់,
ហក់, ចួនជាស៊ិយមានគ្រោះថ្នាក់បាក់ដៃ បាក់
ជើងនោះឪពុកម្ដាយត្រូវចិញ្ចឹមយើងអស់មួយជីវិត,
ព្រោះមិនមានកម្លោះណាមកសូមយើង យកទៅធ្វើ
ជាភរិយារបស់គេឡើយ" ។

ព្រាហ្មណ៍: " ល្អណាស់, កូនក្រមុំសម្ងាញ់ចិត្ត, ខ្ញុំស្ដាប់បាន
ចូលចិត្តហើយ ។ "ចុះស្ត្រីដទៃៗ គេដកយក
សំពត់ចេញពីខ្លួនអស់ហើយ ទើបចុះទៅងូតទឹក,
ចំណែកខាងនាងចុះក្នុងទឹកជាមុន ហើយទើបដក

យកសំពត់ ចេញជាខាងក្រោយ តើបញ្ហានេះយ៉ាងណា?"

វិសាខា: "ឱ, លោកអុំ, ស្ត្រីក្រមុំទាំងឡាយត្រូវតែចេះអៀនខ្មាស មិនសមគួរឲ្យមាននរណាម្នាក់មើលឃើញនូវរូបកាយរបស់ខ្លួន ដែលមិនមានសំពត់ស្លៀកពាក់ទេ" ។

ព្រាហ្មណ៍: "កូនក្រមុំសម្លាញ់ចិត្ត, នៅក្នុងនេះក៏មិនមាននរណាមើលឃើញនីសណាំ" ។

វិសាខា: "ចាំះលោកអុំ, លោកអុំនេះឯងជាអ្នកមើលឃើញ"

ព្រាហ្មណ៍: "ល្អណាស់, កូនក្រមុំសម្លាញ់ចិត្ត, រឿងមួយទៀតដែលអុំចង់ដឹងនោះ គឺស្ត្រីដទៃៗ, គី[១] មិនខ្វីរវល់អើពើដល់ស្ត្រីបម្រើឡើយ តែកូនស្រីត្រឡប់ជាចែកអាហារឲ្យស្ត្រីបម្រើរបស់ខ្លួនញុំាមុន តើដូច

---

(១) គី ជាពាក្យបុរិសសព្ទតាមប្រើជំនួសឈ្មោះស្ត្រី "បើជាបុរសថាគេ" ។

ម្តេចទើបធ្វើយ៉ាងនេះ?"

វិសាខា: "មានហេតុផលយ៉ាងនេះឯងចាស, លោកអ៊ំ, ក្នុងមួយថ្ងៃៗ យើងមានតែសេចក្ដីសប្បាយរីករាយភ្ញើតភ្ញើន, ចំណែកជនទាំងឡាយនេះ គ្នាត្រូវខំប្រឹងធ្វើការឲ្យយើងនឿយហត់ណាស់ ងូតញើសតាងទឹកជានិច្ចកាល" ។

ព្រាហ្មណ៍: "ល្អណាស់, កូនស្រី, ចុះហេតុដូចម្ដេចក្នុងពេលដើរលុយទឹកម្ដងៗ កូនស្រីមិនដោះស្បែកជើងចេញ?" ។

វិសាខា: "ព្រោះក្នុងទឹកមិនមាននរណាម្នាក់មើលឃើញនូវវត្ថុជាគ្រឿងមុតទាំងឡាយមានបន្លាជាដើមទេ, ខ្ញុំមិនត្រូវការឲ្យជើងរបស់ខ្ញុំ បានទទួលរបួសចាកវត្ថុមានមុខមុត ទើបខ្ញុំដើរទាំងស្បែកជើង!"

ព្រាហ្មណ៍: "ល្អដែរហើយ, កូនស្រីរបស់អ៊ំ ស្ត្រីទាំងឡាយ

គឺបិទតាំងយូក្នុងដំណើរចូលក្រោមម្ចប់ឈើ ព្រោះអាកាសក្រោមដើមឈើត្រូវបានថយកម្តៅ អស់ច្រើនហើយ ហេតុអ្វីកូនស្រីនៅតែកាន់តាំងយូដ-ដែល ឬមួយកូនស្រីមិនបានទទួលជាតុត្រជាក់?"

វិសាខា: "តែ លោកអ៊ំចាំះ រឿងនេះវាក៏ដូចជារឿងមុន គឺក្រៅអំពីមានអ្វីៗ ណាមួយធ្លាក់ចុះមក, ស្វាជា សត្វពើសនៅមិនស្ងៀម វានឹងកាច់មែកឈើចោល មកលើខ្លួនរបស់យើងលេងជាល្បែង(២) របស់វា, ជំ ជាងនេះទៅទៀត តាំងយូជាវត្ថុជាតុមួយ អាចជួយ ការពារនូវមែកឈើបាក់បានខ្លះដែរ" ។

ដោយសេចក្ដីពេញចិត្តចំពោះបញ្ញាវៃឆាប់រហ័សរបស់វិ-សាខា ព្រាហ្មណ៍នោះក៏បានចូលខ្លួនទៅរកមាតាបិតារបស់ វិសាខា ហើយបានស្នើសូមគឺឲ្យជាកិរិយានៃបុត្ររបស់សេដ្ឋី

(២) ល្បែង ប្រើជំនួសល្បែងតាមក្បួនវេយ្យាករណ៍ ។

ឈ្មោះ មិគារៈ, ដោយបរិយាយកថាមានដូចនេះ ៖

“នារីមានលក្ខណៈដូចនេះ បើបានជាកិរិយានៃបុរសណា បុរសនោះជាបុគ្គលមានវាសនាខ្ពស់បំផុត ជាបុត្តនៃឪពុកម្តាយណា ឪពុកម្តាយនោះជាបុគ្គលមានសេចក្តីសុខសម្រាប់លោកដល់ទីបំផុត ជាមិត្រនៃមនុស្សទាំងឡាយណា មនុស្សទាំងឡាយនោះ ជាបុគ្គលមានអនាគតទុក្ខមិនមាន ។ នាងមានមារយាទខ្ពស់, មានចរិយាថ្លៃថ្នូមានចិត្តមេត្តាករុណាអ្នកដទៃជាង៖ខ្លួនឯង, មានបញ្ញាឆ្លៀវឆ្លាតវៃវាងវៃក្នុងមុខការគ្រប់វិស័យ សូមមេត្តាអនុញ្ញាតឲ្យនាងមានគូជីវិត រៀបចំអាពាហ៍ពិពាហ៍ ជាមួយបុណ្ណវឌ្ឍនៈ ជាបុត្ររបស់ មិគារៈចុះ” ។

មាតាបិតារបស់វិសាខាយល់ព្រមផង ទើបរៀបចំមង្គលការតាមរបៀបប្រពៃណី ហើយបញ្ជូននាងឲ្យទៅនៅជាមួយស្វាមីក្នុងនគរសាវត្ថី ។

វិសាខា ជាមហាឧបាសិការបស់ព្រះបរមសាស្តា ជាស្ត្រីមានសទ្ធាជ្រះថ្លាក្នុងបុណ្យកុសល ១០០ ភាគ ១០០ តែមិគារៈបិតារបស់ស្វាមីនៃនាង រួមជាមួយមនុស្សក្នុងផ្ទះទាំងអស់របស់គេ, មិនបានដូចជានាងទេ ទោះជាយ៉ាងណាក៏ដោយ វិសាខាខំប្រឹងប្រតិបត្តិខ្លួនឲ្យជាទីស្រឡាញ់ពេញចិត្តនៃមនុស្សទាំងឡាយនោះ តាមការចាំបាច់ដែលកើតមានឡើង ។ វិសាខាជាស្ត្រីមានលម្អខាងរូបកាយ ៥ ប្រការក្នុងឋានៈនៃនាងជាបុត្តប្រសានៃម្ចាស់ផ្ទះ លម្អទាំង ៥ យ៉ាងនេះបានធ្វើឲ្យនាងបានទទួលនូវឯតទគ្គ ខាងលម្អរូបក្នុងគេហដ្ឋានឪពុកក្មេក ម្តាយក្មេករបស់នាងផង ក្នុងនគរសាវត្ថីផង ។ លម្អ ៥ ពោលគឺសក់ល្អ, សាច់ល្អ, ធ្មេញល្អ, សម្បុរស្បែកល្អ, និងវ័យល្អ ។

សក់ល្អគឺសក់របស់នាងមានលក្ខណៈទ្រង់ទ្រាយដូចរោមកន្ទុយបក្សីក្ងោកដែលវាកំពុងតែកាងពង់, វែងស្រុងចុះក្រោម

ទល់ភាគមណ្ឌលនៃចង្កេះ នៅត្រង់ទីបំផុតនៃចុងសក់ដ៏ញឹកល្អិតនោះមានស្លានខ្វេរង់ឡើងខាងលើគ្រប់សរសៃ សាច់ល្អ ក៏គឺបបូរមាត់របស់វិសាខាមានសម្បុរក្រហមព្រឿងៗ ដូចផ្លែម្រះទុំ ធ្មេញល្អក៏គឺធ្មេញសមានជាតិប្រេងធម្មជាតិផុរលោយមានសម្បុរស តែសមានឈាមដូចសម្បុរក្ដុកដំរី ស្បែកល្អ ក៏គឺស្បែកនោះសូម្បីវិសាខាមិនបានប្រើគ្រឿងលាបគ្រឿងសម្អាងអ្វីសោះ ក៏នៅតែល្អម៉ត់ចត់ផូរផង់មានលក្ខណៈទ្រង់ទ្រាយដូចក្ដួងផ្កាឈូក មានសម្រស់សថ្វាដូចផ្កាកណ្ណិការ វ័យល្អ គឺវ័យខាងក្រោយអំពីកាលដែលនាងបានឲ្យកំណើតបុត្រ ២០ នាក់ហើយ ក៏នៅតែល្អដដែលដូចជាលម្អនៃស្ត្រីមានវ័យក្រមុំ ។

វិសាខាមានលម្អមួយពិសេសទៀត បានដល់សំឡេងក្នុងការណាវិសាខាហើបមាត់និយាយម្ដងៗ មានមនុស្សផ្ទៀងស្ដាប់ស្ងាត់ជ្រាប ព្រោះសំឡេងរបស់នាងពិរោះវិស័យដូចសំ-

ល្អូវរគាំងដែលគេសិតដោយធាតុប្រាក់ ឬ សំឡេងតន្ត្រីដែលមានគ្រឿងពាណូដឹកនាំ ។

ក្នុងពេលដែលវិសាខាត្រូវចេញទៅនៅខាងស្វាមី មាតាបិតារបស់គឺក៏បានចែកឲ្យនូវគ្រឿងតែងកាយ មានតម្លៃស្មើរកាត់មិនបានហៅថា "មហាអាភរណៈបក្សីដើរដី" គ្រឿងប្រដាប់តែងកាយនេះគេធ្វើជារូបក្ងោកមួយតួ រោមស្លាបរបស់វាមួយៗ ធ្វើដោយមាសសុទ្ធមានទឹក ១០ ក្នុងស្លាបម្ខាងៗ មាន ៥០០ សន្ទឹក មាត់របស់វាធ្វើដោយផ្កាថ្មកែវ ភ្នែក ក និងរោមខ្នងធ្វើដោយពេជ្រ ប្រកបត្បូង ។ កាលណាវិសាខាពាក់គ្រឿងអាភរណៈនេះលើក្បាលរបស់នាង គេមើលទៅឃើញភាពនាងស្រដៀងភាពបក្សីក្ងោក ទំនៅលើទីមួយខ្ពស់ស្រឡះ មានសំនៀងភ្លេងដែលពន្ទេង ដោយការរណ្តំនៃគ្រឿងតែងកាយរបស់នាង ឮសូរវងំបណ្តាលឲ្យស្ទីកត្រចៀកនៃអ្នកទស្សនាទាំងឡាយស្ថិតនៅស្ងៀមស្ងាត់ប្រុងប្រយ័ត្នដូច

ជាក្អែកដែរ ។

វិសាខា ជាស្ត្រីមានបុណ្យបានសាងច្រើន បានធ្វើគ្រប់មុខបុណ្យទាំងអស់ សូម្បីតែបុណ្យដែលមិនមាននរណាឃើញក៏នាងបានធ្វើដោយច្រើន មានជាអាទិ៍បុណ្យជួយរំដោះទុក្ខលំបាកនៃមនុស្សមានជំងឺ មនុស្សជរា មនុស្សកំព្រាញាតិ កូនក្មេង មនុស្សវង្វេងផ្លូវ មនុស្សមានសេចក្តីខ្វះខាតសម្ភារៈក្នុងដំណើរចេញទៅ មនុស្សមានសេចក្តីខ្វះខាតក្នុងពាក់កណ្តាលដំណើរ មនុស្សមានសេចក្តីខ្វះខាតក្នុងដំណើរចូលមក មនុស្សមានសេចក្តីខ្វះខាតក្នុងដំណើរកំពុងបំពេញបេសកកម្មនានា ។ ល ។ ជាពិសេសជាងនេះទៅទៀត គឺវិសាខាចូលចិត្តធ្វើច្រើន នូវបុណ្យណាដែលអ្នកដទៃគេមិនសូវចង់ធ្វើ ដូចជាជួយសង្គ្រោះមនុស្សរងគ្រោះ ជួយបន្ថែមធនធានលើកុសលរួមដែលមានចំនួនសេសឲ្យគត់ ជួយសង់បង្ហើយនូវសំណង់អ្វីៗ ដែលគេ

ស្តាបនាមិនហើយព្រោះអស់បច្ច័យ ឬព្រោះមកអំពីរឿងអ្វីមួយ ជួយដឹកនាំអ្នកដំណើរដោយយាន, ជួយបំភ្លឺភ្លើងឲ្យបុគ្គលមានភ្នែកល្អមើលឃើញផ្លូវ ។ ល ។ បុណ្យទាំងឡាយនេះគឺធ្វើក្នុងបច្ចុប្បន្នជាតិខ្លះ ក្នុងអតីតជាតិខ្លះ មិនតែប៉ុណ្ណោះគឺតាំងចិត្តថានឹងធ្វើបុណ្យបែបនេះ ទៅក្នុងអនាគតជាតិទៀតផង ។ ដោយអាស្រ័យកម្លាំងបុណ្យទាំងឡាយនេះជួយទំនុកបម្រុងវិសាខាទើបត្រូវបានសម្រេចនូវសម្បទា ៥ យ៉ាងគឺ:

១) **ញាតិសម្បទា** សម្បទាពោលគឺសម្បូណ៌ញាតិ

២) **ភោគសម្បទា** សម្បទាពោលគឺសម្បូណ៌ទ្រព្យ

៣) **អរោគ្យសម្បទា** សម្បទាគឺមិនមានរោគ

៤) **សីលសម្បទា** សម្បទាគឺមារយាទថ្លៃថ្នូរ

៥) **ទិដ្ឋិសម្បទា** សម្បទាគឺមានបញ្ញាវាងវៃ ។

មានការស្ងាត់កំបាំងមួយទៀតគឺ វិសាខា មានកម្លាំងរូបកាយ (កម្លាំងសាច់ដុំ) ខុសអំពីកម្លាំងសាច់ដុំអ្នកដទៃជាច្រើន ព្រោះវិសាខាចូលចិត្តជួយមនុស្សមានកម្លាំងទន់ខ្សោយ ដើម្បីយកផលបុណ្យច្រើនជាងជួយមនុស្សខ្លាំងពូកែ ដើម្បីយកកេរ្តិ៍ឈ្មោះ ។

ដែលថា : វិសាខាសម្បូណ៌ញាតិ, ញាតិក្នុងទីនេះលោកមិនបានគិតត្រឹមតែមនុស្សរួមលោហិតទាំង ៧ ជួរទេ គឺគិតដល់មនុស្សទាំងអស់ណាដែលបានស្គាល់រាប់អាន វិសាខាទាំងជនក្នុងប្រទេសទាំងជនបរទេស ។ ញាតិមិត្ររបស់វិសាខាមិនមែនមានតែជនមានទ្រព្យសម្បត្តិស្តុកស្តម្ភ មានយសស័ក្តិធំដុំទេ, ដែលច្រើនបំផុតគឺញាតិមិត្រអនាថា ក្រខ្សត់ទ្រព្យសម្បត្តិ ព្រោះអ្វី? ព្រោះវិសាខាចូលចិត្តធ្វើសេចក្តីស្និទ្ធស្នាលកៀកកើយជាមួយមនុស្សអន់ជាងមនុស្សគ្រាន់ ។

ដែលថា : វិសាខាសម្បូណ៌ទ្រព្យសម្បត្តិនោះ គឺវិ-

សាខាមានទ្រព្យសម្បត្តិលើសវិស័យនៃការរាប់ចំនួន, តែគេអាចគិតគូរឲ្យដឹងចំនួនតាមក្បួនគណិតសាស្ត្របានដែរ ។ ដូចម្តេចទើបវិសាខាមានទ្រព្យសម្បត្តិច្រើនម៉្លេះ? ចម្លើយមានតែពីរ ។ ១) មានច្រើនព្រោះត្រកូលនេះមានតៗគ្នាមក លុះដល់មកឪពុកម្តាយវិសាខាមិនមានពូជា មានកូនច្រើន គឺមានតែវិសាខាតែមួយជាអ្នកទទួលមត៌ក ។ ២) មានព្រោះបុណ្យក្នុងអតីតជាតិបានធ្វើឲ្យអតីតវិញ្ញាណ របស់វិសាខាមានគុណភាពល្អបរិសុទ្ធ ហើយវិញ្ញាណនោះក៏បានតាក់តែងបង្កើតឲ្យបានវិញ្ញាណថ្មី ដោយអាស្រ័យវិញ្ញាណចាស់ល្អ, វិញ្ញាណថ្មីក៏ល្អដូចវិញ្ញាណចាស់ដែរ ។ វិញ្ញាណល្អត្រូវតែមកកើតក្នុងផ្ទៃនៃត្រកូលមាន ទ្រព្យសម្បត្តិច្រើនដូចនេះឯង ។

ដែលថា : វិសាខាមិនមានរោគ រោគក្នុងទីនេះលោកមិនបានរាប់យកសេចក្តីស្រេកឃ្លានជុះនោមផងទេ គឺលោក

គិតអំពីជម្ងឺ[១] គ្រុនរដូវគ្រុនចាញ់ជាដើមឡើងទៅ ជម្ងឺទាំងឡាយនេះវិសាខាមិនមានទេ ព្រោះមានបុណ្យក្នុងអតីតកាលជួយការពារផង មានអនាម័យក្នុងបច្ចុប្បន្ននៅជុំវិញជីវិតរបស់នាងជារបាំងផង ។

ដែលថា : វិសាខាមានចរិយាមារយាទថ្លៃថ្នូរនោះ គឺវិសាខាមិនមែន ជាស្ត្រីទុកដាក់ជាមិត្តរបស់ខ្លួន ចំពោះតែបុគ្គលដែលមានខ្សែលោហិតជាមួយគ្នាទេ ចំពោះតែដែលមានរូបល្អ មានទ្រព្យសម្បត្តិ មានយសស័ក្តិ ។ ល ។ ប៉ុណ្ណោះទេ មនុស្សនៅក្នុងឋានៈណា ជាតិសាសន៍ណា ក្នុងត្រកូលអម្បូរណា ក្នុងវណ្ណៈណា ក្នុងពណ៌សម្បុរណា ។ ល ។ ក៏វិសាខាយកជាមិត្តទាំងអស់ តែនាងមិនបណ្តោយឲ្យខូចសីលធម៌របស់នាង ព្រោះតែមារយាទថោកទាបរបស់គេទេ ។ ដូច្នេះហើយបានជាក្នុងពេលដែលគេ

(១) ជម្ងឺ ប្រើជំនួសជំងឺតាមក្បួនវេយ្យាករណ៍

លើកនាងឲ្យទៅធ្វើជាប្រពន្ធបុណ្ណវឌ្ឍនៈ ដោយគេឥតមានសួរចិត្តរបស់នាង ក៏គឺមិនមានប្រកែក ទោះជាបានដឹងថាទាំងខ្លួនបុណ្ណវឌ្ឍនៈ ទាំងវង្សត្រកូលជាវត្ថុធាតុមួយដែលនាងមើលឃើញថាមិនល្អក៏ដោយ ព្រោះអ្វី? ព្រោះនាងគិតថាអ្វីៗ ទាំងអស់មិនមែនមិនមានបញ្ហាចោទទេ ។ ដូច្នេះអាត្មាអញត្រូវតែទទួលស្រាយបញ្ហាដែលគេដាក់ឲ្យលុះត្រាតែរួច ទើបឈ្មោះថាជាកូនស្រីនៃត្រកូលមួយ ដែលអ្នកជិតខាងធ្លាប់គោរព និងផ្ញើសេចក្ដីសង្ឃឹមទុកលើខ្លួន ។

ដែលថា : វិសាខាសម្បូណ៌បញ្ញាវាងវៃ បញ្ញាក្នុងទីនេះលោកមិនគិតយកត្រឹមតែវិជ្ជានានា ដែលរៀនអំពីគ្រូទេ គឺគិតដល់សេចក្ដីឆ្លៀវឆ្លាតឆាប់យល់ការណ៍ ឆាប់ឃើញការណ៍អ្វីទាំងអស់នៅជុំវិញខ្លួនរបស់នាង ។ វិសាខាមានទាំងបញ្ញាដែលកើតអំពីការសិក្សាចាកគ្រូ ។ មានទាំងបញ្ញាដែលកើតអំពីការពិចារណាឃើញដោយខ្លួនឯង ។

នៅក្នុងផ្ទះឪពុកក្មេក វិសាខាបានជួបនឹងសេចក្តីពិតដែលនាងបានគិតទុកជាមុនថាមុខតែនឹង ...... រឿងនោះគឺឪពុកក្មេករបស់នាង គេកាន់សាសនាអ្នកបួសស្មៀកអាកាសពួកមួយ អ្នកបួសទាំងឡាយនេះ រួមទាំងឪពុកក្មេករបស់នាងផង បាននិយាយផ្តោះផ្តងចំអកឡកឡឺយដៀមដាមក្នុងឥរិយាបថប្រមាថមើលងាយព្រះអរហន្តសម្មាសម្ពុទ្ធ ហេតុនេះបានធ្វើឲ្យនាងវិសាខាមិនសប្បាយចិត្តយ៉ាងខ្លាំង ។

មានថ្ងៃមួយបព្វជិតស្មៀកមេឃបាននិយាយទៅកាន់មិគារៈថា :

"ឱ ញោម អ្នកបាននាំយកមកនៅក្នុងគ្រួសាររបស់អ្នកនូវមនុស្សអាក្រក់បំផុត ខ្លួនគឺគឺជាសាវ័ករបស់ សមណគោតមៈ ។ចូរអ្នកបណ្តេញវាចេញចាកទីនេះដោយប្រញាប់ទៅ"។

មិគារ : នឹកតែក្នុងចិត្តថា "រឿងនេះមិនមែនងាយទេ! ព្រោះវិសាខាជាស្ត្រីមកចាកត្រកូលស្តុកស្តម្ភណាស់ , តែ

អាត្មាអញមិនធ្វើតាមសំណូមពរ របស់លោកគ្រូទាំងឡាយនៃអញក៏មិនកើត ដូច្នេះ អញត្រូវរំពៃគយគន់មើលគ្រប់នាទីទាំងអស់របស់វិសាខាឃើញមិនមោះសមត្រង់ណា អញនឹងចាប់ផ្តាក់ ហើយបណ្តេញចេញភ្លាម" ។

ផ្តាក់បានកើតមានឡើង ក្នុងពេលដែលមិគារៈកំពុងហុតយាគូផ្សំទឹកដោះក្នុងចានមាស ដែលមានវិសាខាអង្គុយនៅក្បែរខាង មានដៃកាន់ផ្លិតស្លាបបក្សីដង់ភ្លុកកំពុងបក់ខ្យល់ជូនឪពុកក្មេកដោយគោរពយ៉ាងទន់ភ្លន់ ។ ក្នុងពេលជាមួយគ្នានេះ មានព្រះសង្ឃមួយអង្គមានឥន្ទ្រីយ៍គួរអ្នកផងចង់គោរព លោកនិមន្តចូលមកដើម្បីបិណ្ឌបាត តែមិគារៈក្លែងធ្វើជាមិនឃើញ គាត់ឈ្ងោកហុតយាគូរឿយៗ ទៅ ។

វិសាខានិយាយទៅកាន់ភិក្ខុអង្គនោះ ដោយសម្តីយ៉ាងថ្នមទន់ភ្លន់ថា :

"និមន្តហួសផ្ទះនេះទៅចុះព្រះករុណាខ្ញុំ លោកឪពុក

ខ្ញុំកំពុងពិសាអាហារចាស់, លោកឪពុករបស់ខ្ញុំពុំបានគិតគូរដល់អាហារថ្មីទេ" ។ លុះឮសម្ដីនេះរបស់វិសាខាភ្លាមមិគារៈប្រឡោតតូងក្រោកឈរស្រែកសន្ធាប់ង៉ាងថា :

"យកយាគូនេះចេញទៅ ដេញវាចេញចាកផ្ទះនេះភ្លាមទៅ ទាំងអស់គ្នាជួយគិតអញមើល វាគួរដែរឬ? មេស្រីចង្រៃនេះ វាអួតខ្លួនវាថាល្អ វាស្ដីចំពោះមុខថាអញស៊ីអាហារចាស់ វានិយាយក្នុងពេលដែលអញកំពុងតែស៊ីឆ្ងាញ់!"

"លោកប៉ា!" វិសាខានិយាយក្នុងឥរិយាបថយ៉ាងស្ងប់ស្ងៀម ។

"កូនចុះចេញចាកផ្ទះនេះភ្លាមៗ ពុំទាន់បានទេ ព្រោះកូនមិនមែនជាស្រីសោភេណីទេ កូនជាស្រីរបស់ត្រកូលអ្នកមានសីលធម៌មួយ ឪពុករបស់កូនបានដៅស្នានទុកជាមុនហើយថានឹងមានរឿងបែបនេះកើតឡើងជាមិនខាន ដូច្នេះ

មុននឹងឲ្យខ្ញុំមកនៅក្នុងទីនេះ លោកឪពុកបានតែងតាំងព្រាហ្មណ៍ព្រឹទ្ធាចារ្យ ៨ នាក់នៅក្នុងតំណែងជាឧត្តមប្រឹក្សា សម្រាប់វិនិច្ឆ័យឲ្យដឹងក្តីខុសត្រូវ សូមលោកប៉ាជ្រាប ហើយសូមលោកប៉ាប្រើអ្នកបម្រើឲ្យទៅអញ្ជើញព្រាហ្មណ៍ទាំងឡាយនោះមក" ។

មិគារៈ យល់ព្រមផងដោយសេចក្តីរីករាយ ព្រោះគាត់គិតថា ព្រាហ្មណ៍ទាំងឡាយក៏គង់សម្រេចសេចក្តីឲ្យគាត់ត្រូវឲ្យវិសាខាខុស ។ ក្នុងបណ្តាព្រាហ្មណ៍ទាំង ៨ នាក់ មានព្រាហ្មណ៍ម្នាក់ជាវុឌ្ឍិសមាជិកនៃអង្គឧត្តមប្រឹក្សា ក៏បានទទួលមកតាមសេចក្តីអញ្ជើញ មិគារៈ បានផ្តើមនិយាយរឿងដែលកើតមានឡើងឲ្យព្រាហ្មណ៍ទាំងឡាយស្តាប់ ។ ព្រាហ្មណ៍ទាំងឡាយក៏បានតាំងសំនួរនិងស្តាប់ចម្លើយ ដូចមានតទៅនេះ ៖

សំនួរ: "កូនស្រីសំឡាញ់ចិត្ត" , ក្រោយអំពី

នាងបានស្តាប់សេចក្តីរាយការណ៍ របស់ឪពុកក្មេកនៃនាង ហើយ "តើរឿងទាំងអស់ពិតដូច្នោះមែនឬ?"

ចម្លើយ : "មិនត្រូវតាមចំណាំរបស់នាងខ្ញុំឡើយ!" ព្រោះក្នុងខណៈដែលឪពុកក្មេករបស់នាងខ្ញុំ ស្តែងកិរិយារំលងហី មិនងាកមៀងមើលព្រះភិក្ខុអង្គនោះ ហើយដែលនាងខ្ញុំនិយាយថា : "លោកប៉ារបស់ខ្ញុំព្រះករុណាកំពុងធីអាហារចាស់ " ពាក្យនេះមិនមែនមានន័យទៅលើអាហារចាស់មែនទែនទេ គឺមានន័យទៅលើបុណ្យចាស់ ព្រោះខ្ញុំចង់និយាយឲ្យព្រះភិក្ខុអង្គនោះជ្រាបក្នុងព្រះទ័យរបស់លោកថា "លោកឪពុកក្មេករបស់ខ្ញុំ លោកអាស្រ័យតែបុណ្យចាស់ លោកមិនសាងបុណ្យថ្មីទៀតទេ តើវាខុសទៅប៉ុណ្ណាបើខ្ញុំនិយាយប៉ុណ្ណោះ?"

"មិនមានកំហុសអ្វីទេ កូនស្រីសម្លាញ់ចិត្ត", ប្រធានឧត្តមប្រឹក្សាពោលបញ្ជាក់ ។ "កូនស្រីរបស់យើងនិ-

យាយត្រឹមត្រូវណាស់ ដូចម្ដេចទើបលោកត្រឡប់ជាខឹងគ្នោរក្រមាល់នឹងគីទៅវិញ?"

"រឿងនេះ យល់ព្រមលើកទោសឲ្យ ព្រោះមិនមានកំហុសមែន" មិគារៈឆ្លើយតប ។

តែអំពីកាលដែលនាងចេញចាកផ្ទះរបស់នាង មកនៅជាមួយខ្ញុំ ម្ដាយរបស់នាងបានឲ្យមេរៀន ១០ យ៉ាង មេរៀនទាំងអស់នោះខ្ញុំស្ដាប់មិនយល់មិនចូលចិត្តសោះ ចំណុចដំបូងគឺ "ភ្លើងក្នុងផ្ទះកុំនាំយកចេញចាកទ្វារទៅខាងក្រៅ" ។ ចំពោះរឿងនេះលោកឧត្ដមប្រឹក្សាក៏ធ្លាប់ជ្រាបស្រាប់ហើយថា: ត្រកូលរបស់យើង មានទំនៀមទម្លាប់ខាងបញ្ជូនភ្លើងពីផ្ទះមួយទៅផ្ទះមួយទៀតជាធម្មតា គឺយើងធ្លាប់ចែកភ្លើងគ្នាប្រើប្រាស់ជាប្រក្រតីមកហើយ ប្រសិនបើយើងយកមេរៀននេះមកអនុវត្ត យើងក៏មិនដឹងជានឹងរស់នៅជាមួយគ្នាយ៉ាងណាកើតទេ" មិគារៈចោទប្រកាន់ ។

សំនួរ : "វាចាសេចក្តីពិតដូចជាពាក្យដែលគេនិយាយឬទេ, កូនស្រីសម្លាញ់ចិត្ត?"

ចម្លើយ : "លោកឧត្តមប្រឹក្សា វាមិនមែនមានន័យយ៉ាងនេះទេ ពាក្យថាភ្លើងក្នុងមេរៀននេះ មិនមែនជាភ្លើងរបស់ធម្មជាតិសុទ្ធៗ មែនៗ ទេ គឺជាសម្តីដែលលោកប្រៀបធៀបដូចជាភ្លើងទេតើ បំណងរបស់មេរៀននេះគឺចង់ឲ្យមនុស្សយើងរៀនរស់នៅក្នុងវង្សត្រកូលឲ្យបានសុខ សប្បាយ កាលណាមានរឿងថ្មោះថ្មាយ ឬ មានរឿងមិនល្អកើតឡើង លោកហាមមិនឲ្យនាំយកទៅនិយាយប្រាប់គ្រួសារដទៃ ព្រោះមិនមានភ្លើងឯណាមានកម្តៅជាងភ្លើងគឺសំដីចាក់រុក ឬ សំដីមិនល្អនេះទេ" ។ នេះជាសេចក្តីខុស ព្រោះតែខ្ញុំនិយាយទៅកាន់ព្រះភិក្ខុដែលលោកឈរនៅខាងក្រៅទ្វារផ្ទះនោះឬ?

ចំពោះចម្លើយនេះ មិគារៈមានសេចក្តីអៀនខ្មាសយ៉ាង

ខ្ទាំងកើតឡើង ទើបគាត់និយាយថា :

“រឿងនេះសុខចិត្តលើកទោសឲ្យ តែគឺបានទទួលការអប់រំចាកមេរៀនថា : “ភ្លើងខាងក្រៅត្រូវកុំនាំចូលមកខាងក្នុងទ្វារផ្ទះ” មេរៀននេះក្នុងគ្រួសាររបស់យើងមិនអាចអនុវត្តបានទេ ព្រោះប្រពៃណីស្រុកភូមិធ្លាប់បានប្រាស្រ័យគ្នាអំពីរឿងភ្លើងនេះគ្រប់ពេលវេលាមកហើយ ព្រោះហេតុដូច្នេះមេរៀននេះខ្ញុំមិនត្រូវការជាដាច់ខាតហើយ” ។

ក្រោយអំពីពេលបានដាកមកខ្សិបគ្នាទំនងដូចពិគ្រោះរកផ្លូវចេញ ប្រធានឧត្តមប្រឹក្សាក៏ធ្វើសំនួរបន្ថែមតទៅទៀត :

សំនួរ : ម៉េចកូនស្រី រឿងនេះវាមានការណ៍ពិតដូចគេនិយាយមែនឬ?”

ចម្លើយ : ចា៎ះ មិនមែនទេលោកឧត្តមប្រឹក្សា,” គឺន័យមានថា បើមនុស្សក្រៅផ្ទះនិយាយពាក្យអាក្រក់ជាមួយមនុស្សណាម្នាក់ ចូរកុំពាំនាំយកពាក្យនោះ ទៅនិយាយ

នៅខាងក្នុងទ្វារផ្ទះ ព្រោះមិនមានភ្លើងណា ៗ ទាំងអស់ ក្តៅជាងភ្លើងគឺអណ្តាតមិនល្អទេ” ។

“ត្រូវណាស់ ពិរោះណាស់ កូនស្រីសម្លាញ់ចិត្ត ចុះក្រៅអំពីរឿងនេះ មានរឿងអ្វីទៀតដែរ?”

វិសាខាទើបអធិប្បាយតាមដែលគីចាំបានយ៉ាងច្បាស់ៗ មួយៗថា :

“នាងខ្ញុំបានទទួលការអប់រំថា ចូរធ្វើនូវអំណោយ ដល់មនុស្សដែលគេបានធ្វើដល់ខ្លួន និងចូរធ្វើអំណោយដល់ មនុស្សដែលគេមិនបានធ្វើដល់ខ្លួនផង” ។ ក្នុងចំណុចនេះ មានន័យថា ជាមនុស្សត្រូវមានសេចក្តីមេត្តាករុណា ញាតិ មិត្តជិតឆ្ងាយទូទៅដែលគ្នាទីទ័លក្រ ឬដែលរងគ្រោះថ្នាក់ ទោះជាគេមិនមានចិត្តមេត្តាករុណាយើង មិនធ្លាប់ដែលបាន ជួយសង្គ្រោះយើងក៏ដោយ ។ “ចូរអង្គុយយ៉ាងមានសេច-ក្តីសុខ” ។ ក្នុងចំណុចនេះមានន័យថា “កាលណា

អ្នកស្ត្រីឃើញឪពុកក្មេកម្តាយក្មេកនិងស្វាមីរបស់ខ្លួន អ្នកស្រីត្រូវក្រោកឡើងទទួល ឈរនៅចំពោះមុខរបស់លោកទាំងនោះ" ។ "ចូរស៊ីយ៉ាងមានសេចក្តីសុខ" ។ ក្នុងចំណុចនេះមានន័យថា : "អ្នកស្រីត្រូវចាត់ចែងរៀបចំអាហារចំណីជូនឪពុកក្មេកម្តាយក្មេកនិងស្វាមីរបស់ខ្លួន ឲ្យលោកទាំងអស់នោះបរិភោគមុន" ។ "ចូររំពៃឧស្សាហ៍បម្រើភ្លើង" ។ ក្នុងចំណុចនេះមានន័យថា : "អ្នកស្រីត្រូវរំពៃព្យាយាមគោរពប្រតិបត្តិឪពុកក្មេក ម្តាយក្មេក និងស្វាមីរបស់ខ្លួន ដូចជាគេព្យាយាមថែទាំរក្សាភ្លើងទៀនឲ្យឆេះល្អដូច្នោះដែរ" ។ "ចូរគោរពបូជាពួកទេព[១] ក្នុងគេហដ្ឋាន" ។ ក្នុងចំណុចនេះមានន័យថា : "បុគ្គលទាំង ៣ ពួក គឺឪពុកក្មេក ម្តាយក្មេក និងស្វាមីរបស់ខ្លួន ជាបុគ្គលត្រូវបានទទួលការគោរពបូជា

(១) ទេព តំណែងនៃឈ្មោះនេះ មិនមែនមានតែមាតាបិតានិងស្វាមីទេ ស្ត្រីជាភរិយាក៏លោកហៅថា ទេពដែរប្រសិនបើស្ត្រីនោះមានសីលធម៌ ។

ចាកកូនប្រសានិងកិរិយាដោយពិត" ។ "ចូរគេងយ៉ាងមានសេចក្ដីសុខ" ។ ក្នុងចំណុចនេះមានន័យថា : "អ្នកស្រីមិនត្រូវដាក់ កាយចុះលើទីគំនេងមុនអំពីកាលបានបំពេញមុខងារគ្រប់យ៉ាងឲ្យជនទាំង ៣ ស្រេចបាច់អស់ហើយ" ។ ច្បាប់ទាំងអស់នេះ នាងខ្ញុំបានគោរពប្រតិបត្តិដោយឥតមានសល់ខាន," តើមានអ្វីខ្លះដែរដែលនាងខ្ញុំបានធ្វើខុសសូមមេត្តាប្រាប់ខ្ញុំផងមើល?"

មិគារៈមានមុខសំយុងចុះអង្គុយស្ងៀមនៅដូចរូបស៊ីម៉ងត៍ដែលគេផ្អែកនៅជើងសសរ ។ ឧត្តមប្រឹក្សាទាំង ៨ នាក់បាននិយាយថា : "លោកសេនាបតីយ៉ាំង មានសេចក្ដីប្រព្រឹត្តមិនល្អអ្វីខ្លះទៀតដែរឬ ដែលកូនប្រសារបស់លោកបានប្រព្រឹត្តក្រៅអំពីក្រឹត្យស្ត្រីទាំង ១០ ប្រការ? ព្រោះក្រឹត្យ ១០ នាងពុំបានប្រព្រឹត្តល្មើសទេ តាមដែលយើងខ្ញុំបានសួរបានស្ដាប់ បានពិចារណាល្អិតល្អន់សព្វគ្រប់មកហើយនោះ"

"មិនមាន មិនមានសោះឡើយ" ។ មិគារៈតប ។

ក្នុងខណៈនោះ វិសាខា ក្រោកឈរសម្ដែងសេចក្ដីក្រោធខឹងថា :

"អ៊ំឧត្ដមប្រឹក្សាទាំងឡាយ" គឺនិយាយ "ជាការមិនសមគួរសោះឡើយ ដែលនាងខ្ញុំត្រូវគេដេញដោយមិនមានកំហុសក្នុងវិន័យរបស់មនុស្ស ។ តែទោះណាជាខ្លួនខ្ញុំមិនមានកំហុស ក៏ខ្ញុំត្រូវតែដើរចេញចាកទីនេះព្រោះស្ថានការណ៍ក្នុងផ្ទះនិងសីលធម៌ខាងផ្លូវចិត្តវាតម្រូវឲ្យចេញ ឲ្យលាគេទៅក្នុងពេលនេះ ខ្ញុំដល់ម៉ោងហើយ ខ្ញុំសូមលាសិនហើយ"

វិសាខាបានបញ្ជាឲ្យអស្សរថ ច្រើនរយតួនិងមនុស្សបម្រើរបស់នាងច្រើនរយនាក់រៀបចំអីវ៉ាន់ត្រៀមខ្លួន ដើម្បីធ្វើដំណើរត្រឡប់ទៅកាន់ផ្ទះកំណើតវិញ ។ មិគារៈ ឃើញហេតុការណ៍មិនស្រួលដូច្នោះ ទើបនិយាយអង្វរលន់តួ សូមឲ្យ

វិសាខានៅក្នុងផ្ទះក្នុងឋានៈជាកូនប្រសារបស់ខ្លួនតទៅ ។ សំណូមនេះ ត្រូវវិសាខាទាត់ចោលភ្លាម តែមិគារៈទោះណាជាមានកម្មាចមានអំនៀនប៉ុណ្ណាក៏គាត់ ចេះតែខំប្រឹងនិយាយអង្វរវៀយៗ គាត់សម្តែងសេចក្តីប្រាថ្នាយ៉ាងក្លៀវក្លា សូមឲ្យវិសាខាលើកទោសឲ្យគាត់ ។

"លោកអ៊ំឧត្តមប្រឹក្សាទាំងឡាយ" វិសាខាតប "ទំហើណាដែលគួរឲ្យខ្ញុំលើកទោសឲ្យ ខ្ញុំនឹងយល់ព្រមលើកទោសឲ្យយ៉ាងរីករាយសប្បាយចិត្ត ។ តែក្នុងឋានៈនៃខ្លួនខ្ញុំជាបុត្តនៃគ្រួសារដែលមានសទ្ធាជ្រះថ្លាក្នុងធម្មៈ នៃព្រះសម្មាសម្ពុទ្ធ ប្រសិនបើគេអនុញ្ញាតឲ្យខ្ញុំបម្រើគណៈសង្ឃរបស់ខ្ញុំខ្ញុំនឹងនៅក្នុងទីនេះតទៅ ។ បើមិនដូច្នោះទេ ខ្ញុំសូមលាដាច់ខាតហើយ" ។

មិគារៈឆ្លើយថា :

"កូនស្រីដួងជីវិត ចូរកូនបម្រើគណៈសង្ឃរបស់កូនតាម

សេចក្តីពេញចិត្តចុះ" ។

ក្រោយអំពីកាលបានព្រមព្រៀងគ្នាហើយ វិសាខាក៏បាននាំមិគារៈទៅគាល់ ព្រះសម្មាសម្ពុទ្ធដើម្បីស្តាប់ព្រះពុទ្ធោវាទ ព្រះបរមសាស្តាទ្រង់សម្តែងធម៌ល្អៃលម្អមដល់និស្ស័យរបស់គាត់ ដោយធម្មទេសនារបស់ព្រះអង្គ ជាធម្មទេសនាមានបច្ចេកទេសគ្រប់គ្រាន់ ធម៌នេះក៏បានជ្រាបចូលទៅក្នុងបេះដូងរបស់គាត់ លុះចប់ធម្មទេសនាគាត់ក៏បានប្រកាសថ្វាយខ្លួនជាឧបាសកក្នុងពុទ្ធសាសនា ។ មុនកាលក្រោកចេញចាកវត្តទៅបានកើតមានមិគារឧទានថា :

"ប្រយោជន៍ល្អ កេរ្តិ៍ឈ្មោះល្អ គុណធម៌ល្អ ធម្មជាតុទាំងអស់នេះជារបស់ដែលអាត្មាអញបានមកអំពីកូនប្រសា"

លុះមកដល់មាត់ជណ្តើរផ្ទះ មិគារៈបានលើកដៃម្ខាងរបស់គាត់ដាក់លើស្មានៃវិសាខា ហើយគាត់និយាយលួងលោមថា :

“ចាប់ដើមអំពីកាលនេះទៅ ខ្ញុំនឹងត្រូវជាកូនរបស់នាង ចំណែកខ្លួននាងត្រូវនៅក្នុងឋានៈជាម្ដាយរបស់ខ្ញុំ” ។ នេះគឺជាកិត្តិយសខ្ពង់ខ្ពស់បំផុតដែលឪពុកក្មេកបានលើកជូនកូនប្រសា ដោយអាស្រ័យកិត្តិយសនេះ ទើបមិគារៈ ចាត់ចែងឲ្យជាងមាសធ្វើគ្រឿងអាភរណៈប្រដាប់តែងកាយដាន់ខ្ពស់បំផុតហៅថា “ទេពធាយាលក្ខណ៍ដើរដី” គ្រឿងអលង្ការនេះគេធ្វើមានរូបប្រហែលគ្នានឹងគ្រឿងអលង្ការឈ្មោះ “អាភរណៈបក្សីដើរដី” ដែលបាននិយាយមកហើយនោះដែរ ។

វិសាខាជាស្ត្រីមានសីលធម៌ល្អ មានវិន័យសម្រាប់ប្រពៃណីនៃត្រកូល មានចិត្តមេត្តាករុណាច្រើន មានការធ្វើបុណ្យទានអស់កាលជានិច្ច មានវ័យវឌ្ឍនារឿយៗប្រៀបបាននឹងមណ្ឌលព្រះចន្ទ ក្នុងថ្ងៃពាក់កណ្ដាលខែឮតរហូតដល់ថ្ងៃចាស់ខែឮត ។ គឺមានបុត្រច្រើន គឺមានកូនប្រុស ១០ នាក់ កូនស្រី ១០ នាក់ ។ គឺរស់នៅយ៉ាងយូរលុះបាន

អាយុ ១២០ ឆ្នាំទើបអស់ជីពជន្ម មុនអស់អាយុសក់របស់គឺមិនស្កូវសូម្បីមួយសរសៃ ធ្មេញមិនមានបាក់ ស្បែកមិនមានយុរយារ សម្បុរមិនអាប់ វ័យមិនមានប្រែប្រួល ។ គឺដើរទៅវត្តជាមួយកូនៗ ចៅៗ អ្នកផងឃើញតែងសួរគ្នាថា :

"នរណាមួយជាយាយវិសាខា?"

ពាក្យឆ្លើយមានដូចតទៅនេះ៖ "វិសាខាសុភាពស្ត្រីមានចរិយានោះគឺជនដែលដើរយ៉ាងសម្រួមទីងជីងជាងគេទាំងឡាយនុ៎ះឯង"

វិសាខាជាស្ត្រីល្អគ្រប់ឥរិយាបថ កាលណានាងគេងនាងដើរ នាងឈរ នាងអង្គុយ អ្នកទស្សនាចង់ឲ្យនាងប្រព្រឹត្តនៅក្នុងឥរិយាបថមួយៗ រហូតទៅ គឺគេទាំងឡាយចង់ឃើញលម្អដែលមាននៅក្នុងគំនេង, ក្នុងដំណើរ, ក្នុង

ដំហរ, ក្នុងអំនុយ[១] មិនចង់ឲ្យនាងផ្លាស់ប្ដូរឥរិយាបថអំពីមួយទៅមួយទៀតឡើយ ។ គ្រប់តែឥរិយាបថរបស់វិសាខា មិនមាននរណាធ្វើសេចក្ដីរិះគន់ទិទៀនបានសូម្បីត្រឹមតែបន្ដិច ។

ធម្មជាតុដែលគេសង្គ្រោះចូលក្នុងរបស់មានតម្លៃច្រើនបំផុតរបស់វិសាខាគឺការចិញ្ចឹមអ្នកក្រ ឲ្យរស់នៅបានសុខស្រួលគ្រប់ៗ គ្នា ។ ការសាងបុណ្យយ៉ាងធំចុងក្រោយបង្អស់ គឺគឺបានចំណាយថ្វាយព្រះរាជាមួយព្រះអង្គនូវគ្រឿង "មហាអាភរណៈបក្សីដើរដី" យកបច្ច័យមកសាងវត្តមួយឈ្មោះ "បុញ្ញារាម" សាងមន្ទីរពេទ្យាបាលជម្ងឺ សាងផ្ទះសង្គ្រោះចែកអាហារ ចែកឱសថ ឲ្យអ្នកអត់ឃ្លាន អ្នកមានជម្ងឺបៀតបៀន ។ សេចក្ដីរាយការណ៍នៃជីវិតរបស់នាង គេអាចធ្វើបានយ៉ាងឆាយបំផុតខាងសំណង់ តែគេធ្វើបានយ៉ាង

(១) អំនុយពាក្យនាមមកពីកិរិយាស័ព្ទថា "អ៊ុយ" ដែលក្លាយមកជាអង្គុយ

លំបាកអំពីចិត្តមេត្តាករុណាដែលឧបាសិកានេះមានយ៉ាងច្រើន ទៅក្នុងមនុស្សជាតិគ្រប់វណ្ណៈ ។

ព្រះបរមសាស្តាទ្រង់និយាយអំពី រឿងវិសាខាមានដូចនេះ ៖

"ភិក្ខុទាំងឡាយ មាលាការដែលមានសេចក្តីស្ទាត់ជំនាញខាងធ្វើផ្កាឲ្យកើតបានជាកម្រង គេចេះតែព្យាយាមដោតក្រងបន្តិចម្តងៗ លុះត្រាតែបានកើតទៅជាកម្រងផ្កាធំៗយ៉ាងណាមិញ ចិត្តរបស់វិសាខាកូនរបស់យើងជាស្ត្រីមានចិត្តឱនលំទោនទៅក្នុងការងារ មានសេចក្តីព្យាយាមខ្ជាប់ខ្ជួនក្នុងការងារ ហើយញ៉ាំងការងារគ្រប់ប្រភេទឲ្យប្រព្រឹត្តទៅ ដោយក្រងការងារទាំងឡាយនោះឲ្យបានសម្រេចជារូបរាងយ៉ាងល្អួចម្ញែកដូចមាលាការនោះដែរ" ។ នេះគឺជារឿងរ៉ាវរបស់ជីវិតនៃស្ត្រីម្នាក់ ដែលបានស្រាយបញ្ហារស់នៅរបស់ខ្លួន ឲ្យមានដំណើរប្រព្រឹត្តទៅយ៉ាងស្រួលតាំងអំពី

កាលជាបឋមរហូតដល់កាលជាទីបំផុតនៃជីវិត ។

ជីវិតមនុស្ស ដែលអ្នកប្រាជ្ញសាកលប្រវត្តិសាស្រ្តបានទទួលស្គាល់ បានសរសេរក្នុងទំព័រសៀវភៅរបស់ខ្លួន ហើយដែលខ្ញុំបានដកស្រង់ យកមកសរសេរក្នុងសៀវភៅឈ្មោះ "បញ្ហាជីវិត" របស់ខ្ញុំចប់ប៉ុណ្ណោះហើយ ។ អ្នកអានចង់បកស្រាយជីវិតរបស់បុគ្គលទាំងឡាយនេះ ទៅលើអ្វីស្រេចហើយតែគំនិតអ្នកអានចុះព្រោះអ្នកអានក៏មានសេរីភាពពេញទីក្នុងការបកស្រាយបញ្ហាគ្រប់យ៉ាង ដូចអ្នកសរសេរដែរ ។

ក្នុងទីបំផុតនេះ ខ្ញុំសូមរំឭកមិត្តអ្នកអានថា ជីវិតរបស់យើង មានចោទឡើងជាបញ្ហាគ្រប់ជីវិត ដោយហេតុដូចនេះ ទើបអ្នកប្រាជ្ញវេយ្យាករណ៍លោកបានបង្កើតសញ្ញាមួយហៅថា "បុច្ឆនសញ្ញា" មានរូបដូច្នេះ"?" សម្រាប់ប្រើក្នុងភាសាសរសេរ ឧទាហរណ៍ ដេក? ដើរ? ឈរ?

អង្គុយ? ស៊ី? ផឹក? ធ្វើ? គិត? កើត? ចាស់? ឈឺ? ស្លាប់? រក? ទៅ? ច្បាំង? ជួយ? ចិញ្ចឹម? ។ ល ។ សរសេរឲ្យពេញជាប្រយោគពាក្យនិយាយថា គេដេកដូចម្តេច? គេដើរដូចម្តេច? គេឈរដូចម្តេច? គេអង្គុយដូចម្តេច? គេស៊ីនូវអ្វី? គេផឹកនូវអ្វី? គេធ្វើការអ្វី? គេគិតអំពីអ្វី? គេកើតអំពីអ្វី? គេចាស់ព្រោះអ្វី? គេឈឺព្រោះអ្វី? គេស្លាប់ព្រោះអ្វី? គេរកអ្វី? គេទៅណា? គេច្បាំងគ្នាយ៉ាងម៉េច? គេជួយទំនុកបម្រុងគ្នាដូចម្តេចខ្លះ? គេចិញ្ចឹមអ្នកដែរឬ? ។ ល ។ អ្នកអានក្រោយអំពីបានដឹងនូវចំណោទនៃជីវិតដូចខ្ញុំបាននិយាយមកដោយសង្ខេបនេះហើយ គប្បីព្យាយាមដោះស្រាយតាំងអំពីបញ្ហាដេក ដើរ ឈរ អង្គុយ ។ ល ។ រហូតដល់បញ្ហាសីលធម៌ បញ្ហានយោបាយ បញ្ហាសង្គមកិច្ច បញ្ហាវប្បធម៌ ។ ល ។ តាមសមត្ថភាពរបស់ខ្លួនដោយយកតម្រាប់តាមជីវិតរបស់បុគ្គល ដែលគេបានដោះ

ស្រាយបញ្ហាជីវិតរបស់គេរួចមកហើយមុនយើង ជាពិសេសគឺជីវិតនៃព្រះសម្មាសម្ពុទ្ធបរមគ្រូរបស់យើង តាំងអំពីនៅក្នុងទុសជាតក៏មានព្រះតេមិយៈជាដើម, រហូតដល់សោយព្រះជាតិជាព្រះសិទ្ធត្ថ ព្រោះជីវិតនៃព្រះអង្គជាជីវិតមានការពិសោធន៍ច្រើន មានការដោះស្រាយយ៉ាងត្រឹមត្រូវជាងជីវិតនៃបុគ្គលណាៗ ទាំងអស់ ។ ចំណែកខាងជីវិតរបស់បុគ្គលដទៃៗ យើងត្រូវត្រាប់តាមតែត្រង់ចំណុចដែលសំខាន់ ដែលមានមនុស្សធម៌ សីលធម៌និងឧត្តមគតិយ៉ាងថ្លៃថ្នូរ ។ តួយ៉ាងដូចជីវិតរបស់ហ៊ីត្លែរ៍ យើងត្រូវធ្វើតាមតែមុខងារណាល្អ ចំណែកមុខងារអាក្រក់យើងត្រូវទាត់ចោល កុំយកមកអនុវត្តឡើយព្រោះអ្វី? ព្រោះការងារអាក្រក់មិនមែនជាការងារសម្រាប់មនុស្សជាតិទេ ។

-ចប់-

# ពុទ្ធភាសិត

ស. វៀរចាកសេចក្តីអាក្រក់ = ជីវិតស្អាត

ក. សាងសេចក្តីល្អ = ជីវិតស្វាង រុងរោចន៍

ស. ចិត្តបរិសុទ្ធ = ជីវិតស្ងប់

ភិក្ខុ ជម្ពូចាល